រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចក្ខុវិស័យ និង យុទ្ធសាស្ត្រ
កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ដំណាក់កាលទី៤ ២០២៣-២០២៧



១ ដំណាក់កាលទី
ភាពរឿទុកចិត្តនៃថវិកា
២០០៤-២០០៨

២ ដំណាក់កាលទី
គណនេយ្យភាពហិរញ្ញវត្ថុ
២០០៩-២០១៥

៣ ដំណាក់កាលទី
ការផ្សារភ្ជាប់ថវិកាទៅនឹង
គោលនយោបាយ
២០១៦-២០២២

៤ ដំណាក់កាលទី
២០២៣-២០២៧

ប្រកាសដាក់ឱ្យអនុវត្ត នាថ្ងៃចន្ទ ១៤ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ផ្លូវ ៤២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ,
រាជធានីភ្នំពេញ, ប្រទេសកម្ពុជា
(+៨៥៥) ៨៥ ៧៧៧ ៩២៤
gsc@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm

អាញ្ជើយក

រៀបចំដោយ÷
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បុព្វកថា

ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា បាននិងកំពុងបន្តឈានឡើងជាលំដាប់ឥតឈប់ឈរ នៅលើមាគ៌ាដ៏ត្រឹមត្រូវនិងប្រកបដោយក្តីសង្ឃឹម។ ផ្លែផ្កាជាសមិទ្ធផលទទួលបាននាបច្ចុប្បន្ន ដុះចេញពីឫសគល់ដែលជាមូលដ្ឋានគ្រឹះពីអតីតកាល នោះគឺការបញ្ចប់ជាស្ថាពរនូវសង្គ្រាម និង ការធានាបាននូវសុខសន្តិភាពបរិបូរណ៌ពេញផ្ទៃប្រទេស។ សន្តិភាព គឺជាបុរេលក្ខខណ្ឌជាសកលនិងជាបរិយាកាសចម្បងមិនអាចខ្វះបានសម្រាប់ធានាដល់ដំណើរជីវិតជាប្រក្រតី និង ការរីកចម្រើនជឿនលឿនរបស់ប្រទេសជាតិ ក្នុងគ្រប់ផ្នែកគ្រប់វិស័យ, រួមបញ្ចូលទាំងការផ្តល់ឱកាសដល់ការកែលម្អ ឬ កែទម្រង់រចនាសម្ព័ន្ធ និង អភិបាលកិច្ចឱ្យកាន់តែប្រសើរឡើងថែមទៀតផងដែរ ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម។

ច្បាស់ណាស់ថា, កន្លងមក, យើងមិនបានរង់ចាំទាល់តែទទួលបានសុខសន្តិភាពបរិបូរណ៌ពេញផ្ទៃប្រទេស ទើបចាប់ផ្តើមកិច្ចការកែទម្រង់នោះទេ។ ផ្ទុយទៅវិញ, ដោយតម្កល់ឧត្តមប្រយោជន៍ជាតិ និង ប្រជាជន ជាធំ, យើងបានចាប់ផ្តើមធ្វើការកែទម្រង់លើគោលនយោបាយរបស់យើងជាបន្តបន្ទាប់ ដោយផ្តោតលើអាទិភាពបន្ទាន់ទាំងឡាយ ស្របតាមបរិការណ៍ និងកាល:ទេស: នៃសម័យកាលនីមួយៗ ចាប់តាំងពីក្រោយការ-ដួលរលំនៃរបបប្រល័យពូជសាសន៍មកម្ល៉េះ។ យ៉ាងណាមិញ, សុខសន្តិភាព, ស្ថិរភាពនយោបាយ និង ឯកភាពជាតិពេញផ្ទៃប្រទេស ដែលយើងសម្រេចបានមកដោយលំបាកបំផុត បានផ្តល់ឱកាសឱ្យយើងអាចកែលម្អ និងស្ថាបនាបន្ថែមទៀត លើប្រព័ន្ធអភិបាលកិច្ចរបស់យើង តាមរយៈការរៀបចំការងារកែទម្រង់ជាប្រព័ន្ធ និងក្នុងលក្ខណៈជាកម្មវិធីរយៈពេលវែង ដែលមានការកំណត់ចក្ខុវិស័យវែងឆ្ងាយ មានការបែងចែកជាដំណាក់កាលប្រកបដោយភាពជាក់ស្តែងនិយម ជាមួយនឹងគោលដៅជាក់លាក់ ព្រមទាំងមានរចនាសម្ព័ន្ធដឹកនាំ និង មានយន្តការអនុវត្តច្បាស់លាស់។ យុទ្ធសាស្ត្រនេះ បានបង្ហាញអំពីសេចក្តីក្លាហាន, មហិច្ឆតា និង ឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា លើការកែទម្រង់ ដោយតម្រូវទៅតាមបរិបទកម្ពុជា និង ឆ្លើយតបបានតាមសេចក្តី-ត្រូវការរបស់កម្ពុជា ប្រកបដោយមោទនភាព, ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព។

ផ្អែកលើសារវតារ និង ទស្សនៈវិស័យនេះ, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាបន្តបន្ទាប់ នូវកម្មវិធីកែទម្រង់ក្នុងលក្ខណៈជាប្រព័ន្ធ ឬការកែទម្រង់រចនាសម្ព័ន្ធរយៈពេលវែងជាច្រើន លើវិស័យសំខាន់ៗ សំដៅលើកកម្ពស់គុណភាពនៃប្រព័ន្ធអភិបាលកិច្ច ដែលរួមមាន ៤ គឺ÷ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**, **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**, **កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ** និង **កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌**។ ជាមួយនឹងរចនាសម្ព័ន្ធ

ដឹកនាំ, យន្តការអនុវត្ត និងផែនការសកម្មភាពលម្អិតច្បាស់លាស់, កម្មវិធីកែទម្រង់នីមួយៗ ទទួលបាននូវការសាទរ និង ការគាំទ្រយ៉ាងសកម្ម ពីសំណាក់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា រួមបញ្ចូលនូវការផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ជាបន្តបន្ទាប់, ក្នុងភាពជាដៃគូ, កិច្ចសហប្រតិបត្តិការ និងការគោរពភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជា។

ឥឡូវនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានមកដល់ដំណាក់កាលទី៤ ដែលជាដំណាក់កាលចុងក្រោយរបស់ខ្លួន បន្ទាប់ពីត្រូវបានអនុវត្តអស់រយៈពេលជិត ២០ ឆ្នាំ។ ខ្ញុំចាំបានថា ខ្ញុំផ្ទាល់បានធ្វើជាអធិបតី ក្នុងពិធីប្រកាសដាក់ចេញនូវដំណាក់កាលទី១ នៃកម្មវិធីកែទម្រង់នេះ នៅក្នុងអំឡុងខែធ្នូ ឆ្នាំ២០០៤។

ជាមួយនឹងឆន្ទៈមុតស្រួចឥតរាថយ និងឥតងាករេ, រាជរដ្ឋាភិបាលកម្ពុជា បានជំរុញអនុវត្តកម្មវិធីកែទម្រង់ដ៏មានសារៈសំខាន់បំផុតមួយនេះ ឆ្លងកាត់ដំណាក់កាលធំៗ ចំនួន ៣ រួមមាន÷

- **ដំណាក់កាលទី១** ត្រូវបានអនុវត្ត ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ ដែលមានគោលដៅគន្លឹះសំដៅលើ "**ការកសាងតាពជឿទុកចិត្តនៃថវិកា**"
- **ដំណាក់កាលទី២** ត្រូវបានអនុវត្ត ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដែលមានគោលដៅគន្លឹះសំដៅលើ "**ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ**"
- **ដំណាក់កាលទី៣** ត្រូវបានអនុវត្ត ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ ដែលមានគោលដៅគន្លឹះសំដៅលើ "**ការផ្សារភ្ជាប់ថវិកានៅនឹងគោលនយោបាយ**"

ដំណាក់កាលទី៤ ដែលយើងកំពុងប្រកាសដាក់ឱ្យចាប់ផ្តើមអនុវត្តនាពេលនេះ ត្រូវបានគ្រោងចាប់អនុវត្តពីឆ្នាំ២០២៣ នេះ រហូតដល់ឆ្នាំ២០២៧ ដែលមានគោលដៅគន្លឹះ ត្រូវអនុវត្តពីឆ្នាំ២០២៣នេះ រហូតដល់ឆ្នាំ២០២៧ មានគោលដៅគន្លឹះគឺ "**ការកសាងគណនេយ្យភាពសមិទ្ធកម្ម**"។

ជារួម, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេលប្រមាណ ២០ ឆ្នាំកន្លងទៅនេះ បានបង្កើតសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើននៅកម្ពុជា, ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទាំងសមិទ្ធផលក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គម-សេដ្ឋកិច្ច របស់កម្ពុជា។ ជាការពិត, ការរីកចម្រើនផ្នែកសេដ្ឋកិច្ច និង សង្គម មានទំនាក់ទំនងយ៉ាងស្និតល្អតជាមួយនឹងសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ថវិកាជាតិ។ នៅឆ្នាំ២០០៣, មុនការចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់នេះ, ចំណូលថវិកាជាតិសរុប មានប្រមាណតែ ១ ៨២១ ប៊ីលាន រៀលប៉ុណ្ណោះ; រីឯចំណាយថវិកាជាតិ មានប្រមាណ ២ ៩៩៤ ប៊ីលានរៀល។ រយៈពេល២០ឆ្នាំក្រោយ, ចំណូលថវិកាជាតិ ក្នុងឆ្នាំ២០២៣

ត្រូវបានប៉ាន់ស្មានថា នឹងមានរហូតដល់ ៣២ ៩៣៦ ប៊ីលានរៀលឯណោះ, រីឯចំណាយថវិកាជាតិសរុប មានប្រមាណ ៤១ ៥៣៧ ប៊ីលានរៀល។ សូចនាករសមិទ្ធកម្មដ៏ល្អប្រសើរនេះ គឺជាឃ្លាស់សេដ្ឋកិច្ចដ៏សំខាន់ បំផុតមួយ ដែលធ្វើឱ្យកម្ពុជាទទួលបានកំណើន និង បន្តស្ថិរភាពនៃកំណើនសេដ្ឋកិច្ច ជាបន្តបន្ទាប់ រហូតដល់ សម្រេចបាននូវចំណាត់ថ្នាក់ជា **ប្រទេសមានចំណូលមធ្យមកម្រិតទាប** នៅឆ្នាំ២០១៥ និង កំពុងបោះជំហាន ប្រកបដោយភាពជឿជាក់ ទៅកាន់ឋានៈជា **ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់** នៅឆ្នាំ២០៣០ និង ជា **ប្រទេសមានចំណូលកម្រិតខ្ពស់** នៅឆ្នាំ២០៥០។

សមិទ្ធកម្មដ៏ប្រសើរនេះ ក៏បានផ្តល់លទ្ធភាពកាន់តែខ្ពស់ ជូនរាជរដ្ឋាភិបាលក្នុងការលើកកម្ពស់កម្រិត ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាលើកកម្ពស់ជីវភាព និង គុណភាពរបស់មន្ត្រីរាជការ, ពង្រឹង ប្រសិទ្ធភាពស្ថាប័នសាធារណៈ, និង បម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ បានកាន់តែល្អឡើង តាមរយៈ អាទិភាពចំនួន ៤ នៅក្នុងយុទ្ធសាស្ត្រចតុកោណ គឺ÷ **មនុស្ស, ផ្លូវ, ទឹក និង ភ្លើង** ដែលសំដៅដល់ការ កសាង និង ការអភិវឌ្ឍឥតឈប់ឈរ នូវហេដ្ឋារចនាសម្ព័ន្ធ, ទាំងរូបវន្ត និង មិនមែនរូបវន្ត, លើគ្រប់វិស័យ។ រឹតតែសំខាន់ជាងនេះ, សមិទ្ធផលទាំងអស់នេះ គឺជាកត្តារួមចំណែកដ៏ធំធេង ក្នុងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា ដែលមានការធ្លាក់ចុះជាលំដាប់។

លើសពីនេះ, សុខភាពដ៏ល្អប្រសើរនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ក៏បានធ្វើឱ្យរាជរដ្ឋាភិបាលមានថវិកាសន្សំគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាជាយថាហេតុទាំងឡាយ នាគ្រាកន្លងទៅ ជាអាទិ៍÷ ការឆ្លើយតបនឹងស្ថានភាពមិនអំណោយផល បង្កឡើងដោយវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសកលលោក ក៏ដូចជា ការឆ្លើយតបនឹងគ្រោះមហន្តរាយ និង គ្រោះធម្មជាតិផ្សេងៗ ដែលមិនអាចស្មានទុកជាមុនបាន។ ជាក់ស្តែង, រាជរដ្ឋាភិបាលកម្ពុជា មានលទ្ធភាពគ្រប់គ្រាន់ខាងផ្នែកហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ខ្ពស់ នូវវិបត្តិសុខុមាលភាព, សង្គម និង សេដ្ឋកិច្ច ដែលបណ្តាលមកពីការីករាលដាលជាសកលនៃជំងឺ កូវីដ-១៩ រហូតកម្ពុជាត្រូវបានទទួលស្គាល់នៅក្នុងកម្រិតសកលលោកថា ជាប្រទេសគ្រប់គ្រងជំងឺកូវីដ-១៩ បានយ៉ាងល្អ និង ជាប្រទេសស្ទុះងើបឡើងវិញពីវិបត្តិនៃជំងឺ កូវីដ-១៩ បានយ៉ាងរហ័ស។

រឹតតែសំខាន់ថែមទៀត, ក្នុងបុព្វហេតុឯករាជ្យ និង អធិបតេយ្យជាតិ, សមិទ្ធកម្មដ៏ល្អនៃកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានពង្រឹងឱ្យកាន់តែមាំមួនឡើង នូវភាពជាម្ចាស់ និង តួនាទី របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទទួលខុសត្រូវលើជោគវាសនារបស់ប្រទេសជាតិ ដោយបានកាត់បន្ថយ ការពឹងពាក់លើការខ្ចីពីក្រៅប្រទេស ដែលបច្ចុប្បន្ន ការខ្ចីពីក្រៅប្រទេសប្រចាំឆ្នាំ មានទំហំមិនស្មើនឹង ២០ ភាគរយនៃថវិកាជាតិសរុបនោះទេ។ ផ្ទុយទៅវិញ, នៅក្នុងអតីតកាល ៣០ ឆ្នាំមុន, ចំណូលក្នុងស្រុកដែល

យើងរកបានដោយខ្លួនឯង មានត្រឹមប្រមាណមួយភាគបីនៃថវិកាជាតិសរុប តែប៉ុណ្ណោះ, បានន័យថា តម្រូវ-ការប្រមាណពីរភាគបីនៃថវិកាជាតិ ត្រូវបានដោះស្រាយដោយប្រភពធនធានជាជំនួយហិរញ្ញវត្ថុពីក្រៅប្រទេស។ នេះ គឺជាលទ្ធផលជាក់ស្តែងដែលយើងសម្រេចបាន ស្របតាមគោលជំហរដឹកនាំ ដែលខ្ញុំបានប្រកាសជាសាធារណៈ នាពេលកន្លងទៅ គឺ÷ “**កែទម្រង់-រស់, មិនកែទម្រង់-ស្លាប់**”។ ទស្សនៈដឹកនាំនេះ, រួមជាមួយនឹងសមិទ្ធផលជាក់ស្តែងនៃកិច្ចការកែទម្រង់, បានធ្វើឱ្យក្តីរំពឹងទុកលើការកសាងប្រជាជាតិរបស់យើង ដែលត្រូវបានចារឹកទុកក្នុងបុព្វកថានៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្លាយទៅជាការពិត នោះគឺ÷ “**ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើងវឹកចម្រើនល្អតលាស់ សម្បូរបែប ជានិច្ចនិរន្តរ៍**” និង ប្រែក្លាយកម្ពុជា ឱ្យទៅជា “**កោះសន្តិភាព**” យ៉ាងពិតប្រាកដ។

សន្តិភាព និង វិបុលភាពសង្គម, ដែលកំពុងតែផ្តល់មនុញ្ញផលដល់យើងទាំងអស់គ្នានាបច្ចុប្បន្ននេះ, បានធ្វើឱ្យយើងមានមោទនភាពជាតិយ៉ាងក្រៃលែង និង មានការជឿជាក់កាន់តែរឹងមាំថា “**ខ្មែរពិតជាអាចធ្វើបាន**”។ ប៉ុន្តែ, ច្បាស់ណាស់ថា, យើងក៏មិនត្រូវស្កប់ស្កល់ ឬ លង់លក់នៅក្នុងជោគជ័យបច្ចុប្បន្នដែរ។ ផ្ទុយទៅវិញ, យើងត្រូវប្រឹងប្រែងរៀនសូត្រ និង ដកស្រង់ពិសោធន៍ ពីការអនុវត្ត និង បណ្តាបញ្ហាប្រឈមនាពេលកន្លងទៅ ដើម្បីបោះជំហានទៅដំណាក់កាលថ្មីជាបន្តទៀត ជាមួយនឹងមហិច្ឆតាបែបប្រាកដនិយម និង មិនបង្អង់រង់ចាំ។ ប្រការនេះ មានន័យថា យើងត្រូវវាយតម្លៃឱ្យចំសកម្មភាពជាអាទិភាពដែលយើងត្រូវធ្វើជាបន្ទាន់ និង អាចធ្វើទៅបាន ដើម្បីឆ្លើយតបឱ្យចំសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និង ឱ្យសម្រេចបានលទ្ធផលកាន់តែប្រសើរ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់តាមការរំពឹងទុក ស្របពេលដែលយើងត្រូវមានការប្រុងប្រយ័ត្នខ្ពស់ លើកត្តាបរិបទ និង កត្តាបរិស្ថានគ្របដណ្តប់ជារួមផងដែរ ដើម្បីធានានូវការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ឱ្យបានក្នុងក្រមិតជាអតិបរមា។

នៅក្នុងគោលដៅនៃ “**ការកសាងគណនេយ្យភាពសមិទ្ធកម្ម**” នេះ ដែលសំដៅទៅដល់ការទទួលខុសត្រូវផ្អែកលើលទ្ធផល, ការកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា បានឈានចូលមកដល់ដំណាក់កាលយុទ្ធសាស្ត្រកម្រិតខ្ពស់ ដែលជាគោលដៅដ៏ចម្បងរបស់យើង នោះគឺ ការប្រែប្រួលជាសារវន្តផ្នែកគោល-នយោបាយ និង យុទ្ធសាស្ត្រអាទិភាព ដែលសំដៅដល់ការពង្រឹងប្រសិទ្ធភាព, គុណភាព និង ការទទួលខុសត្រូវលើលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នសាធារណៈ និង មន្ត្រីរាជការ ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ក្នុងន័យនេះ, សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ជាមួយនឹងការទទួលបានន្ូវការ-ផ្ទេរសិទ្ធិអំណាចក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួន, ក្រសួង ស្ថាប័ន នីមួយៗ នឹងត្រូវមានការទទួល-ខុសត្រូវខ្ពស់ លើការប្រើប្រាស់ថវិកាឱ្យបានប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធភាព ព្រមទាំងចំគោលដៅ

កំណត់, ពោលគឺ, ម្ខាង, ត្រូវទទួលខុសត្រូវលើការសម្រេចឱ្យបាន នូវគោលបំណងគោលនយោបាយ, បេសកកម្ម និង សូចនាករលទ្ធផលរំពឹងទុករបស់ខ្លួន អនុលោមតាមគោលការណ៍នៃ "**ការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយ**"; និងម្ខាងទៀត, ត្រូវទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់លើការប្រើប្រាស់ថវិកាដែលត្រូវបានអនុម័តផ្តល់ជូន ឱ្យបានប្រកបដោយប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព ព្រមទាំងធានាបាននូវ "តម្លៃនៃលុយ" ស្របតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាធរមាន។

ក្នុងស្មារតីបន្តជំរុញអនុវត្តដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់នេះ ឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក, ខ្ញុំសូមផ្តល់អនុសាសន៍គន្លឹះមួយចំនួន សម្រាប់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃគ្រប់ក្រសួង ស្ថាប័ន ដែលជាតួអង្គនិម្មាបនករ និង ប្រតិបត្តិករ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម ÷

ទី១. ត្រូវបង្កើនភាពជាម្ចាស់ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន ដោយរដ្ឋមន្ត្រី និង ប្រធានស្ថាប័ន ត្រូវជំរុញអនុវត្តប្រកបដោយភាពជាម្ចាស់ នូវកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅតាមគោលការណ៍រួមរបស់រាជរដ្ឋាភិបាល។ ការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការសម្រេចបាន នូវគោលបំណង និង បេសកកម្មរបស់ក្រសួង ស្ថាប័ន ដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។ អាស្រ័យនេះ, គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវចាត់ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាការងារដែលត្រូវតាមដានការអនុវត្តជាប្រចាំ។ ការកែទម្រង់ ត្រូវផ្តើមចេញជាសំខាន់ពីការពង្រឹងភាពជាអ្នកដឹកនាំ និង ការពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រង ដោយផ្តោតទៅលើការសម្រេចនូវលទ្ធផល ស្របគ្នានឹងការពង្រឹងសមត្ថភាពធនធាន មន្ត្រីរាជការនៅក្រោមឱវាទ។

ទី២. ត្រូវផ្តល់ការយកចិត្តទុកដាក់ខ្ពស់ ដល់ការត្រៀមរៀបចំគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យបាននូវ "ការអនុវត្តជាមូលដ្ឋាន" នូវថវិកាព័ត៌មានសមិទ្ធកម្ម យ៉ាងយូរនៅឆ្នាំ២០២៦ ខាងមុខ ស្របតាមគោលដៅកំណត់នៃ "**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា**" របស់រាជរដ្ឋាភិបាល។ ច្បាស់ណាស់ថា ការកែទម្រង់ប្រព័ន្ធថវិកាជាតិ គឺជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយសារ ថវិកា គឺជាឧបករណ៍គន្លឹះសម្រាប់រដ្ឋាភិបាលនៃប្រទេសនីមួយៗ ប្រើប្រាស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍប្រទេសជាតិ តាមរយៈការប្រមែប្រមូលធនធានរបស់ជាតិ ប្រកបដោយចីរភាព និង ការវិភាជធនធានទាំងនោះ បម្រើឱ្យការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។

ទី៣. ត្រូវបន្តពង្រឹងយន្តការសម្របសម្រួល, សង្គតិភាព និង ភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់សំខាន់ៗទាំងឡាយរបស់រាជរដ្ឋាភិបាល, ពិសេស គឺកម្មវិធីកែទម្រង់ ៣ ឃុក ១ ស្របតាមឯកសារ "**ចតុវិស័យ និង យុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្មការកែទម្រង់ ៣ ឃុក ១ នៃរាជរដ្ឋាភិបាល**" ដែលខ្ញុំបានសម្រេចដាក់ឱ្យអនុវត្ត នាពេលថ្មីៗកន្លងទៅ។

ទី៤. ត្រូវបន្តជំរុញឱ្យបានរីកចម្រើននូវវិស័យឌីជីថល ស្របតាមក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដោយបន្សុំ និង ប្រទាក់ក្រឡាគ្នា ជាមួយនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៍ដូចជាជាមួយកម្មវិធីកែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

ទី៥. ត្រូវបន្តប្រកាន់ខ្ជាប់នូវ អភិក្រមការងារ "ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់" ដែលជាអភិក្រមកែទម្រង់របស់មន្ត្រីរាជការ និង ថ្នាក់ដឹកនាំនៅតាមក្រសួង ស្ថាប័ន ក្នុងគ្រប់កម្រិត, ទាំងកម្រិតបច្ចេកទេស, កម្រិតគ្រប់គ្រង និង កម្រិតដឹកនាំ, ក្នុងស្មារតីភ្ញាក់រលឹក, កែលម្អ និង បង្កើនប្រសិទ្ធភាពការងារ, ទាំងក្នុងក្របខ័ណ្ឌនៃការបំពេញការងារជាបុគ្គល ក៍ដូចជាការបំពេញការងារជាក្រុម។

ទី៦. ត្រូវផ្តល់សារៈសំខាន់លើការពង្រឹង "ភាពជាអ្នកដឹកនាំ" នៅគ្រប់កម្រិត និង ជាពិសេស **"ក្នុងកម្រិតថ្នាក់ដឹកនាំ"** នៅក្នុងស្ថាប័ន និង អង្គភាព ពីព្រោះនេះ គឺជាកត្តាចម្បងដែលកំណត់នូវភាពជោគជ័យនៃការងារ នៅក្នុងគ្រប់អង្គភាព និង ក្រសួង ស្ថាប័ន, ទាំងសាធារណៈ និង ឯកជន។

ទី៧. ត្រូវប្រកាន់យកគោលការណ៍ "គុណភាព, សមត្ថភាព និង គុណាធិបតេយ្យ" ជាវប្បធម៌ការងារ, ពិសេស នៅក្នុងការគ្រប់គ្រងធនធានមនុស្ស។ ប្រការនេះ សំដៅដល់ភាពចាំបាច់ក្នុងការផ្តល់នូវឱកាស និង ការលើកទឹកចិត្ត, ទាំងផ្នែកហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុ, ប្រកបដោយសមធម៌ និង យុត្តិធម៌, ជូនដល់ មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ដោយផ្អែកលើគុណ-សម្បត្តិ ស្របតាមគុណវុឌ្ឍិ, បទពិសោធន៍, សមត្ថភាព, ឆន្ទៈ និង វិន័យ ក្នុងការបំពេញការងារ។ គោលការណ៍នេះ ត្រូវអនុវត្តមិនត្រឹមតែក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវតែក្លាយទៅជាគោលការណ៍អាទិភាពមួយរបស់រាជរដ្ឋាភិបាល សម្រាប់ពង្រឹងអភិបាលកិច្ច និង សមត្ថភាពស្ថាប័ន នៅគ្រប់កម្រិត។

ទី៨. ត្រូវពង្រឹងយន្តការ "តាមដាន, ត្រួតពិនិត្យ និង វាយតម្លៃ" នៅគ្រប់កម្រិត និង ឱ្យបានទូលំទូលាយ, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ សម្រាប់ជាឧបករណ៍ ដើម្បីកំណត់

ចំណុចខ្លាំង, ចំណុចខ្សោយ, បញ្ហាប្រឈម និង កាលានុវត្តភាព នៃរាល់ការអនុវត្តផែនការសកម្មភាពការងារ។ ម្យ៉ាងទៀត, យន្តការនេះក៏ជាមធ្យោបាយដ៏សំខាន់មួយ សម្រាប់ចូលរួមពង្រឹង "**គណនេយ្យភាពសមិទ្ធកម្ម**" ផងដែរ។

ខ្ញុំពិតជាមានមោទនភាពខ្ពស់ ចំពោះការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅ ដែលតាមរយៈនេះ យើងអាចកសាងមូលដ្ឋានគ្រឹះ តាមដំណាក់កាលនីមួយៗ និង អាចឈានមកដល់ដំណាក់កាលចុងក្រោយនេះបាន ដោយជោគជ័យយ៉ាងប្រចក្ស។

ជាការពិត,លទ្ធផល, សមិទ្ធផល និង វឌ្ឍនភាព ដែលសម្រេចបានមកដល់ពេលនេះ ពិតជាមិនអាចកាត់ផ្តាច់បានឡើយ ពីការចូលរួមចំណែករបស់គ្រប់ស្ថាប័នទាំងអស់ក្នុងជួររាជរដ្ឋាភិបាល, ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី។ ក្នុងនាមរាជរដ្ឋាភិបាល, ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការវាយតម្លៃខ្ពស់ជូនដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីឆ្នាំ២០០៤ មក, ជាពិសេស ថ្នាក់ដឹកនាំ និង មន្ត្រីទាំងឡាយ ដែលជាប់ពាក់ព័ន្ធតាំងពីដំបូង រហូតមកដល់បច្ចុប្បន្ន។

ជាមួយគ្នានេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** និង **ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដែលបានដឹកនាំផ្ទាល់ និង ជាប់លាប់ តាំងពីដើមទី លើការងារនេះ ប្រកបដោយភាពជាអ្នកដឹកនាំ និង វិជ្ជាជីវៈខ្ពស់។ ខ្ញុំក៏សូមកោតសរសើរដោយស្មោះ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការទាំងអស់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏ដូចជាគ្រប់ក្រសួង ស្ថាប័ន ដែលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់នេះ ប្រកបដោយភាពអត់ធ្មត់ និង ភាពជាម្ចាស់។ បន្ថែមលើនេះ, ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាដៃគូអភិវឌ្ឍន៍ទាំងឡាយ ដែលតែងតែបានគាំទ្រ, ទាំងជាជំនួយបច្ចេកទេស និង ទាំងជាជំនួយហិរញ្ញវត្ថុ, ជាបន្តបន្ទាប់, តាំងពីដំណាក់កាលទី១ រហូតមកដល់ដំណាក់កាលទី៤ ដែលជាដំណាក់កាលចុងក្រោយនេះ។

ជាទីបញ្ចប់, ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមផ្តាំផ្ញើ និង ជំរុញ, ជាថ្មីម្តងទៀត, ឱ្យគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ បន្តសកម្មចូលរួមអនុវត្ត តាមបេសកកម្ម, មុខងារ, កម្មវិធីការងារ និង គណនេយ្យភាពរបស់ខ្លួន ប្រកបដោយភាពជាម្ចាស់ និង ឆន្ទៈកែទម្រង់មោះមុត នៅក្នុងកម្មវិធីកែទម្រង់នេះ ដូចត្រូវបានកំណត់នៅក្នុងឯកសារ "**ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤**"។ ខ្ញុំសង្ឃឹមថា ដំណាក់កាលទី៤ នឹងត្រូវបានអនុវត្តប្រកបដោយជោគជ័យ ជាមួយនឹង

ការដកស្រង់នូវមេរៀន និង ពិសោធន៍ល្អៗ ព្រមទាំងការតាមដាន, ការត្រួតពិនិត្យ និង ការវាយតម្លៃ ជាបន្ត បន្ទាប់ ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម និង ជម្នះនូវឧបសគ្គផងទាំងពួង ប្រកបដោយស្មារតីសាមគ្គី, កិច្ចសហការ និង ការសម្របសម្រួលខ្ពស់ ក្នុងគោលបំណងសម្រេចឱ្យបាននូវចក្ខុវិស័យ **កសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឱ្យឆ្លើយតបទៅតាមស្តង់ដា និង ខ្នតមានទុវត្ថន៍អន្តរជាតិ**។

ថ្ងៃសៅរ៍ ១៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អារម្ភកថា

ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ ÷ **ប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធផ្តោតលើធាតុចូល និង មានលក្ខណៈមជ្ឈការ ទៅជាប្រព័ន្ធ ដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង មានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ**។ ដើម្បីសម្រេចចក្ខុវិស័យនេះ, យើងបានកំណត់យក យុទ្ធសាស្ត្របោះជំហានតាមដំណាក់កាល ឬ អភិក្រមជាខឿនតាមរយៈក្របខ័ណ្ឌផែនការសកម្មភាពរួមដ៏លម្អិតមួយ ដែលផ្សំឡើងពី÷ (១). បណ្តាសកម្មភាពចាំបាច់សម្រាប់ការកសាងមូលដ្ឋានគ្រឹះនៅតាមដំណាក់កាលនីមួយៗ; និង (២). សកម្មភាពចាំបាច់នានា ដែលត្រូវចាប់ផ្តើមសាកល្បងដកពិសោធន៍ជាបណ្តើរៗ មុនឈានចូលទៅដល់ដំណាក់កាលបន្ទាប់។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី១ បានចាប់ផ្តើមឡើង នៅចុងឆ្នាំ ២០០៤ ដោយផ្តោតលើ "**ការកសាងភាពជឿជុំកចិត្តបាននៃថវិការ**" ហើយដែលត្រូវបានអនុវត្តរហូតដល់ឆ្នាំ ២០០៨ ដោយសម្រេចបាននូវសមិទ្ធផលគន្លឹះជាមូលដ្ឋាន សម្រាប់ការបោះជំហានឡើងមកកាន់ដំណាក់កាលបន្ទាប់ នោះគឺ÷ ការដោះស្រាយបានដោយជោគជ័យ នូវបញ្ហាបំណុលសាច់ប្រាក់ដ៏រ៉ាំរ៉ៃ; ការអនុវត្តពេញលេញនូវប្រព័ន្ធគណនីទោលរតនាគារជាតិ; ការធ្វើទំនើបកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ; ការកែទម្រង់កិច្ចលទ្ធកម្មសាធារណៈ; ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ជាដើម។ ទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ និង ជាបុរេលក្ខខណ្ឌ មិនអាចខ្វះបាន សម្រាប់ការចាប់ផ្តើមដំណាក់កាលទី២, ដោយផ្តោតលើ "**ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ**", ដែលត្រូវបានអនុវត្ត ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥។ ដំណាក់កាលទី២ នេះត្រូវបានអនុវត្តតាមរយៈក្របខ័ណ្ឌផែនការសកម្មភាព រយៈពេល ៥ ឆ្នាំ, និងបន្ទាប់ពីបានឆ្លងការវាយតម្លៃ, ត្រូវបានបន្ថែមសកម្មភាពសម្រាប់អនុវត្ត រយៈពេលប្រមាណ ២ ឆ្នាំបន្តទៀត ដោយសម្រេចបាននូវសមិទ្ធផលជាសារវន្តមួយចំនួន ជាអាទិ៍÷ ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ; ការពង្រីកអង្គភាពសវនកម្មផ្ទៃក្នុង; ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS); និង ការចាប់ផ្តើមសាកល្បងអនុវត្តប្រព័ន្ធថវិកាកម្មវិធី នៅតាមក្រសួងមួយចំនួន។

បន្ទាប់ពីបានវាយតម្លៃយ៉ាងម៉ត់ចត់លើវឌ្ឍនភាព រយៈពេល ៧ ឆ្នាំ នៃដំណាក់កាលទី២ រួចមក, រាជរដ្ឋាភិបាលបានសម្រេចចាប់ផ្តើមអនុវត្តដំណាក់កាលទី៣ ដែលជាដំណាក់កាលយុទ្ធសាស្ត្រដ៏សំខាន់មួយទៀត ដោយផ្តោតលើ "**ការជួរក្សាច់ថវិការនៃនិរន្តរយោបាយ**"។ ដំណាក់កាលទី៣ នេះ ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០១៦ មក។ យ៉ាងណាមិញ, ដោយសារកត្តាសត្យានុម័តជាច្រើន, ជាពិសេស បញ្ហា

វិបត្តិជំងឺកូវីដ-១៩, គោលដៅគន្លឹះមួយចំនួននៃដំណាក់កាលទី៣ មិនអាចសម្រេចបានតាមកាលកំណត់ឡើយ ដែលជាហេតុតម្រូវឱ្យមានការពន្យារពេល តាមរយៈការដាក់ចេញនូវក្របខ័ណ្ឌផែនការសកម្មភាពដំណាក់កាលទី៣ នេះ ចំនួន ២ ឆ្នាំបន្ថែមទៀត, គឺ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២, មុននឹងយើងអាចចាប់ផ្តើមអនុវត្តដំណាក់កាលទី៤ ដែលផ្តោត លើ "**គណនេយ្យភាពសមិទ្ធកម្ម**" នៅក្នុងឆ្នាំ២០២៣ នេះ។

បន្ថែមលើការពង្រឹងគណៈនេយ្យភាពហិរញ្ញវត្ថុ តាមរយៈការពង្រីក និង ការពង្រឹងការអនុវត្តថវិកាកម្មវិធី ក៏ដូចជាការកែលម្អ និង ការពង្រឹងប្រព័ន្ធគណនេយ្យសាធារណៈ និង ប្រព័ន្ធសវនកម្ម និង អធិការកិច្ចហិរញ្ញវត្ថុ, ពិសេស ការចាប់ផ្តើមដាក់ឱ្យអនុវត្តជាជំហានៗ នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), លទ្ធផលជាក់ស្តែងជាសារវន្តនៃការអនុវត្តដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ ក៏រួមបញ្ចូលផងដែរ នូវយុទ្ធសាស្ត្រកែទម្រង់សំខាន់ៗ និង ច្បាប់គន្លឹះមួយចំនួន សម្រាប់ជាមូលដ្ឋានគ្រឹះនៃ "**ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម**" ជាអាទិ៍÷ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា; យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ; យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម; យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ; យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ; និង យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគណនេយ្យ។ ថ្មីៗនេះ, **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)** ក៏ត្រូវបានអនុម័ត និង ប្រកាសដាក់ឱ្យប្រើប្រាស់ ជំនួស **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨** ដែលច្បាប់ថ្មីនេះ បានកំណត់ឱ្យរាជរដ្ឋាភិបាលរៀបចំដាក់ឱ្យ "**អនុវត្តជាមូលដ្ឋាន**" នូវ "**ថវិកាព័ត៌មានសមិទ្ធកម្ម**" ឱ្យបាន នៅឆ្នាំ២០២៦។ បន្ថែមលើនេះ, **សេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ** សម្រាប់ជំនួស **ច្បាប់ស្តីពីលទ្ធកម្មសាធារណៈឆ្នាំ២០១២** និង **សេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធ** សម្រាប់ជំនួស**ច្បាប់ស្តីពីសារពើពន្ធជាធរមានបច្ចុប្បន្ន** ក៏ត្រូវបានរៀបចំរួចស្រេចបាច់ផងដែរ ដែលរំពឹងថា នឹងអាចឆ្លងការពិនិត្យ សម្រេចដោយអង្គគណៈរដ្ឋមន្ត្រី ព្រមទាំងការពិនិត្យ និង ការអនុម័ត ដោយស្ថាប័ននីតិបញ្ញត្តិ តាមនីតិវិធីច្បាប់ជាធរមាន ក្នុងពេលដ៏ឆាប់ខាងមុខ។

សមិទ្ធផលក្នុងរយៈពេលជិត ២០ ឆ្នាំនេះ បានបង្ហាញជាក់ច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជា, ដែលមានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាសេនាធិការ, បាន និង កំពុងធ្វើដំណើរនៅលើមាគ៌ាដ៏ត្រឹមត្រូវ ឆ្ពោះទៅកាន់ការសម្រេចបាន នូវចក្ខុវិស័យដែលបានកំណត់។ ជោគជ័យនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានផ្តល់ផលជាបណ្តើរៗ លើការពង្រឹងគុណភាព "**អភិបាលកិច្ចល្អ**" និង ការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរឹងមាំមួយ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចលើកកម្ពស់ជីវភាព និង បម្រើសេវាសាធារណៈ ជូនប្រជាជនបានកាន់តែប្រសើរឡើង តាមរយៈការ-

អភិវឌ្ឍធនធានមនុស្ស ឱ្យកាន់តែមានគុណភាព; ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានា ដូចជា ប្រព័ន្ធគមនាគមន៍, ប្រព័ន្ធធារាសាស្ត្រ និង ប្រព័ន្ធអគ្គិសនី; ការកសាងសាលារៀន និង មន្ទីរពេទ្យ បាន កាន់តែច្រើន និង មានគុណភាពកាន់តែប្រសើរឡើងឥតឈប់ឈរ។ល។

សមិទ្ធផលជាប្រវត្តិសាស្ត្រនៃការកែទម្រង់ និង ការអភិវឌ្ឍ, ដែលយើងទាំងអស់គ្នាកំពុងតែក្រេប ជញ្ជក់ជាមនុញ្ញផលនេះ, អាចសម្រេចបានមក ដោយសារកិច្ចប្រឹងប្រែងរួមជាធ្លុងមួយ ជាមួយនឹងឆន្ទៈមុត ស្រួចឥតរាថយ នៃថ្នាក់ដឹកនាំ និង មន្ត្រីរាជការពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ នៃគ្រប់ក្រសួង ស្ថាប័ន នៅក្រោម ម្លប់ដ៏ត្រជាក់នៃ “**សន្តិភាព**” ដែល **អគ្គមហារដ្ឋបុរសដ៏ឆ្នើមឆ្លាតវាងវៃ** នៃយើង គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននាំមកជូនប្រទេសជាតិ និង ប្រជាជនកម្ពុជា តាមរយៈការតស៊ូលះបង់ដ៏ធំធេងបំផុត ពោលគឺ ដោយប្រថុយជីវិតផ្ទាល់ខ្លួន ដើម្បីបុព្វហេតុដ៏ឧត្តុង្គឧត្តមមិន អាចកាត់ថ្លៃបាននេះ។ សមិទ្ធផល និង បទពិសោធន៍ ក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅ បានផ្តល់មេរៀនដ៏មាន តម្លៃ ជាច្រើនអនេក និង បានធ្វើឱ្យយើងរឹតតែជឿជាក់លើភាពត្រឹមត្រូវនៃទស្សនៈវិស័យរបស់យើង នោះគឺ យើងត្រូវកែទម្រង់តាមសេចក្តីត្រូវការរបស់កម្ពុជា, ក្នុងបរិបទសង្គម-សេដ្ឋកិច្ច ស្ថាប័ន និង រដ្ឋបាល របស់ កម្ពុជា, ក្នុងភាពជាម្ចាស់របស់កម្ពុជា, និង ជាពិសេស ក្នុងការទទួលខុសត្រូវរបស់កម្ពុជា ចំពោះជោគវាសនា អនាគតជាតិ ដោយខ្លួនឯង ស្របតាមបាវចនា ២ ÷ “**កែទម្រង់ខាងក្នុង, បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ**”; និង អភិក្រមទាំង ៥ ÷ “**ឆ្នុះកញ្ចក់, ឲ្យតឹក, ដុសក្តែល, ញ៉ាឋាល និង ឌុះកាត់**”; របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

កែទម្រង់-រស់, មិនកែទម្រង់-ស្លាប់! នេះ គឺជាឱវាទានុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលគណៈកម្មាធិការដឹកនាំកាងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តែងប្រកាន់ ខ្ជាប់ ជាប្រទីបនាំផ្លូវ នៅក្នុងគ្រប់សកម្មភាពរបស់ខ្លួន។ ឱវាទានុសាសន៍នេះ តែងក្រើនរំលឹក និង ដាស់ ស្មារតីយើងទាំងអស់គ្នាជាប់ជាប្រចាំថា យើងគ្មានជម្រើសអ្វីល្អជាង ក្រៅពីត្រូវកែទម្រង់នោះឡើយ, កែឱ្យ បានល្អ, កែឱ្យកាន់តែមានប្រសិទ្ធភាព និង កែឱ្យបានរីកចម្រើនរុងរឿងថែមទៀត! ប្រាកដណាស់ថា ការកែ-ទម្រង់ ជាការងារដ៏លំបាកស្មុគស្មាញ, ដោយម្តង, យើងត្រូវជួបប្រទះបញ្ហាប្រឈមច្រើន, ទាំងផ្នែកផ្នត់ គំនិត, ឆន្ទៈ, ភាពជាអ្នកដឹកនាំ, ការប៉ះពាល់ផលប្រយោជន៍, សមត្ថភាព, ធនធានមនុស្ស និង បញ្ហា បច្ចេកទេស; និង ម្តងទៀត, យើងត្រូវតែចាប់ផ្តើមធ្វើ ដោយមិនបង្អង់រង់ចាំទាល់តែមានសមត្ថភាព, ធនធាន និង មធ្យោបាយគ្រប់គ្រាន់នោះឡើយ ក្នុងស្មារតី “**ធ្វើបណ្តើរ, រៀនបណ្តើរ, និង កែលម្អបណ្តើរ**”។ ដូច្នេះ, ការកែទម្រង់ អាចប្រៀបប្រដូចបានទៅនឹងការដាំ និង ការថែរក្សាដើមឈើយ៉ាងដូច្នោះដែរ ដែលតម្រូវឱ្យ

មានភាពអត់ធ្មត់ និង ទ្រាំជម្ទះភាពនឿយហត់, ហើយជួនកាលរួមទាំងភាពជូរចត់ផងដែរ; ក៏ប៉ុន្តែ, ផ្លែផ្កា ដែលទទួលបានពីកិច្ចខិតខំប្រឹងប្រែងដ៏មោះមុត និង ការព្យាយាមឥតរាថយនោះ គឺ÷ ភាពរីករាយ, ក្តីសុខ ក្សេមក្សាន្ត និង ការរីកចម្រើនឈានឡើងជាបន្តបន្ទាប់ របស់សង្គមជាតិ ប្រកបដោយវិបុលភាព និង ចីរភាព។

ពេលនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានដល់ដំណាក់កាលទី៤÷ "**គណនេយ្យតាមសមិទ្ធកម្ម**" ដែលជាដំណាក់កាលចុងក្រោយរបស់ខ្លួន ដោយសម្រួចទិស និង តម្រង់គោលដៅ ឆ្ពោះទៅរក "**សមិទ្ធកម្ម ឬ លទ្ធផល**"។ ក្នុងន័យនេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការ-គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាត្រូវការ នូវការគាំទ្រ ក៏ដូចជាការចូលរួមកាន់តែសកម្មឡើងថែមទៀត ពីសំណាក់គ្រប់ដៃគូ និង តួអង្គពាក់ព័ន្ធទាំងអស់, ជាពិសេស ពីសំណាក់គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីសម្រេចឱ្យបានជោគជ័យនូវផែនការសកម្មភាពទាំងឡាយ នៅក្នុង **ដំណាក់កាលទី៤** នេះ ដែលខ្ញុំសូមអនុញ្ញាតគូសរំលេចនូវការងារជាអាទិភាពគន្លឹះមួយចំនួន ដូចខាងក្រោម÷

ទី១. ការរៀបចំជុំវិញអនុវត្តនូវ **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣** ដែលទើបត្រូវបានត្រូវបានអនុម័ត ដាក់ឱ្យប្រើជំនួស **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨**។

ទី២. ការរៀបចំជុំវិញអនុវត្តនូវ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម** និង **ក្របខ័ណ្ឌថវិការយៈពេលមធ្យម**។

ទី៣. ការពង្រឹង និង ការជុំវិញការអនុវត្តយុទ្ធសាស្ត្រកែទម្រង់សំខាន់ៗ ដែលត្រូវបានដាក់ចេញរួចហើយ ដើម្បីបន្តផ្តល់ការគាំទ្រ និង មូលដ្ឋានគ្រឹះរឹងមាំ ដល់ការអនុវត្តកម្មវិធីកែទម្រង់របស់យើងទៅមុខទៀត ដែលរួមមានជាអាទិ៍÷ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា; យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ; យុទ្ធសាស្ត្រកៀរគរចំណូល; យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ; យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និង យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធគណនេយ្យ។

ទី៤. ការផ្តោតអាទិភាពលើ "**សមិទ្ធកម្ម**" ជាមូលដ្ឋានគ្រឹះក្នុងការចរចា និង អនុម័តថវិកាកម្មវិធីប្រចាំឆ្នាំ។ និង

ទី៥. ការពង្រីកវិសាលភាព និងការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។

ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធម៌ និង កតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះឧបការគុណដ៏ខ្ពង់ខ្ពស់បំផុត នៅក្នុងការដឹកនាំ, ការចង្អុលបង្ហាញ និង ការគាំទ្រ ក្នុងគ្រប់កាលៈទេសៈ, ជាពិសេស នៅពេលមានបញ្ហាវិបត្តិសុគស្ទាញផ្សេងៗ ដូចជាវិបត្តិនៃជំងឺកូវីដ-១៩ ថ្មីៗនេះ ដែលទាមទារនូវការសម្រេចចិត្ត និង ការដឹកនាំបញ្ជា ប្រកបដោយគតិបណ្ឌិត, ភាពឈ្លាសវៃ, យុត្តិធម៌ និង គុណធម៌, ជាបច្ច័យនាំឱ្យសម្រេចបាននូវសមិទ្ធផលជាប្រវត្តិសាស្ត្រ នៅក្នុងការ-អនុវត្តកម្មវិធីកែទម្រង់ ក៏ដូចជាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំថ្ងៃ ក្នុងរយៈពេល ២ ទសវត្សរ៍កន្លងទៅ។

ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់, ជាពិសេស សមាសភាពនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ននានា ដែលបានចូលរួមអនុវត្តផែនការសកម្មភាពកែទម្រង់ យ៉ាងសស្រាក់សស្រាំ តាំងពីក្នុងដំណាក់កាលទី១ រហូតមកដល់ដំណាក់កាលទី៤ ដែលជាដំណាក់កាលចុងក្រោយនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរ ជូនបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានផ្តល់នូវកិច្ចសហការ និង ការឧបត្ថម្ភគាំទ្រ, ទាំងផ្នែកបច្ចេកទេស និង ផ្នែកហិរញ្ញវត្ថុ, សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគោរពខ្ជាប់ខ្ជួន នូវភាពជាម្ចាស់របស់កម្ពុជា។ ចុងក្រោយ, ខ្ញុំសូមវាយតម្លៃខ្ពស់ និង កោតសរសើរ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីបុគ្គលិកនៃ អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកន្លងមក បានបំពេញការងារជាសេនាធិការយ៉ាងល្អ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ជាមួយនឹងការខិទ្ធិសខ្ជួនចំពោះការងារកែទម្រង់។

ថ្ងៃសៅរ៍ ៦រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០២៣

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

មាតិកានុក្រម

បុព្វកថា i

អារម្ភកថា ix

មាតិកានុក្រម xiv

១. សេចក្តីផ្តើម ១

២. ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២

៣. យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២

៤. សមិទ្ធផល បញ្ហាប្រឈម និងការណែនាំដំណាក់កាលទី៤ ..... ៥

៥. ផែនការសកម្មភាពរួមនិងក្របខ័ណ្ឌលទ្ធផលដំណាក់កាលទី៤ ..... ៧

៥.១. ផ្នែកទី១ “ការបន្តពង្រឹងតាពេជ្រីទុកចិត្តនៃថវិកា” ៩

៥.២. ផ្នែកទី២ “ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ” ១១

៥.៣. ផ្នែកទី៣ “ការពង្រឹងប្រសិទ្ធភាពការផ្សារភ្ជាប់ថវិកានៅនឹងគោលនយោបាយ” ១៥

៥.៤. ផ្នែកទី៤ “ការកសាងគណនេយ្យភាពសមិទ្ធកម្ម” ១៨

៥.៥. ផ្នែកទី៥ “ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត” ២០

៦. យុទ្ធសាស្ត្រគ្រប់គ្រងសម្រាប់ដំណាក់កាលទី៤ ..... ២២

៦.១. យន្តការស្ថាប័ន ២២

៦.២. សមត្ថភាពស្ថាប័ន ២៧

៦.៣. ធនធានហិរញ្ញវត្ថុ ៣០

៦.៤. វិធានការដោះស្រាយបញ្ហាប្រឈម ៣២

៦.៥. វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ៣៣

៧. សេចក្តីសន្និដ្ឋាន ៣៥

បញ្ជីឯកសារយោង ៣៨

១. សេចក្តីផ្តើម

កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ កម្មវិធីនេះ ជាអាទិភាពគោលនយោបាយមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងប្រព័ន្ធអភិបាលកិច្ចជាតិ។ ក្នុងរយៈពេលជិត ២០ ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយគិតចាប់ពីចុងឆ្នាំ២០០៤ រហូតមកដល់ ឆ្នាំ២០២២, រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលជាច្រើន ក្នុងការកសាងប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំស្របតាមស្តង់ដាអន្តរជាតិ ដែលបានរួមចំណែកប្រែក្លាយកម្ពុជា ពីប្រទេសមានចំណូលកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងពីប្រទេសឆ្លាប់តែពឹងផ្អែកលើជំនួយបរទេសសម្រាប់ហិរញ្ញប្បទានការអភិវឌ្ឍ ទៅជាប្រទេសមានលទ្ធភាពអាចកៀរគរ គ្រប់គ្រង និងវិភាជធនធាន សម្រាប់បម្រើឱ្យគោលដៅអភិវឌ្ឍន៍របស់ខ្លួនប្រកបដោយប្រសិទ្ធភាព ចីរភាព ឯករាជ្យ និងអធិបតេយ្យ។ សមិទ្ធផលនេះ ឆ្លុះបញ្ចាំងពីឆន្ទៈនយោបាយមោះមុត ភាពជាម្ចាស់លើជោគវាសនាប្រទេស និងស្មារតីទទួលខុសត្រូវពីសំណាក់គ្រប់តួអង្គពាក់ព័ន្ធ។

នៅឆ្នាំ២០២៣ នេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានមកដល់ដំណាក់កាលទី៤ ដែលផ្តោតសំខាន់លើការកសាងប្រព័ន្ធគណនេយ្យភាពសមិទ្ធកម្ម។ ក្នុងនោះ, ការកែទម្រង់ប្រព័ន្ធថវិកា ឆ្ពោះទៅប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា ប្រព័ន្ធថវិកាសមិទ្ធកម្ម ត្រូវបានកំណត់ថាជាមូលដ្ឋានស្នូល ដើម្បីសម្រេចគោលដៅសមិទ្ធកម្មនេះ។ ការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនឹងផ្តោតលើសមាសធាតុសំខាន់ៗនៃប្រព័ន្ធថវិកា ដូចជាការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ការរៀបចំថវិកា, ការអនុវត្តថវិកា, ការតាមដាននិងត្រួតពិនិត្យ និងសវនកម្ម។ ការងារនេះ មានអន្តរសកម្មឬទំនាក់ទំនងជាមួយសមាសធាតុកែទម្រង់ដទៃទៀត ដូចជាការកៀរគរចំណូល, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System; FMIS), ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ការគ្រប់គ្រងរំហួរសាច់ប្រាក់, កិច្ចការគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ។ សមាសធាតុទាំងនេះ មានបច្ច័យសំខាន់ចំពោះការសម្រេចគោលបំណងកែទម្រង់ប្រព័ន្ធថវិកាដែលកំពុងតែបោះជំហានទៅមុខ។ ទន្ទឹមនេះ, ក្រៅពីក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមានការដ្ឋានកែទម្រង់ពាក់ព័ន្ធសំខាន់ៗដទៃទៀត ជាពិសេសគឺ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលមានឥទ្ធិពលមកលើដំណើរការនៃការកែទម្រង់ប្រព័ន្ធថវិកា។

ដើម្បីធានាបានន្លូវចលនការ និងភាពប្រាកដនិយម ក្នុងការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ឆ្ពោះទៅគោលដៅកសាងគណនេយ្យភាពសមិទ្ធកម្ម, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានរៀបចំឯកសារមគ្គុទេសន៍ សម្រាប់កិច្ចដំណើរការកម្មវិធីកែទម្រង់ជំហានបន្ទាប់និងចុងក្រោយនេះ ដោយប្រសិទ្ធនាមថា “**ចក្ខុវិស័យនិងយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ដំណាក់កាលទី៤**”។ ឯកសារនេះ ចែកចេញជា ៧ ផ្នែកគឺ÷

១. សេចក្តីផ្តើម

២. ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៣. យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៤. សមិទ្ធផល បទពិសោធន៍ និងការបោះជំហានទៅកាន់ដំណាក់កាលទី៤

៥. ផែនការសកម្មភាពរួមនិងក្របខ័ណ្ឌលទ្ធផលដំណាក់កាលទី៤

៦. រចនាសម្ព័ន្ធទ្រទ្រង់សម្រាប់ដំណាក់កាលទី៤

៧. សេចក្តីសន្និដ្ឋាន

២. ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានកំណត់តាំងពីដំណាក់-កាលទី១ នៅតែរក្សាបានភាពត្រឹមត្រូវសម្រាប់ដំណាក់កាលទី៤ ពោលគឺ **“ការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដោយផ្លាស់ប្តូរពីប្រព័ន្ធដែលផ្តោតលើធាតុចូលនិងមានលក្ខណៈមជ្ឈការ ទៅកាន់ប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ”**។

ការសម្រេចបានន្លូវចក្ខុវិស័យនេះ នឹងធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាកាន់តែមានភាពរឹងមាំ និងឈានទៅសម្រេចបានលទ្ធផលចុងក្រោយទាំង ៣ រួមមាន ប្រសិទ្ធភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា (ទាំងក្នុងផ្នែកវិភាជន៍និងក្នុងផ្នែកប្រតិបត្តិការ), និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

៣. យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីសម្រេចចក្ខុវិស័យរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលបានកំណត់យកតាំងពីចុងឆ្នាំ២០០៤ រហូតមក នូវ “អភិក្រមជាខឿននិងជាដំណាក់កាល (Platform Approach)” ជាយុទ្ធសាស្ត្រកែទម្រង់។ អភិក្រមនេះ មានលក្ខណៈពិសេស ៣ យ៉ាងគឺ÷ (១) ការកែទម្រង់ក្នុងខឿន

នីមួយៗ ឬដំណាក់កាលនីមួយៗ ត្រូវមានគោលបំណងស្នូលច្បាស់លាស់ ដែលឆ្លើយតបទៅនឹងចក្ខុវិស័យនៃកម្មវិធីកែទម្រង់, (២) ការកែទម្រង់ក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ ត្រូវជាមូលដ្ឋានសម្រាប់ការកែទម្រង់ក្នុងខឿនបន្តបន្ទាប់ និង (៣) សមិទ្ធផលផ្សេងៗដែលសម្រេចបានក្នុងខឿនមុនៗ ឬដំណាក់កាលមុនៗ ត្រូវបន្តពង្រឹងបន្ថែមក្នុងខឿន ឬដំណាក់កាលបន្តបន្ទាប់។

ស្របតាមអភិក្រមនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ត្រូវបានរៀបចំឡើង ដោយបែងចែកជា ៤ ខឿន និង ៤ ដំណាក់កាល។ ការកែទម្រង់ក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ ឆ្លុះបញ្ចាំងតាមរយៈផែនការសកម្មភាពរួមមួយ (Consolidated Action Plan; CAP)។ អង្គភាពដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ ត្រូវរៀបចំផែនការសកម្មភាពលម្អិតរបស់ខ្លួន ដោយផ្អែកលើផែនការសកម្មភាពរួម (CAP)។ ការកែទម្រង់ក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ មានគោលបំណងដូចតទៅ÷

- **ដំណាក់កាលទី១ "ការកសាងភាពជឿទុកចិត្តនៃថវិកា"÷** ការកែទម្រង់នៅក្នុងដំណាក់កាលទី១ ចំណាយអស់រយៈពេលប្រហែល៤ឆ្នាំ គិតចាប់ពីចុងឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០០៨ ដោយសម្រេចបានជោគជ័យ នូវមូលដ្ឋានគ្រឹះនៃការពង្រឹងការប្រមូលចំណូល, ការគ្រប់គ្រងចំណូល, ការគ្រប់គ្រងសាច់ប្រាក់, និងការកែលម្អចំណាយ។
- **ដំណាក់កាលទី២ "ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ"÷** ការកែទម្រង់នៅក្នុងដំណាក់កាលទី២ ចំណាយអស់រយៈពេលប្រហែល៧ឆ្នាំ គិតចាប់ពីដើមឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១៥ ដោយសម្រេចបាននូវមូលដ្ឋានគ្រឹះសំខាន់ៗ សម្រាប់ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ រួមមានដូចជាការដាក់ឱ្យអនុវត្តប្តង់គណនេយ្យថ្មី, មាតិកាថវិកាថ្មី, ថវិកាកម្មវិធី, ផែនការយុទ្ធសាស្ត្រថវិកា (Budget Strategic Plan; BSP), អង្គភាពថវិកា, និងប្រព័ន្ធ FMIS។
- **ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"÷** ការកែទម្រង់នៅក្នុងដំណាក់កាលទី៣ ចំណាយអស់រយៈពេលប្រហែល៧ឆ្នាំ គិតចាប់ពីឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០២២ ដោយសម្រេចបាននូវមូលដ្ឋានគ្រឹះសំខាន់ៗ ដូចជាការដាក់ឱ្យអនុវត្តជាផ្លូវការនូវការកែទម្រង់ថ្មីនៃប្រព័ន្ធ FMIS និងការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង ស្ថាប័ន និងនៅតាមបណ្តារដ្ឋបាលរាជធានី ខេត្តទាំង២៥។
- **ដំណាក់កាលទី៤ "កសាងគណនេយ្យភាពសមិទ្ធកម្ម"÷** ការកែទម្រង់នៅក្នុងដំណាក់កាលទី៤ ចាប់ផ្តើមពីឆ្នាំ២០២៣ នេះតទៅ។ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនេះ, ការកែទម្រង់ប្រព័ន្ធ

ថវិកាឆ្ពោះទៅរកប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថាថវិកាសមិទ្ធកម្ម ត្រូវបានកំណត់ថា ជាស្នូល របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានគិតគូរម៉ត់ចត់ ដោយរៀបចំជារចនាសម្ព័ន្ធទ្រទ្រង់ចំនួន៥ ដើម្បី គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ រចនាសម្ព័ន្ធទ្រទ្រង់ទាំង៥ រួមមាន÷

ទីមួយ. យន្តការស្ថាប័ន÷ នៅដំណាក់កាលទី១, ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈប្រមូលផ្តុំនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប៉ុន្តែសម្រាប់ដំណាក់កាលទី២ និងដំណាក់កាល បន្តបន្ទាប់, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានលក្ខណៈស្មុគស្មាញនិងមានវិសាលភាពដល់ ក្រសួង ស្ថាប័ន និង រដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មាន ភាពប្រទាក់ក្រឡាគ្នា ជាមួយកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល ជាពិសេសគឺ កម្មវិធីជាតិកែ-ទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ហេតុនេះ, ការបែងចែកភារកិច្ចរបស់តួអង្គនីមួយៗឱ្យបានច្បាស់លាស់ នៅក្នុងការដ្ឋានកែទម្រង់ និងការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធ ពិតជាមានសារៈសំខាន់។ ក្នុងន័យ នេះ, យន្តការស្ថាប័នសម្រាប់អនុវត្តកម្មវិធីកែទម្រង់នេះ មានលក្ខណៈបត់បែន ដែលតម្រូវឱ្យមានការពង្រឹង ពង្រីក និងកែលម្អជាប្រចាំ ស្របតាមបរិការណ៍កែទម្រង់ក្នុងដំណាក់កាលនីមួយៗ។ យន្តការស្ថាប័ន សម្រាប់ គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ នៅក្នុងដំណាក់កាលទី៤ មានចែងលម្អិតនៅក្នុងផ្នែក ៦.១.។

ទីពីរ. សមត្ថភាពស្ថាប័ន÷ សមត្ថភាពស្ថាប័នត្រូវឆ្លើយតបទៅនឹងគោលបំណងនៃការងារកែទម្រង់ នៅក្នុងដំណាក់កាលនីមួយៗ។ ក្នុងន័យនេះ, ផែនការកសាងសមត្ថភាព ចាំបាច់ត្រូវរៀបចំសម្រាប់ដំណាក់-កាលនីមួយៗ ហើយការងារនេះទាមទារឱ្យមានការកំណត់និងវិភាគពីតម្រូវការជំនាញមូលដ្ឋាននិងជំនាញ បច្ចេកទេសឱ្យបានច្បាស់លាស់។ ផែនការកសាងសមត្ថភាពនេះ ក៏នឹងក្លាយជាមធ្យោបាយមួយ ក្នុងការចូលរួម ចំណែកលើកទឹកចិត្តនិងពង្រឹងភាពជាអ្នកដឹកនាំដល់មន្ត្រី ដែលចូលរួមដោយផ្ទាល់និងប្រយោល ក្នុងការងារ កែទម្រង់ផងដែរ។ យន្តការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ នៅក្នុង ដំណាក់កាលទី៤ មានចែងលម្អិតនៅក្នុងផ្នែក ៦.២.។

ទីបី. ធនធានហិរញ្ញវត្ថុ÷ កិច្ចដំណើរការកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុង ដំណាក់កាលនីមួយៗ ទាមទារឱ្យមានធនធានហិរញ្ញវត្ថុសមស្រប។ កម្មវិធីកែទម្រង់ត្រូវបានគាំទ្រដោយ មូលនិធិមួយដែលមានថវិការបស់រាជរដ្ឋាភិបាលនិងហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍន៍។ ព័ត៌មានពាក់ព័ន្ធ នឹងធនធានហិរញ្ញវត្ថុ សម្រាប់ការអនុវត្តកម្មវិធីកែទម្រង់ ក្នុងដំណាក់កាលទី៤ មានបង្ហាញនៅក្នុងផ្នែក ៦.៣។

ទីបួន. វិធានការដោះស្រាយបញ្ហាប្រឈម÷ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងដំណាក់កាលនីមួយៗ ទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះបញ្ហាប្រឈមនានាដែលបានកើតឡើង និងអាចកើតមានឡើងជាយថាហេតុ។ ក្នុងន័យនេះ, វិធានការដោះស្រាយបញ្ហាប្រឈមចាំបាច់ត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ដើម្បីធានាបាននូវចលនការនៃការងារកែទម្រង់នៅក្នុងដំណាក់-កាលនីមួយៗ។ វិធានការដោះស្រាយបញ្ហាប្រឈមសម្រាប់ដំណាក់កាលទី៤ មានបង្ហាញនៅក្នុងផ្នែក ៦.៤.។

ទីប្រាំ. វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ÷ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងដំណាក់កាលនីមួយៗ ឆ្លុះបញ្ចាំងតាមរយៈផែនការសកម្មភាពរួម និង ផែនការសកម្មភាពលម្អិតរបស់អង្គភាពដែលចូលរួមអនុវត្ត។ ផែនការសកម្មភាពលម្អិតរបស់អង្គភាពនីមួយៗ បង្ហាញពីសកម្មភាពដែលត្រូវអនុវត្ត ស្ថចនាករសមិទ្ធកម្មគន្លឹះ និងក្របខ័ណ្ឌពេលវេលា។ ហេតុនេះ, ដើម្បីធានាបានថាការកែទម្រង់ប្រព្រឹត្តទៅតាមអ្វីដែលបានកំណត់នៅក្នុងផែនការសកម្មភាពលម្អិត និង ដើម្បីធានាថាផែនការសកម្មភាពលម្អិតឆ្លើយតបទៅនឹងបរិការណ៍ជាក់ស្តែងនិងតម្រូវការនៃការកែទម្រង់, ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃជាប្រចាំគឺជាការចាំបាច់។ ក្នុងដំណាក់កាលទី១និងដំណាក់កាលទី២, យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការងារកែទម្រង់មានលក្ខណៈបត់បែន ដោយតម្រូវតាមបរិការណ៍ជាក់ស្តែងនៃការកែទម្រង់។ ឆ្លងកាត់បទពិសោធន៍នៃការកែទម្រង់ក្នុងដំណាក់កាលទាំង២, វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីកែទម្រង់ កាន់តែមានភាពប្រាកដប្រជាជាងមុន ដូចមានចែងលម្អិតនៅក្នុងសារាចរ-រាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ឧបសម្ព័ន្ធទី៥)។ នៅក្នុងដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់, វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ នឹងត្រូវបន្តអនុលោមតាមសារាចរនេះ និងមានបង្ហាញនៅក្នុងផ្នែក ៦.៥។

៤. សមិទ្ធផល បទពិសោធន៍ និងការដោះដូរមានទៅកាន់ដំណាក់កាលទី៤

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី១ “ភាពជឿទុកចិត្តនៃថវិកា” ផ្តល់អាទិភាពលើការងារពង្រឹងការប្រមូលនិងការគ្រប់គ្រងចំណូល, ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនិងជំរុញការអនុវត្តវិធានការជាច្រើន ដែលនាំឱ្យកម្ពុជាសម្រេចបានសមិទ្ធផលជាច្រើន ដូចជា÷ ការដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ, ការបង្កើតគណនីទោលរតនាគារ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងចំណូល ចំណាយ និងសាច់ប្រាក់, ការធ្វើទំនើបកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ

២០០៨, ការកែទម្រង់កិច្ចលទ្ធកម្មសាធារណៈ និងការបង្កើតប្រព័ន្ធត្រួតពិនិត្យនិងសវនកម្ម។ ចំពោះដំណាក់-កាលទី២ “គណនេយ្យភាពហិរញ្ញវត្ថុ”, កម្មវិធីកែទម្រង់ផ្តោតសំខាន់លើការរៀបចំ ការកែលម្អ ការពង្រឹង ការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និង ទាន់ពេលវេលា ព្រមទាំងស្របតាមស្តង់ដាអន្តរជាតិ។ នៅក្នុងដំណាក់កាលនេះ, រាជរដ្ឋាភិបាលសម្រេចបាន សមិទ្ធផលជាច្រើន ដូចជា÷ ការដាក់ឱ្យអនុវត្តប្រព័ន្ធធនាគារសម្រាប់ការបើកផ្តល់ប្រាក់បៀវត្សមន្ត្រីរាជការ, ការពង្រីកអង្គភាពសវនកម្ម, ការអភិវឌ្ឍសម្រេចបាននូវប្រព័ន្ធ FMIS និងការអនុវត្តគម្រោង FMIS។

សម្រាប់ដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”, កម្មវិធីកែទម្រង់បាន បោះជំហានដ៏សំខាន់មួយថ្មីទៀត ពោលគឺការចាប់ផ្តើមផ្លាស់ប្តូរប្រព័ន្ធថវិកាបច្ចុប្បន្ន ព្រមទាំងការចាប់ផ្តើម ពង្រឹង និងពង្រីកការសាកល្បងប្រព័ន្ធថវិកាកម្មវិធី ជាជំហានៗ ទៅក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាល រាជធានី ខេត្ត។ ក្នុងដំណាក់កាលនេះ, រាជរដ្ឋាភិបាលដាក់ចេញយុទ្ធសាស្ត្រគន្លឹះៗ រួមមាន÷ “យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥”, “យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម-ជាតិឆ្នាំ២០១៩-២០២៥”, “យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥”, “យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥”, “យុទ្ធសាស្ត្រកៀរគរ ចំណូល ២០១៩-២០២៣” និង “ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥” ដែលភ្ជាប់ជាមួយនឹងផែនការសកម្មភាពលម្អិត ដើម្បីធានាថាគ្រប់អង្គភាពពាក់ព័ន្ធ ទាំងអស់ចូលរួមអនុវត្តប្រកបដោយឆន្ទៈ, មនសិការ, និងការទទួលខុសត្រូវខ្ពស់។ ជាមួយគ្នានេះ, ច្បាប់គន្លឹះៗ មួយចំនួនត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងនោះ រួមមាន÷ (១) ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម, (២) ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការ ចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, (៣) ច្បាប់ស្តីពីមូលបត្ររដ្ឋ, (៤) ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរ សេវាហិរញ្ញវត្ថុមិនមែនធនាគារ និង (៥) ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

សមិទ្ធផលនេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចសន្សំ និងបង្វែរថវិកាកាន់តែច្រើនទៅកាន់វិស័យ អាទិភាព ក៍ដូចជាអាចបង្កើនយ៉ាងច្រើន នូវធនធានវិនិយោគសាធារណៈក្នុងស្រុក ពិសេស លើការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាប្រការជួយលើកស្ទួយមួយកម្រិត ដល់ឯករាជ្យភាពផ្នែកថវិការបស់កម្ពុជា។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលមានលទ្ធភាពដំឡើងបៀវត្សនិងប្រាក់ឧបត្ថម្ភជូនមន្ត្រីសាធារណៈ និងប្រាក់-សោធនជូនមន្ត្រីរាជការស៊ីវិលដែលចូលនិវត្តន៍ ឬបាត់បង់សម្បទាវិជ្ជាជីវៈ និងអតីតយុទ្ធជន។

ទន្ទឹមនឹងសមិទ្ធផលទាំងនេះ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឆ្លងកាត់បញ្ហា ប្រឈមមួយចំនួន ទាំងកម្រិតដឹកនាំ និងកម្រិតបច្ចេកទេស និងជាពិសេស ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ

នេះ គឺវិបត្តិសកលដែលរួមមានវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន។ វិបត្តិសកលទាំងនេះបានផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម-សេដ្ឋកិច្ចកម្ពុជា និងកិច្ចដំណើរការនៃការកែទម្រង់។ ប៉ុន្តែ, តាមរយៈមូលដ្ឋានគ្រឹះសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរឹងមាំដែលជាសមិទ្ធផលនៃការងារកែទម្រង់កន្លងមក, រាជរដ្ឋាភិបាលកម្ពុជាអាចគ្រប់គ្រងសភាពការណ៍បានល្អប្រសើរ។ បទពិសោធន៍ទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាស្ថិតនៅក្នុងមាគ៌ាមួយដ៏ត្រឹមត្រូវ ក្នុងការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរឹងមាំមួយ ដើម្បីឈានទៅសម្រេចបានលទ្ធផលចុងក្រោយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ពោលគឺ (១) ប្រសិទ្ធភាពនៃការគោរពវិន័យថវិកា, (២) ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍និងផ្នែកប្រតិបត្តិការ និង (៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។ ជាការសន្និដ្ឋាន, កម្ពុជាមានមូលដ្ឋានរឹងមាំគ្រប់គ្រាន់សម្រាប់បោះជំហានទៅកាន់ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"។

៥. ផែនការសកម្មភាពរួមនិងក្របខ័ណ្ឌលទ្ធផលដំណាក់កាលទី៤

ផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4) បង្ហាញពីគោលបំណង និងសកម្មភាពការងារកែទម្រង់កម្រិតយុទ្ធសាស្ត្រ។ CAP4 ជាឯកសារមូលដ្ឋាន សម្រាប់អង្គភាពនីមួយៗដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ ក្នុងការរៀបចំផែនការសកម្មភាពលម្អិតរបស់ខ្លួន។ ឯកសារនេះចែកចេញជា៥ផ្នែក ដូចមានលម្អិតក្នុងឧបសម្ព័ន្ធទី១០។ ក្នុងនោះ, ផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣បង្ហាញពីការងារកែទម្រង់ដែលមានទិសដៅពង្រឹងសមិទ្ធផលនានាដែលសម្រេចបាននៅក្នុងដំណាក់កាលមុនៗ។ ដោយឡែក, ផ្នែកទី៤បង្ហាញពីការងារកែទម្រង់ដែលមានទិសដៅ "កសាងគណនេយ្យភាពសមិទ្ធកម្ម" ដែលជាស្នូលរបស់កម្មវិធីកែទម្រង់ដំណាក់កាលទី៤ និង ផ្នែកទី៥បង្ហាញពីការងារកែទម្រង់ដែលមានទិសដៅគាំទ្រនិងធានាចលនការនៃការអនុវត្តកម្មវិធីកែទម្រង់។ ផ្នែកទាំងប្រាំនៃ CAP4 រួមមានដូចខាងក្រោម÷

- ផ្នែកទី១. ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា
- ផ្នែកទី២. ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ
- ផ្នែកទី៣. ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
- ផ្នែកទី៤. ការកសាងគណនេយ្យភាពសមិទ្ធកម្ម
- ផ្នែកទី៥. ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត។

CAP4 ត្រូវបានរៀបចំឡើង ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣, យុទ្ធសាស្ត្រកែទម្រង់នានារបស់រាជរដ្ឋាភិបាល និងរបាយការណ៍វាយតម្លៃអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈរបស់កម្ពុជា ដូចជា របាយការណ៍វាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability; PEFA) ឆ្នាំ២០២១, របាយការណ៍វាយតម្លៃប្រសិទ្ធភាពចំណាយសាធារណៈ (Public Expenditure Review; PER) ឆ្នាំ២០២២ និងរបាយការណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធ (Tax Administration Diagnostic Assessment Tool; TADAT) ឆ្នាំ ២០២២។ ខ្លឹមសារ CAP4 ត្រូវបានពិនិត្យនិងពិភាក្សា ជាមួយអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងតំណាងដៃគូអភិវឌ្ឍន៍, ហើយខ្លឹមសារលម្អិតត្រូវបានកែសម្រួលជាបន្តបន្ទាប់ និងទទួលបានការឯកភាពពីគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

CAP4 ផ្តោតលើការកែលម្អនិងពង្រឹងប្រសិទ្ធភាពចំណូល-ចំណាយ, ការធ្វើស្ងួយប្រវត្តិកម្មប្រតិបត្តិការហិរញ្ញវត្ថុក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ភាពគ្រប់ជ្រុងជ្រោយនៃការកត់ត្រា តាមដាន និងរាយការប្រតិបត្តិការហិរញ្ញវត្ថុ, ប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាប្រចាំឆ្នាំ ដែលផ្សារភ្ជាប់ទៅនឹងគោល-នយោបាយ, ការដាក់ឱ្យដំណើរការប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម, ការបង្កើនតម្លាភាពថវិកា និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យ។ គោលដៅចម្បងៗ នៃ CAP4 រួមមាន÷

- ប្រភពចំណូល គ្រប់ប្រភេទនឹងត្រូវធ្វើពិពិធកម្មនិងប្រមូលឱ្យអស់សក្តានុពល ដើម្បីពង្រីកលំហហិរញ្ញវត្ថុសាធារណៈ និងបង្កើនលទ្ធភាពចំណាយរបស់រាជរដ្ឋាភិបាល ក្នុងការរក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងឆ្លើយតបទៅនឹងកំណើនតម្រូវការចំណាយវិនិយោគសាធារណៈ។
- រដ្ឋបាលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ ត្រូវបន្តធ្វើទំនើបកម្មបន្ថែមទៀត ស្របតាមទិសដៅនៃយុទ្ធសាស្ត្រកៀរគរចំណូល, ហើយវិធាន នីតិវិធី និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងចំណូល ត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តនិងសង្គតិភាពនៃទិន្នន័យ។
- ការរៀបចំផែនការថវិកាត្រូវផ្អែកលើ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (Medium-Term Fiscal Framework; MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (Medium-Term Budget Framework; MTBF) ព្រមទាំងកំណត់បានហានិភ័យហិរញ្ញវត្ថុសាធារណៈ និងវិធានការដោះស្រាយ។ ដោយឡែក, ផែនការយុទ្ធសាស្ត្រថវិកា (BSP) ក៏នឹងត្រូវរៀបចំឱ្យកាន់តែមានភាពសុក្រឹត ដើម្បីកំណត់បាននូវពិតានចំណាយ ដែលជាមូលដ្ឋាននៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។
- ការចរចារនិងអនុម័តគម្រោងថវិកា នឹងផ្តល់អាទិភាពខ្ពស់លើ “សមិទ្ធកម្ម” ដោយការវិភាជថវិកាត្រូវពិនិត្យសមិទ្ធកម្ម នៃការអនុវត្តថវិកាឆ្នាំមុន (N-1) និងការវិនិច្ឆ័យគុណភាពនៃការរៀបចំផែនការ

ថវិកាឆ្នាំបន្ទាប់ (N+1) ដើម្បីឱ្យសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំកាន់តែមានខ្លឹមសារគ្រប់ជ្រុងជ្រោយ ព្រមទាំងស្របតាមការកំណត់នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

- ការអនុវត្តថវិកា នឹងត្រូវធ្វើវិមជ្ឈការសិទ្ធិសម្រេចបន្ថែមជូនអង្គភាពថវិកា ដែលមានលក្ខណៈសម្បត្តិសមស្រប, ហើយនីតិវិធីនៃការអនុវត្តថវិកានិងត្រួតពិនិត្យការអនុវត្តថវិកា ក៏នឹងត្រូវកែសម្រួលបន្ថែម ដោយបង្កើនការប្រើប្រាស់មុខងារនៃប្រព័ន្ធ FMIS និងកែលម្អរបបរបាយការណ៍។
- ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកា នឹងត្រូវផ្តោតលើគោលបំណងចំនួន២ គឺ (១) ធានាបាននូវគណនេយ្យភាព រវាងអង្គភាពគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈនិងអង្គភាពប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈ និង (២) ធានាតម្លៃនៃលុយ ដោយផ្សារភ្ជាប់លទ្ធផលនៃការត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តថវិកាទៅនឹងលទ្ធភាពនៃការវិភាជថវិកាសម្រាប់ឆ្នាំបន្ទាប់ (N+1)។
- គណនេយ្យនិងការទូទាត់ថវិកា នឹងត្រូវអនុវត្តតាមប្រព័ន្ធ FMIS ដើម្បីពន្លឿនការបើកផ្តល់សាច់ប្រាក់ ការផ្ទៀងផ្ទាត់ និងការបិទបញ្ជីគណនេយ្យ ឱ្យទាន់ពេលវេលានិងប្រកបដោយភាពគ្រប់ជ្រុងជ្រោយ សម្រាប់រៀបចំច្បាប់ទូទាត់ និងរបាយការណ៍ហិរញ្ញវត្ថុ ឱ្យស្របតាមស្តង់ដាគណនេយ្យសាធារណៈ។

៥.១. ផ្នែកទី១ "ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"

ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា មានគោលបំណងពង្រីកលំហហិរញ្ញវត្ថុសាធារណៈ (Fiscal Space) ដើម្បីទ្រទ្រង់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍និងសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់។ លទ្ធផលនៃផ្នែកទី១នេះ គឺសម្រេចឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ (Fiscal Sustainability) ក្នុងបរិបទដែលស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈកម្ពុជា បាននិងកំពុងរងឥទ្ធិពលពីភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល។ ចីរភាពហិរញ្ញវត្ថុសាធារណៈ នឹងត្រូវឆ្លុះបញ្ចាំងតាមរយៈភាពធន់មាំនៃកំណើនថវិកា ដែលត្រូវបានអនុវត្តប្រចាំត្រីមាសនិងឆ្នាំ ប្រកបដោយភាពរលូននិងអាចប៉ាន់ប្រមាណបានស្ថិតនៅក្នុងរង្វង់ +/- ៥% នៃច្បាប់ថវិកា។

ផ្នែកនេះនឹងជំរុញការកែទម្រង់ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៤ រួមមាន÷ (១) ការបង្កើនការប្រមូលចំណូល, (២) ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកា, (៣) ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ, និង (៤) ការពង្រឹងការគ្រប់គ្រងបន្ទុកសារពើពន្ធ (Tax Expenditure)។

ការប្រមូលចំណូល នៅតែជាអាទិភាពស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្អែកតាមយុទ្ធសាស្ត្រកៀរគរចំណូល, ការសម្រេចបានគោលដៅនៃការប្រមូលចំណូលប្រចាំឆ្នាំឱ្យបានយ៉ាងតិច ០,៣ ពិន្ទុភាគរយធៀបនឹង ផ.ស.ស. គឺជាមូលដ្ឋានដ៏ចាំបាច់ ក្នុងការទ្រទ្រង់ថវិកាចំណាយប្រតិបត្តិការនិង

បង្កើនការវិនិយោគសាធារណៈ។ ក្នុងន័យនេះ, CAP4 ជំរុញការកែលម្អគោលនយោបាយនិងរដ្ឋបាលសារពើពន្ធ ដើម្បីកៀរគរចំណូលឱ្យអស់សក្តានុពលនិងផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធឱ្យចំគោលដៅ សម្រាប់ការលើកកម្ពស់ភាពប្រកួតប្រជែងនិងការបង្កើនផលិតភាពសេដ្ឋកិច្ចជាតិ។

ចំពោះការគ្រប់គ្រងថវិកាចំណាយវិញ, CAP4 ពង្រឹងការរៀបចំនិងអនុវត្តផែនការថវិកា ដោយគ្រប់គ្រងសាច់ប្រាក់និងបង្ការមិនឱ្យមានចំណាយកកស្ទះ ពន្លឿនដំណើរការនៃការអនុវត្តនិងការទូទាត់ចំណាយដោយបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារនិងប្រព័ន្ធ E-transfer ហើយបន្តកែលម្អដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈ ដោយធ្វើវិមជ្ឈការសិទ្ធិសម្រេចលទ្ធកម្មនិងពង្រឹងការរៀបចំនិងអនុវត្តផែនការលទ្ធកម្មសាធារណៈ។

តារាង ៥.១. ក្របខ័ណ្ឌលទ្ធផលឆ្នាំ២០២៧ សម្រាប់ផ្នែកទី១

"ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"

លទ្ធផលចុងក្រោយ	សូចនាករឆ្លងគោលដៅឆ្នាំ២០២៧
ផ្នែកទី១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ការអនុវត្តថវិកា (ចំណូល-ចំណាយ) មានភាពធន់មាំ ហើយលទ្ធផលនៃការអនុវត្តថវិកាប្រចាំត្រីមាសនិងប្រចាំឆ្នាំ មានភាពរលូននិងអាចប៉ាន់ប្រមាណបានស្ថិតនៅក្នុងរង្វង់ +/- ៥% នៃច្បាប់ថវិកា។	
(១) ការបង្កើនការប្រមូលចំណូល	កំណើនចំណូលចរន្តធៀបនឹងផ.ស.ស. = ០,៣ ពិន្ទុភាគរយ
	ទឹកប្រាក់បំណុលពន្ធទារបានក្នុងឆ្នាំនីមួយៗ = យ៉ាងតិច ២០% ក្នុងមួយឆ្នាំ
	បំណុលមិនមែនពន្ធក្នុងឆ្នាំ (ថ្មី) មិនត្រូវលើស ១០% នៃចំណូលមិនមែនពន្ធសរុបក្នុងឆ្នាំ
	សន្និធិបំណុលមិនមែនពន្ធត្រូវបានកាត់បន្ថយ ១០% ជារៀងរាល់ឆ្នាំ
	ការប្រមូលចំណូលនៃប្រភេទពន្ធ លើមុខសញ្ញា (ដូចជា ពន្ធលើចំណូលរូបវន្តបុគ្គល និងពន្ធលើប្រាក់ចំណេញមូលធន) នីមួយៗសម្រេចយ៉ាងតិច ៩៥% នៃគោលដៅឆ្នាំ
(២) ការកែលម្អការអនុវត្តថវិកា	ភាគរយនៃការអនុវត្តចំណាយ (កម្រិតក្រសួង ស្ថាប័ន) ធៀបនឹងកម្មវិធីចំណាយប្រចាំត្រីមាស÷ • ត.ម. ១ = យ៉ាងតិច ២០% • ត.ម. ២ = យ៉ាងតិច ៤៥% • ត.ម. ៣ = យ៉ាងតិច ៧០% • ត.ម. ៤ = យ៉ាងតិច ៩៥%
	យ៉ាងតិច ៨០% នៃចំណាយសរុបទូទាត់រួច ត្រូវបានធ្វើការទូទាត់តាម E-Transfer
	ប្រតិបត្តិការថវិកាឆ្នាំ N ត្រូវបិទបញ្ចប់ត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ N+1

លទ្ធផលចុងក្រោយ	សូចនាករគន្លឹះគោលដៅឆ្នាំ២០២៧
	ការអនុវត្តថវិកា (កម្រិតជាតិ) ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំត្រូវស្ថិតក្នុងរង្វង់ +/- ៥%
(៣) ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ	ភាគរយនៃចំនួនគម្រោងនិងឥណទានគម្រោងលទ្ធកម្មសាធារណៈដែលត្រូវបានប្រតិបត្តិការក្នុងប្រព័ន្ធ FMIS • ៩០% នៃចំនួនគម្រោងសរុប • ៩៥% នៃឥណទានគម្រោងសរុប
	ការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្មក្នុងការអនុវត្តថវិកាចរន្តសម្រេចយ៉ាងតិច ៨០% (ថវិកាចរន្ត) នៃទឹកប្រាក់លទ្ធកម្មសរុប
	វិមជ្ឈការលទ្ធកម្មសាធារណៈ÷ ជំហានទី៣ នៃការអនុវត្តប្រកាសបង្កើនសិទ្ធិសម្រេចលទ្ធកម្ម ត្រូវបានអនុម័តក្នុងឆ្នាំ២០២៥
	ព័ត៌មានលទ្ធកម្ម (ផែនការលទ្ធកម្ម, ការប្រគល់កិច្ចសន្យា, ព្រឹត្តិបត្រលទ្ធកម្ម) នៃអង្គភាពថវិកាយ៉ាងតិច ៧៥% នៃចំនួនអង្គភាពថវិកាសរុបឆ្នាំ២០២៦ សរុប ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ
(៤) ការគ្រប់គ្រងបន្ទុកសារពើពន្ធ	បន្ទុកសារពើពន្ធត្រូវបានវិភាគនិងរាយការយ៉ាងគ្រប់ជ្រុងជ្រោយ
	ផលិតភាពសេដ្ឋកិច្ចកម្ពុជាត្រូវបានត្រួតពិនិត្យ វាស់វែង និងវាយតម្លៃផ្អែកតាមក្របខ័ណ្ឌនិងផែនការសកម្មភាពច្បាស់លាស់

៥.២. ផ្នែកទី២ "ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"

ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ មានគោលបំណងធ្វើស្ងួយប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពង្រឹងប្រព័ន្ធគណនេយ្យសាធារណៈកម្ពុជា ឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ ដើម្បីអាចផលិតរបាយការណ៍ហិរញ្ញវត្ថុនិងរៀបចំច្បាប់ទូទាត់ថវិកា ទាន់ពេលវេលានិងអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ។ លទ្ធផលនៃផ្នែកទី២នេះ គឺសម្រេចឱ្យបាននូវការពង្រីកការដ្ឋានប្រើប្រាស់មុខងារប្រព័ន្ធ FMIS ហើយធានាថាទិន្នន័យស្តីពីធនធានហិរញ្ញវត្ថុសាធារណៈរួមមាន ថវិការដ្ឋ, ទ្រព្យសម្បត្តិរដ្ឋ, បំណុលសាធារណៈ និងស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈមានវិសាលភាពគ្រប់ជ្រុងជ្រោយនិងអាចប្រើប្រាស់ សម្រាប់ការត្រួតពិនិត្យនិងពិនិស្ច័យ។

ផ្នែកនេះនឹងជំរុញការកែទម្រង់លើលទ្ធផលចុងក្រោយចំនួន ៥ រួមមាន÷ (១) ការធ្វើស្ងួយប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងច្បាប់ទូទាត់ថវិកា, (៣)

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, (៤) ការគ្រប់គ្រងបំណុលសាធារណៈ, និង (៥) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈ។

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ បានកំណត់ឱ្យមានការប្រើប្រាស់ប្រព័ន្ធ FMIS តែមួយគត់ សម្រាប់គ្រប់គ្រង រៀបចំ អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តចំណូល-ចំណាយថវិការដ្ឋ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិ-រដ្ឋ។ អង្គភាពសាធារណៈទាំងអស់ រួមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំនិងផ្តល់ជូនរដ្ឋមន្ត្រីក្រសួង-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរបាយការណ៍និងឯកសារដែលពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យ នៃថវិការដ្ឋ ដើម្បីផ្ទៀងផ្ទាត់និងរៀបចំជាច្បាប់ហិរញ្ញវត្ថុ។

ស្របតាមទិសដៅនេះ, CAP4 ផ្តល់អាទិភាពសំខាន់លើការពង្រីកការដ្ឋានប្រើប្រាស់ប្រព័ន្ធ FMIS ដោយអភិវឌ្ឍមុខងារបន្ថែម និងធ្វើសន្ទានកម្មជាមួយប្រព័ន្ធពាក់ព័ន្ធ ហើយពង្រឹងគុណភាពទិន្នន័យនិង អនុលោមភាពនៃការរៀបចំរបាយការណ៍របស់អង្គភាពសាធារណៈទាំងអស់ ឱ្យស្របតាមការកំណត់នៃច្បាប់ពោលគឺ ថវិកាចំណូល-ចំណាយ (ចរន្តនិងវិនិយោគ) និងចលនាឥណទានត្រូវអនុវត្តទាំងស្រុងតាមនីតិវិធីនៃប្រព័ន្ធ FMIS, របាយការណ៍អនុវត្តថវិកាប្រចាំត្រីមាសនិងប្រចាំឆ្នាំអាចផលិតពីប្រព័ន្ធ FMIS, ទិន្នន័យទ្រព្យ-សម្បត្តិរដ្ឋនិងបំណុលសាធារណៈត្រូវបានឆ្លុះបញ្ចាំងក្នុងប្រព័ន្ធ FMIS, និងរបាយការណ៍និងច្បាប់ហិរញ្ញវត្ថុ របស់ជាតិត្រូវបានរៀបចំ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងអនុលោមតាមស្តង់ដា គណនេយ្យសាធារណៈ។

តារាង ៥.២. ក្របខ័ណ្ឌលទ្ធផលឆ្នាំ២០២៧ សម្រាប់ផ្នែកទី២

"ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
ផ្នែកទី២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងការធ្វើស្ង៉ៃប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ, និង ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។	
(១) ការធ្វើស្ង៉ៃប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	ការប្រើប្រាស់មុខងាររបស់ប្រព័ន្ធ FMIS ត្រូវបានពង្រីកទៅកាន់ការដ្ឋានគោលដៅ÷ • មុខងារស្នូលទាំង៦÷ គ្រប់ក្រសួង ស្ថាប័ន, រដ្ឋបាលរាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រតនាគារ, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ, គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញចំនួន ៦ តាមបណ្តារាជធានីខេត្តទាំង ២៥

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
	• មុខងាររៀបចំថវិកា÷ គ្រប់ក្រសួង ស្ថាប័ន, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ, រដ្ឋបាលរាជធានីខេត្ត, និងមន្ទីរជំនាញចំនួន ៦ តាមបណ្តារាជធានីខេត្តទាំង២៥ • មុខងារគ្រប់គ្រងលទ្ធកម្ម÷ គ្រប់ក្រសួង ស្ថាប័ន, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ, រដ្ឋបាលរាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ព្រមទាំងការដាក់ឱ្យដំណើរការ e-GP នៅក្រសួងចំនួន ១០ • មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ÷ គ្រប់ក្រសួង ស្ថាប័ន • មុខងារគ្រប់គ្រងសន្និធិ÷ គ្រប់ក្រសួង ស្ថាប័ន
	នីតិវិធីថ្មីសម្រាប់អនុវត្តថវិកានៅអង្គភាពថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យអនុវត្តទាំងស្រុងតាមប្រព័ន្ធ FMIS÷ • នីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា • នីតិវិធីចលនាឥណទានថវិកា (ការរៀបចំប្រកាសនិយ័តកម្ម/ផ្ទេរឥណទាន) • នីតិវិធីចំណូលថវិកា • នីតិវិធីចំណាយថវិកាវិនិយោគហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិគ្រប់មុខសញ្ញា • នីតិវិធីលទ្ធកម្មពេញលេញ
	វិសាលភាពទិន្នន័យនៃប្រព័ន្ធ FMIS ត្រូវបានពង្រីក ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់÷ • ប្រព័ន្ធ FMIS ត្រូវបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធគយ, ប្រព័ន្ធពន្ធដារ, NRMIS, DMFAS, ប្រព័ន្ធធនាគារជាតិ, ប្រព័ន្ធធនាគារពាណិជ្ជ, SARMIS, ប្រព័ន្ធគ្រប់គ្រងបៀវត្ស, ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ និង EFMS ហើយអាចផលិតទិន្នន័យប្រកបដោយសង្គតិភាព • ចំណាយដៃគូត្រូវបានកត់ត្រាក្នុងប្រព័ន្ធ FMIS និងអាចផលិតចេញពីប្រព័ន្ធ FMIS សម្រាប់រៀបចំជាតារាងឧបសម្ព័ន្ធនៃច្បាប់ទូទាត់ • ទម្រង់ត្រូវបានអភិវឌ្ឍន៍គ្រប់គ្រាន់ សម្រាប់ផលិតរបាយការណ៍ស្តីពីការអនុវត្តថវិកា, របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍តាមដានប្រតិបត្តិការហិរញ្ញវត្ថុចេញពីប្រព័ន្ធ FMIS
	ប្រព័ន្ធ FMIS ត្រូវបានធ្វើទំនើបកម្ម ដែលអាចសម្រួលប្រតិបត្តិការនិងរក្សាទុកទិន្នន័យហិរញ្ញវត្ថុសាធារណៈប្រកបដោយសុវត្ថិភាព ព្រមទាំងបង្កើនន្ធវគណនេយ្យភាព

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
	ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ ដែលផ្តល់នូវព័ត៌មានចំណូល-ចំណាយថវិកាគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា។
(២) ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងច្បាប់ទូទាត់	បញ្ជីគណនេយ្យត្រូវបានបិទត្រឹមខែមិថុនា ឆ្នាំ N+1
	របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំស្របតាមស្តង់ដាគណនេយ្យកែសម្រួលសាច់ប្រាក់ (Modified Cash) ត្រូវផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មត្រឹមខែសីហា ឆ្នាំ N+1
	សេចក្តីព្រាងច្បាប់ទូទាត់ត្រូវផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ដោយភ្ជាប់នូវរបាយការណ៍ហិរញ្ញវត្ថុ ក្នុងរយៈពេល ៦ ខែបន្ទាប់ពីការបិទបញ្ជីគណនេយ្យ
(៣) ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ	គ្រប់ក្រសួង ស្ថាប័ន, រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌប្រើប្រាស់ប្រព័ន្ធ SARMIS អនឡាញ
	គ្រប់ទីតាំងដីរដ្ឋទាំងអស់មានបណ្ណសម្គាល់កម្មសិទ្ធិ
	គ្រប់ក្រសួង ស្ថាប័នអនុវត្តកម្រិតទំហំទ្រព្យសកម្មរយៈពេលវែង (Fixed Asset Threshold)
(៤) ការគ្រប់គ្រងបំណុលសាធារណៈ	សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិដានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
	របាយការណ៍វឌ្ឍនភាពនៃការគ្រប់គ្រងបំណុល ត្រូវបានរៀបចំនៅក្នុងរង្វង់ ៣ខែ បន្ទាប់ពីត្រីមាសនីមួយៗ
	របាយការណ៍វឌ្ឍនភាពស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ត្រូវបានរៀបចំ
(៥) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ	គ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន ៣០ រៀបចំរបាយការណ៍អនុវត្តថវិកានិងរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមលក្ខណវិនិច្ឆ័យអប្បបរមា
	គ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន ៣០ ផ្ញើរបាយការណ៍អនុវត្តថវិកានិងរបាយការណ៍ហិរញ្ញវត្ថុទាន់ពេលវេលាស្របតាមការកំណត់នៃច្បាប់
	របាយការណ៍វាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈប្រចាំឆ្នាំត្រូវបានពិនិត្យនិងពិភាក្សា ស្របតាមការកំណត់នៃយុទ្ធសាស្ត្រស្តីពីការកែទម្រង់សហគ្រាសសាធារណៈនិងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ

៥.៣. ផ្នែកទី៣ "ការពង្រឹងប្រសិទ្ធភាពការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"

ការពង្រឹងប្រសិទ្ធភាពការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ មានគោលបំណងពង្រឹងការរៀបចំគម្រោងថវិកាឱ្យមានព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយ ដើម្បីអាចតម្រឹមធនធានហិរញ្ញវត្ថុជាមួយនឹងអាទិភាពគោលនយោបាយនិងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល។

លទ្ធផលផ្នែកទី៣នេះ គឺត្រូវសម្រេចឱ្យបាននូវការអនុម័តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ហើយជំរុញការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ឱ្យមានរចនាសម្ព័ន្ធកម្មវិធីនិងព័ត៌មានសមិទ្ធកម្មច្បាស់លាស់ ព្រមទាំងឆ្លុះបញ្ចាំងនូវគម្រោងចំណូលនិងចំណាយគ្រប់មុខសញ្ញាទាំងថវិកាចរន្តនិងវិនិយោគតាមកម្មវិធីផងដែរ។

ផ្នែកនេះនឹងជំរុញការកែទម្រង់ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៤ រួមមាន÷ (១) ការកែលម្អការរៀបចំផែនការថវិការយៈពេលមធ្យម, (២) ការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ, (៣) ការកែលម្អប្រសិទ្ធភាពនៃការគ្រោងថវិកា (ថវិកាកម្មវិធី), និង (៤) ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិនិងតាមវិស័យរបស់រាជរដ្ឋាភិបាល ត្រូវរក្សាភាពទន់ភ្លន់ដើម្បីឆ្លើយតបទៅនឹងបរិការណ៍និងស្ថានភាពនៃការអនុវត្តជាក់ស្តែង។ ក្របខ័ណ្ឌ MTFF និង MTBF គឺជាការកំណត់អាទិភាពចំពោះមុខរបស់រាជរដ្ឋាភិបាល សម្រាប់អង្គភាពសាធារណៈទាំងអស់ ក្នុងការរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍន៍តាមវិស័យនិងតាមសមត្ថកិច្ចរៀងៗខ្លួន។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ បានកំណត់នូវវិធាននិងដំណើរការនៃការរៀបចំ BSP និងគម្រោងថវិកាប្រចាំឆ្នាំ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំបែបបទនិងនីតិវិធីណែនាំលម្អិត។

ស្របតាមទិសដៅនេះ, CAP4 ជំរុញការកែលម្អគុណភាពនៃការរៀបចំគម្រោងថវិការបស់អង្គភាពសាធារណៈទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយផ្តោតការយកចិត្តទុកដាក់លើការអនុម័តក្របខ័ណ្ឌ MTFF និង MTBF, ការកំណត់ពិដានចំណាយគោល, ការធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាវិនិយោគ, ការពង្រឹងយន្តការពិនិត្យលើគម្រោងវិនិយោគសាធារណៈ, ការរៀបចំចំណាយតាមកម្មវិធីឱ្យមានរចនាសម្ព័ន្ធនិងការទទួលខុសត្រូវច្បាស់លាស់ និងពង្រឹងមុខងារត្រួតពិនិត្យការអនុវត្តថវិកា។

តារាង ៥.៣. ក្របខ័ណ្ឌលទ្ធផលឆ្នាំ២០២៧ សម្រាប់ផ្នែកទី៣

"ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
ផ្នែកទី៣ ÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម,ការពង្រឹងការអនុវត្តថវិកាកម្មវិធី, ការរៀបចំក្របខ័ណ្ឌនៃការគ្រប់គ្រងវិនិយោគសាធារណៈ និង ការបន្តជំរុញការធ្វើវិមជ្ឈការប្រព័ន្ធថវិកាពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ។	
(១) ការកែលម្អការរៀបចំផែនការថវិការយៈពេលមធ្យម	MTFF ត្រូវបានភ្ជាប់ជាមួយសេចក្តីព្រាងច្បាប់ថវិកាជូនទៅអង្គនីតិប្បញ្ញត្តិ
	MTFF ត្រូវបានផ្សព្វផ្សាយលើគេហទំព័រ កហសវ. បន្ទាប់ពីដាក់ជូនអង្គនីតិប្បញ្ញត្តិ
	MTBF & ពិតានចំណាយគោលត្រូវបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល
	លទ្ធផលនៃការវាយតម្លៃគុណភាព BSP របស់ក្រសួង ស្ថាប័នត្រូវបានប្រើប្រាស់សម្រាប់ការចរចារថវិកា
(២) ការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ	ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈរួមមួយរបស់ជាតិត្រូវបង្កើត÷ • អនុក្រឹត្យលេខ ៤១ ត្រូវបានធ្វើបច្ចុប្បន្នភាព ផ្អែកតាមការវាយតម្លៃ ក្របខ័ណ្ឌវាយតម្លៃការគ្រប់គ្រងវិនិយោគសាធារណៈ (Public Investment Management Assessment; PIMA) • នីតិវិធីប្រតិបត្តិរួមតាមប្រភពធនធានត្រូវបានតម្រឹមតាមខ្លឹមសារនៃអនុក្រឹត្យលេខ ៤១ ថ្មី • យន្តការអនុវត្តការគ្រប់គ្រងវិនិយោគសាធារណៈត្រូវបានអនុវត្ត • ប្រព័ន្ធគ្រប់គ្រងទិន្នន័យវិនិយោគសាធារណៈត្រូវបានអភិវឌ្ឍន៍
(៣) ការកែលម្អប្រសិទ្ធភាពនៃការគ្រោងថវិកា (PB)	ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នត្រូវបានកែលម្អ÷ • គម្លាតរវាងពិដានចំណាយគោលនិងលទ្ធផលកញ្ចប់ថវិកាប្រចាំឆ្នាំ (N+1) ស្ថិតក្នុងរង្វង់ +/-១0% • ចំណាយបន្ទុកបុគ្គលិកនៃការស្នើថវិកាឆ្នាំ N+1 ត្រូវបានព្យែកតាមកម្មវិធី • ពិដានចំណាយគោលលើចំណាយវិនិយោគផ្តាល់ត្រូវបានកំណត់ជូនក្រសួង ស្ថាប័នចំនួន ១១ (៩៥% នៃចំណាយវិនិយោគផ្តាល់សរុប) • ចំណាយចរន្តនិងវិនិយោគផ្តាល់របស់ក្រសួង ស្ថាប័នចំនួន ៩ (៩0% នៃចំណាយវិនិយោគផ្តាល់សរុប) ត្រូវបានធ្វើសមាហរណកម្មក្នុងគម្រោងថវិកា BSP & PB
	ការទទួលខុសត្រូវលើថវិកាត្រូវបានធ្វើវិមជ្ឈការបន្ថែម÷ • ក្រសួង ស្ថាប័នទាំងអស់អនុវត្តការត្រួតពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកា

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
	• ក្រសួង ស្ថាប័នទាំងអស់ធ្វើសេចក្តីសម្រេច ក្នុងការរក្សាឬបង្កើនចំនួនអង្គភាពថវិកា, អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញ ផ្អែកតាមការពិនិត្យលក្ខណៈសម្បត្តិជារៀងរាល់ឆ្នាំ
	ការផ្សារភ្ជាប់ថវិកានិងគោលនយោបាយត្រូវបានពង្រឹង÷ • យន្តការត្រួតពិនិត្យការអនុវត្តថវិកាតាមវិស័យនិងគោលនយោបាយត្រូវបានអនុវត្ត • របាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យថវិកាតាមវិស័យឬគោលនយោបាយប្រចាំឆ្នាំត្រូវរៀបចំ
(៤) ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ	ការរៀបចំនិងចរចារគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ÷ • គម្រោងថវិការបស់មន្ទីរជំនាញរាជធានីខេត្តត្រូវបានតម្រឹមជាមួយ BSP របស់រដ្ឋបាលរាជធានី ខេត្ត • គម្រោងថវិការបស់រដ្ឋបាលក្រុងស្រុកនិងរដ្ឋបាលឃុំសង្កាត់ត្រូវបានធ្វើសមាហរណកម្មក្នុង BSP របស់រដ្ឋបាលរាជធានីខេត្ត • រដ្ឋបាលរាជធានីខេត្តរៀបចំនិងចរចារគម្រោងថវិកាតាមកម្មវិធី ដោយគោរពតាម MTBF របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
	ធនធានហិរញ្ញវត្ថុត្រូវបានធ្វើវិមជ្ឈការជូនរដ្ឋបាលថ្នាក់ក្រោមជាតិ÷ • ប្រភេទចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធបន្ថែមទៀត ត្រូវបានកំណត់សម្រាប់ជាគុណប្រយោជន៍នៃថវិការដ្ឋបាល ថ្នាក់ក្រោមជាតិ • កំណើននៃ % ការផ្ទេរធនធានថវិការដ្ឋទៅក្នុងមូលនិធិក្រុង ស្រុក និងឃុំ សង្កាត់ • មានធនធានហិរញ្ញវត្ថុសមស្របសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
	ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អ÷ • យន្តការនិងបទដ្ឋានគតិយុត្តក្នុងការត្រួតពិនិត្យការអនុវត្តថវិកាការផ្ទេរមុខងារ និងការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើបច្ចុប្បន្នភាព • មុខងារនិងនីតិវិធីសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត ត្រូវបានរៀបចំនិងអនុវត្តនៅតាមរដ្ឋបាលរាជធានី ខេត្ត

៥.៤. ផ្នែកទី៤ "ការកសាងគណនេយ្យភាពសមិទ្ធកម្ម"

ការកសាងគណនេយ្យភាពសមិទ្ធកម្ម មានគោលបំណងរៀបចំ និងដាក់ឱ្យដំណើរការនូវសមាសធាតុនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មជាបណ្តើរៗ ដើម្បីកែលម្អការគ្រប់គ្រង, ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងគណនេយ្យភាព។

លទ្ធផលផ្នែកទី៤នេះ គឺត្រូវសម្រេចឱ្យបាននូវការបញ្ចប់ការរៀបចំបទដ្ឋានគតិយុត្តសំខាន់ៗ អំពីវិធាននិងនីតិវិធីនៃដំណើរការប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម និងការធ្វើវិមជ្ឈការសិទ្ធិអំណាចក្នុងការអនុវត្តថវិកាជូនដល់អង្គភាពថវិកាដែលមានលក្ខណៈសម្បត្តិសមស្រប ព្រមទាំងការពង្រឹងគណនេយ្យភាពតាមរយៈការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម, ការលើកកម្ពស់តម្លាភាពថវិកា និងការកែលម្អប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្ទៃក្រៅ។

ផ្នែកទី៤នេះ ជំរុញការកែទម្រង់ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៣ រួមមាន÷ (១) ការដាក់ឱ្យអនុវត្តវិធាននិងនីតិវិធីនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម, (២) ការកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យអធិការកិច្ច និងសវនកម្ម, និង (៣) ការលើកកម្ពស់តម្លាភាពថវិកា។

ក្នុងក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ បានកំណត់ក្របខ័ណ្ឌ, វិធីសាស្ត្រ, យន្តការ និងនីតិវិធីនៃការតាមដាននិងវាយតម្លៃការអនុវត្តថវិកា។ ក្នុងនោះ អង្គភាពសាធារណៈទាំងអស់ ត្រូវរៀបចំគម្រោងថវិកានិងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ដែលឯកសារទាំងនេះ ជាកម្មវត្ថុនៃការពិនិត្យអនុលោមភាពនិងការផ្តល់អនុសាសន៍កែលម្អដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

លើមូលដ្ឋាននេះ, CAP4 ជំរុញការរៀបចំបញ្ចប់នូវលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការរៀបចំរបាយការណ៍ និងការត្រួតពិនិត្យតាមដាននិងវាយតម្លៃថវិកាសមិទ្ធកម្ម ព្រមទាំងរៀបចំយន្តការសម្រាប់អនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម (Performance Agreement)។ ជាមួយគ្នានេះ CAP4 ពង្រឹងការអនុវត្តមុខងារអធិការកិច្ចហិរញ្ញវត្ថុនិងសវនកម្មផ្ទៃក្នុង ព្រមទាំងលើកកម្ពស់ការរៀបចំនិងផ្សព្វផ្សាយឯកសារថវិកា ដើម្បីធានានូវតម្លាភាពនិងគណនេយ្យភាពចំពោះអង្គនីតិប្បញ្ញត្តិ និងសាធារណជន។

តារាង ៥.៤. ក្របខ័ណ្ឌលទ្ធផលឆ្នាំ២០២៧ សម្រាប់ផ្នែកទី៤

"ការកសាងគណនេយ្យភាពសមិទ្ធកម្ម"

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
ផ្នែកទី៤ ÷ ការសាងគណនេយ្យភាពសមិទ្ធកម្ម ការដាក់ឱ្យអនុវត្ត "ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម" និង ធានានូវគណនេយ្យសមិទ្ធកម្មនៅក្នុងវដ្តថវិកា ទាំងចំពោះអង្គនីតិប្បញ្ញត្តិនិងសាធារណជន	
(១) ការរៀបចំវិធាននិងនីតិវិធីនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម	ក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត÷ • លិខិតបទដ្ឋានគតិយុត្ត (ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី, អនុក្រឹត្យ ៨១ និង ៨២, ប្រកាសស្តីពីអង្គភាពត្រួតពិនិត្យថវិកាអមក្រសួង ស្ថាប័ន) សម្រាប់អនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម • កិច្ចព្រមព្រៀងសមិទ្ធកម្មត្រូវបានអនុវត្ត ត្រួតពិនិត្យនិងរាយការណ៍
	ប្រព័ន្ធតាមដាននិងវាយតម្លៃសមិទ្ធកម្មត្រូវបានដាក់ឱ្យអនុវត្ត÷ • គ្រប់ក្រសួង ស្ថាប័នរៀបចំនិងអនុវត្តកម្មវិធីចំណូល-ចំណាយផ្សារភ្ជាប់ទៅនឹងព័ត៌មានសមិទ្ធកម្ម • គ្រប់ក្រសួង ស្ថាប័នរៀបចំរបាយការណ៍សមិទ្ធកម្ម និងហិរញ្ញវត្ថុប្រចាំឆមាសទី១ និងប្រចាំឆ្នាំ តាមកម្មវិធី និងអនុកម្មវិធី
(២) ការកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យ	គ្រប់ក្រសួង ស្ថាប័នបានកំណត់ក្របខ័ណ្ឌ, វិធាន, តួនាទីនិងភារកិច្ចលើការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង
	គ្រប់ក្រសួង ស្ថាប័នធ្វើសវនកម្មសមិទ្ធកម្មនិងរៀបចំរបាយការណ៍ជាប្រចាំឆ្នាំ
	គ្រប់ក្រសួង ស្ថាប័នធ្វើសវនកម្មបច្ចេកវិទ្យាព័ត៌មាននិងរៀបចំរបាយការណ៍ជាប្រចាំឆ្នាំ
	អាជ្ញាធរសវនកម្មជាតិបញ្ជូនរបាយការណ៍វាយតម្លៃចំនួន ៥ ក្នុងមួយឆ្នាំ ជូនអង្គនីតិប្បញ្ញត្តិពិនិត្យ
(៣) ការលើកកម្ពស់តម្លាភាពថវិកា	សូចនាករ PEFA ស្តីពីតម្លាភាពថវិកាត្រូវបានកើនពិន្ទុ • សូចនាករចំណាត់ថ្នាក់ថវិកាទទួលពិន្ទុ (PI-4) C ទៅ B • សូចនាកររបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល (PI-6.3) ទទួលពិន្ទុ D ទៅ B • សូចនាករព័ត៌មានសមិទ្ធកម្មសម្រាប់ការផ្តល់សេវាសាធារណៈ (PI-8) ទទួលពិន្ទុ C ទៅ B

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
	សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវបានផ្សព្វផ្សាយ បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា និងបន្ទាប់ពីត្រូវបានអនុម័ត
	សេចក្តីព្រាងច្បាប់ទូទាត់ត្រូវបានផ្សព្វផ្សាយ បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា និងបន្ទាប់ពីត្រូវបានអនុម័ត
	ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំវេទិកាសាធារណៈស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាប្រចាំឆ្នាំ
	ក្រសួង ស្ថាប័នស្ថិតក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចរៀបចំសៀវភៅថវិកាប្រជាពលរដ្ឋ និងរៀបចំវេទិកាសាធារណៈស្តីពីថវិការបស់ស្ថាប័នសាមីប្រចាំឆ្នាំ

៥.៥. ផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងតាមប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត"

សកម្មភាពកែទម្រង់ក្នុងផ្នែកទី៥នេះ មានគោលបំណងពង្រឹងការអនុវត្តយន្តការលើកទឹកចិត្តនិងគ្រប់គ្រងសមិទ្ធកម្មការងារកែទម្រង់របស់អង្គភាពអនុវត្ត ដើម្បីបណ្តុះភាពជាម្ចាស់និងអភិវឌ្ឍសមត្ថភាព ក្នុងការដឹកនាំនិងអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពង្រឹងយន្តការសម្របសម្រួលរវាងការដ្ឋានកែទម្រង់ដទៃទៀត។

លទ្ធផលផ្នែកទី៥នេះ គឺត្រូវពង្រឹងភាពជាអ្នកដឹកនាំ ភាពជាម្ចាស់ និងសមត្ថភាពរបស់អង្គភាពសាធារណៈ ក្នុងការគ្រប់គ្រង កំណត់ និងអនុវត្តសកម្មភាពកែទម្រង់ ស្របតាមចក្ខុវិស័យនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីរក្សាចលនការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងភាពប្រទាក់ក្រឡាជាមួយនឹងគ្រប់ការដ្ឋានកែទម្រង់ពាក់ព័ន្ធ។

ផ្នែកនេះជំរុញការកែទម្រង់ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៤ រួមមាន÷ (១) ការលើកកម្ពស់ភាពជាអ្នកដឹកនាំនិងសមត្ថភាពរបស់អង្គភាពសាធារណៈ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) ការធានាចលនការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (៣) ការសម្រប-សម្រួលកម្មវិធីកែទម្រង់ ៣ប្លុក១ របស់រាជរដ្ឋាភិបាល និង (៤) ការបង្កើនសមិទ្ធកម្មការងាររបស់មន្ត្រីសាធារណៈ។

CAP4 ផ្តោតលើការពង្រឹងអនុលោមភាពនៃការអនុវត្តសារាចរ ០៩ របស់រាជរដ្ឋាភិបាល ដោយបន្តកែលម្អការរៀបចំនិងអនុវត្តផែនការសកម្មភាពកែទម្រង់ និងជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងគណនេយ្យ-

ភាពនិងសមិទ្ធកម្ម (Performance Management and Accountability System; PMAS) សម្រាប់សម្រួលដល់ការរៀបចំផែនការសកម្មភាពនិងរបាយការណ៍សមិទ្ធកម្ម។ ម្យ៉ាងវិញទៀត, CAP4 ក៏នឹងផ្តោតទៅលើការបង្កើនកិច្ចសម្របសម្រួលជាមួយកម្មវិធីកែទម្រង់ពាក់ព័ន្ធ ដើម្បីកំណត់ចក្ខុវិស័យនិងផែនការសកម្មភាពកែទម្រង់រួម ពិសេសលើការជំរុញវិមជ្ឈការហិរញ្ញវត្ថុ, ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងលក្ខខណ្ឌ-យោងការងារមន្ត្រីសាធារណៈទូទាំងប្រទេសសម្រាប់អនុវត្តការពិនិត្យសមិទ្ធកម្មការងារ, ការផ្តល់ការលើក-ទឹកចិត្ត និងការអភិវឌ្ឍគុណវុឌ្ឍិរបស់មន្ត្រី។

តារាង ៥.៥. ក្របខ័ណ្ឌលទ្ធផលឆ្នាំ២០២៧ សម្រាប់ផ្នែកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត"

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
ផ្នែកទី៥ ÷ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត ការរក្សាចលនការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈប្រកបដោយចីរភាព និងការបង្កើនភាពប្រទាក់ក្រឡាគ្នានឹងការកែទម្រង់ផ្សេងទៀត (៣+១)	
(១) ការលើកកម្ពស់ភាពជាអ្នកដឹកនាំនិងសមត្ថភាព របស់អង្គភាពក្នុងការអនុវត្តកម្មវិធីកែទម្រង់	គ្រប់ក្រសួង ស្ថាប័ននិងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំរៀបចំកិច្ចប្រជុំលើការងារកែទម្រង់ជាទៀងទាត់
	គ្រប់ក្រសួងស្ថាប័នរៀបចំនិងផ្តល់ផែនការសកម្មភាព និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសនិងឆ្នាំទាន់ពេលវេលា
	គ្រប់មន្ត្រីក្នុងមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានគុណវុឌ្ឍិសមស្របនឹងមុខតំណែង
(២) ការធានាចលនការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	មូលនិធិកែទម្រង់ដំណាក់កាលទី២ ត្រូវបានអនុម័តនិងអនុវត្តពេញលេញ
	ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មនិងគណនេយ្យភាព (PMAS) ត្រូវបានដាក់ឱ្យដំណើរការ
(៣) ការសម្របសម្រួលកម្មវិធីកែទម្រង់ពាបួក១	ផែនការសកម្មភាពរួមប្រចាំឆ្នាំ និងត្រូវបានរៀបចំ តាមដាន និងត្រួតពិនិត្យ វាយតម្លៃ ជាទៀងទាត់
	គ្រប់ក្រសួង ស្ថាប័នរៀបចំនិងអនុវត្តលក្ខខណ្ឌយោងការងាររបស់មន្ត្រី
	គ្រប់ក្រសួង ស្ថាប័នធ្វើការត្រួតពិនិត្យសមិទ្ធកម្មការងាររបស់មន្ត្រី

លទ្ធផលចុងក្រោយ	សូចនាករនិងគោលដៅឆ្នាំ២០២៧
(៤) ការកែលម្អ សមិទ្ធកម្មការងាររបស់មន្ត្រីរាជរដ្ឋាភិបាល	គ្រប់ក្រសួង ស្ថាប័នរៀបចំនិងអនុវត្តក្របខ័ណ្ឌគ្រប់គ្រងការប្រើប្រាស់ប្រាក់រង្វាន់ ដោយផ្សារភ្ជាប់ទៅនឹងសមិទ្ធកម្មការងារមន្ត្រីរបស់អង្គភាពសាមី

៦. រចនាសម្ព័ន្ធទ្រទ្រង់សម្រាប់ដំណាក់កាលទី៤

ដើម្បីធានាការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4) ទទួលបានលទ្ធផលតាមការរំពឹងទុក, រាជរដ្ឋាភិបាលបានកំណត់រចនាសម្ព័ន្ធទ្រទ្រង់ ចំនួន ៥ រួមមាន÷ (១) យន្តការស្ថាប័ន, (២) សមត្ថភាពស្ថាប័ន, (៣) ធនធានហិរញ្ញវត្ថុ, (៤) វិធានការដោះស្រាយបញ្ហាប្រឈម និង (៥) វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។

៦.១. យន្តការស្ថាប័ន

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលទី៤ ត្រូវបានគាំទ្រនិងអនុវត្តដោយយន្តការស្ថាប័នរួមមាន÷ (១) គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**), (២) គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.ក.ហ.**), (៣) ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ប្រចាំក្រសួងស្ថាប័ន, (៤) ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ប្រចាំរដ្ឋបាលរាជធានី ខេត្ត, (៥) អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**), (៦) យន្តការអន្តរកែទម្រង់ និង (៧) យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។ យន្តការស្ថាប័នទាំងនេះ មានបង្ហាញដូចខាងក្រោម÷

៦.១.១. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ (ឧបសម្ព័ន្ធទី១)។ តាមរយៈសេចក្តីសម្រេចលេខ២០ សសរ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, **គ.ហ.ស.** មានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន, រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ជាអនុ-

ប្រធាន, ព្រមទាំងថ្នាក់ដឹកនាំមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសមាជិក។ **គ.ហ.ស.** បំពេញភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។ យោងតាមសារាចររាជរដ្ឋាភិបាលលេខ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, **គ.ហ.ស.** មានកិច្ចប្រជុំប្រចាំត្រីមាសនិងប្រចាំឆ្នាំ ដែលជាវេទិកាកម្រិតនយោបាយ ក្នុងការត្រួតពិនិត្យតាមដានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ននីមួយៗ។

៦.១.២. គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

តាមរយៈប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ (ឧបសម្ព័ន្ធទី៦), ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាស្ថាប័នស្នូលក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា បានបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ក.ហ.**)។ តាមរយៈសេចក្តីសម្រេចលេខ ០៣៦ សហវ.សសរ.អគហ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ឧបសម្ព័ន្ធទី៨), **គ.ក.ហ.** ស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានសមាសភាពពីថ្នាក់ដឹកនាំក្រសួងនិងប្រធាននៃគ្រប់អង្គភាពក្រោមឱវាទក្រសួងជាអនុប្រធាន និងជាសមាជិក។ **គ.ក.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ **គ.ក.ហ.** ជាស្ថាប័នកម្រិតបច្ចេកទេស ដែលដើរតួជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនត្រឹមតែក្នុងការពិនិត្យសម្រេចលើចក្ខុវិស័យ គោលបំណង កម្មវិធី ផែនការសកម្មភាព និងការរៀបចំនិងតាមដានការអនុវត្តផែនការសកម្មភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាអ្នកសម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តទៀតផង។ ទន្ទឹមនេះ, **គ.ក.ហ.** ក៏ជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការកៀរគរជំនួយនិងការសម្របសម្រួល ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍នានា។

លើសពីនេះ, **គ.ក.ហ.** ក៏ជាគណៈកម្មការដឹកនាំផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ ដែលក្នុងនោះ **គ.ក.ហ.** ត្រូតពិនិត្យលើការងារកែទម្រង់របស់ក្រុមការងារកែទម្រង់២ គឺ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំអគ្គនាយកដ្ឋាននិងអង្គភាពក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្នាក់កណ្តាល និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំអគ្គនាយកដ្ឋាននិងអង្គភាពក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្នាក់កណ្តាល

អនុលោមតាមមាត្រា៣ នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គ្រប់ក្រសួង ស្ថាប័ននិងអង្គភាពដែលមានការពាក់ព័ន្ធនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**)។ ដោយឡែក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាន **ក.ហ.ស.** ច្រើន ដែល **ក.ហ.ស.** ទាំងអស់នោះ ត្រូវបានបង្កើតឡើងនៅតាមអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន, អគ្គាធិការដ្ឋាន, ក្រុមប្រឹក្សានីតិកម្ម, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអង្គភាពថ្នាក់កណ្តាលផ្សេងទៀត។ **ក.ហ.ស.** ទាំងនេះ ជាក្រុមការងារបច្ចេកទេសដែលមានភារកិច្ចដឹកនាំ និងសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំអង្គភាពរបស់ខ្លួន ដោយរៀបចំផែនការសកម្មភាពលម្អិតដែលចុះហត្ថលេខាទទួលស្គាល់ដោយប្រធានអង្គភាព ឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម (CAP) ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**)។

ខ. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុលោមតាមសារាចររាជរដ្ឋាភិបាលលេខ០៤ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ឧបសម្ព័ន្ធទី៥) ដែលបើកផ្លូវឱ្យអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិបង្កើត **ក.ហ.ស.** និងដោយយោងលើភាពចាំបាច់, **ក.ហ.ស.** ប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងក្នុងគោលបំណងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព។ ក្នុងនោះ **ក.ហ.ស.** ប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំជាផែនការសកម្មភាពលម្អិត ឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួមដែលរៀបចំឡើងដោយ **អ.គ.ហ**។

៦.១.៣. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមាន **ក.ហ.ស.** មួយប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ដែលត្រូវបានដឹកនាំដោយផ្ទាល់ពីតំណាងនៃក្រសួង ស្ថាប័ន ០១រូប ដែលជាសមាជិក **គ.ហ.ស.** ហើយដែលត្រូវជារដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការឬថ្នាក់ដឹកនាំមួយរូប ដែលទទួលបន្ទុកជួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន។ **ក.ហ.ស.** ជាក្រុមការងារបច្ចេកទេស ដែលមានភារកិច្ចដឹកនាំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ព្រមទាំងជាអ្នកសម្របសម្រួលរៀបចំនិងកែតម្រូវផែនការសកម្មភាពលម្អិតប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម។

៦.១.៤. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំរដ្ឋបាលរាជធានី ខេត្ត

ដោយសារតែការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលនេះ មានគណនេយ្យភាពសមិទ្ធកម្មជាស្នូល ហើយដែលសមិទ្ធកម្មនោះមិនសំដៅដល់ត្រឹមតែជាសមិទ្ធកម្មរបស់មន្ត្រីនិងស្ថាប័នទៅថ្នាក់ជាតិនោះ, **ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត នឹងត្រូវបានបង្កើតឡើង ក្នុងគោលបំណងពង្រឹងការទទួលខុសត្រូវលើសមិទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **ក.ហ.ស.** ជាក្រុមការងារបច្ចេកទេស ដែលមានភារកិច្ចដឹកនាំនិងអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន ព្រមទាំងជាអ្នកសម្របសម្រួលរៀបចំនិងកែតម្រូវផែនការសកម្មភាពលម្អិតប្រចាំរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួនឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម។

ថ្នាក់ដឹកនាំ **ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត នឹងត្រូវជាសមាជិក **គ.ហ.ស.** ហើយដែលថ្នាក់ដឹកនាំនោះអាចជាអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬ ជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត។

៦.១.៥. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អនុលោមតាមអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ឧបសម្ព័ន្ធទី២), អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ត្រូវបានបង្កើតឡើងដើម្បីជាសេនាធិការឱ្យ **គ.ហ.ស.**។ ក្នុងការបំពេញមុខងាររបស់ខ្លួន, **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** រួមទាំងការរៀបចំដាក់ឱ្យអនុវត្តនិងការតាមដាន

ត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **អ.គ.ហ.** ក៏មានតួនាទីស្នូលក្នុងការជំរុញការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ស្ថាប័ន និង ប្រចាំរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ, **អ.គ.ហ.** ក៏ជាសេនាធិការឱ្យ **គ.ក.ហ.** ក្នុងការសហការនិងសម្របសម្រួលជាមួយ **ក.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាជំនួយដល់ការរៀបចំផែនការសកម្មភាពលម្អិត និងតាមដានការអនុវត្តការកែទម្រង់របស់ **ក.ហ.ស.** ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៦.១.៦. យន្តការអន្តរកែទម្រង់

យន្តការអន្តរកែទម្រង់ សំដៅដល់កម្មវិធីកែទម្រង់ ៣បូក១។ កម្មវិធីកែទម្រង់ ៣បូក១ ជាកម្មវិធីកែទម្រង់ ដែលសំដៅមិនត្រឹមតែកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ តែជាកម្មវិធីដែលមានលក្ខណៈប្រទាក់ក្រឡា ជាមួយកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងនោះមានកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ យន្តការអន្តរកែទម្រង់ ឬហៅម្យ៉ាងទៀតថា យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល ឬហៅកាត់ថា **យ.ស.ក.** ត្រូវបានប្រកាសដាក់ឱ្យអនុវត្តតាមរយៈអនុក្រឹត្យលេខ២៤១ អនក្រ.បក. ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្រប-សម្រួលការកែទម្រង់ ៣បូក១ នៃរាជរដ្ឋាភិបាល ដែលមានវិសាលភាពអនុវត្ត ចំពោះការកែទម្រង់ទាំងអស់របស់រាជរដ្ឋាភិបាលដែលមានទំនាក់ទំនងជាមួយនឹង កម្មវិធីកែទម្រង់ទាំង៤ នេះ (ឧបសម្ព័ន្ធទី៣)។

កម្មវិធីកែទម្រង់ ៣បូក១ ខាងលើ គឺស្ថិតនៅក្រោមសមត្ថកិច្ចដាច់ដោយឡែកៗ នៅតាមក្រសួងនីមួយៗ។ ក្នុងនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដឹកនាំសម្របសម្រួលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួងមហាផ្ទៃដឹកនាំសម្របសម្រួលកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ក្រសួងមុខងារសាធារណៈដឹកនាំសម្របសម្រួលកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងយុត្តិធម៌ដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ទំនាក់ទំនងនៃកម្មវិធីកែទម្រង់ទាំងនេះ អាចមើលឃើញក្រោមរូបភាពប្រទាក់ក្រឡា រវាងមុខងារ, ហិរញ្ញវត្ថុ, ធនធានមនុស្ស និងទិដ្ឋភាពច្បាប់និងប្រព័ន្ធយុត្តិធម៌។

យ.ស.ក. ជាយន្តការដឹកនាំនិងសម្របសម្រួលផ្លាស់វេនប្រចាំត្រីមាសរវាង **អ.គ.ហ.**, លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**),

លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.ក.រ.**) និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (**គ.ជ.ច្រ.**)។ **យ.ស.ក.** មានជាផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ និងមានរបបប្រជុំប្រចាំត្រីមាសដែលដឹកនាំដោយប្រធានផ្លាស់វេន។

៦.១.៧. យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

ដើម្បីឱ្យការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដើរស្របជាមួយនឹងគតិមានុវត្តន៍អន្តរជាតិ, ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ប.ហ.**) ឬជាភាសាអង់គ្លេស Public Financial Management Technical Working Group (PFM-TWG) ត្រូវបានបង្កើតឡើង ក្នុងគោលបំណងធ្វើជាយន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ **ក.ប.ហ.** មានសមាសភាពមកពី **គ.ហ.ស.** ដែលតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការដៃគូអភិវឌ្ឍន៍ (Development Partner Committee; DPC) ដែលតំណាងឱ្យដៃគូអភិវឌ្ឍន៍។ DPC ផ្តល់អនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4) និងផ្តល់អនុសាសន៍ លើរបាយការណ៍តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក.ប.ហ. មានរបបប្រជុំប្រចាំត្រីមាសនិងប្រចាំឆ្នាំ ដែលត្រូវដឹកនាំដោយប្រធាន **គ.ហ.ស.** និងរួមមានការចូលរួមពីតំណាងដៃគូអភិវឌ្ឍន៍។ កិច្ចប្រជុំនេះ ធ្វើឡើងក្នុងគោលបំណងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។

៦.២. សមត្ថភាពស្ថាប័ន

នៅក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមត្ថភាពស្ថាប័នជាសមាសធាតុសំខាន់ក្នុងការសម្រេចបានន្ូវគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់គឺ “គណនេយ្យភាពសមិទ្ធកម្ម”។ សមត្ថភាពស្ថាប័ន សំដៅលើភាពជាអ្នកដឹកនាំ ភាពជាម្ចាស់ ឆន្ទៈ និងសមត្ថភាពជំនាញបច្ចេកទេស ក្នុងការចូលរួម និងគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ ប្រកបដោយភាពជោគជ័យ និងចីរភាព។

ក្នុងដំណាក់កាលទី៣កន្លងមក, ក្រសួង ស្ថាប័នប្រមាណ ៥% ដែលមានសមាសភាពប្រធានក្រុមការងារកែទម្រង់ ជាប្រធានស្ថាប័ន បានជំរុញឱ្យការចូលរួមការងារកែទម្រង់មានភាពល្អប្រសើរ ទាំងសមិទ្ធផលការងារនិងភាពទាន់ពេលវេលានៃការធ្វើផែនការសកម្មភាពនិងរបាយការណ៍វឌ្ឍនភាព។ ចំពោះក្រសួង ស្ថាប័នប្រមាណជាង ៦០% ដែលមានប្រធានក្រុមការងារជារដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការ, វឌ្ឍនភាពការងារ

ស្ថិតក្នុងកម្រិតល្អទៅល្អប្រសើរលើភាពទាន់ពេលវេលានៃការផ្ទេរបាយការណ៍ និងការចូលរួមផ្សេងៗ។ ក្រសួង ស្ថាប័នប្រមាណ ៣០% ទៀត ដែលមានសមាសភាពប្រធានក្រុមការងារកែទម្រង់ ត្រឹមជា អគ្គលេខាធិការ/ អគ្គនាយក/អគ្គនាយករងឬតំណែងប្រហាក់ប្រហែល មានវឌ្ឍនភាពការងារនិងការចូលរួមផ្សេងៗនៅក្នុង កម្រិតមធ្យមទៅល្អ។

ទិដ្ឋភាពនេះបានបង្ហាញថា កម្រិតថ្នាក់ដឹកនាំចូលរួមកាន់តែខ្ពស់ ឆ្លុះបញ្ចាំងពីឆន្ទៈកែទម្រង់ និង ការយកចិត្តទុកដាក់របស់ក្រសួង ស្ថាប័ន កាន់តែខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ, យន្តការផ្តល់ប្រាក់ឧបត្ថម្ភ លើកទឹកចិត្តជូនក្រុមការងារកែទម្រង់ ក៏បានចូលរួមចំណែកក្នុងការធ្វើឱ្យមានភាពកាន់តែល្អប្រសើរនៃសមិទ្ធកម្ម ការងារផងដែរ។ នៅក្នុងរយៈពេល៣ឆ្នាំចុងក្រោយ, ពោលពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២, ការផ្តល់ប្រាក់ឧបត្ថម្ភ លើកទឹកចិត្តបានកើនឡើងជារួមប្រមាណ ២០% ធៀបជាមួយនឹងឆ្នាំកន្លងមក ដែលក្នុងនោះ ចំនួនក្រុមការងារ កែទម្រង់ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភបានកើនឡើងបន្ថែមដល់ ១៣២ នាក់នៅឆ្នាំ២០២២។ ខណៈដែល ការលើកទឹកចិត្តត្រូវបានបង្កើន សមិទ្ធផលការងារនិងការចូលរួមនានាពីក្រុមការងារកែទម្រង់ក្នុងរយៈពេល ដូចគ្នា ក៏មានភាពរលូននិងល្អប្រសើរគួរឱ្យកត់សម្គាល់ផងដែរ។ ក្នុងន័យនេះ, ឆន្ទៈជំរុញការងារពីថ្នាក់ដឹកនាំ ជាកត្តាសំខាន់មិនអាចខ្វះបាន, តែការលើកទឹកចិត្តដល់ក្រុមការងារ ទាំងផ្នែកហិរញ្ញវត្ថុ (ឧទាហរណ៍÷ ការផ្តល់ ប្រាក់ឧបត្ថម្ភបន្ថែម) និងមិនមែនហិរញ្ញវត្ថុ (ឧទាហរណ៍÷ ការផ្តល់មុខតំណែងការងារខ្ពស់ជាងមុន) ក្នុងការ អនុវត្តការងារកែទម្រង់ក៏ជាកត្តាសំខាន់ផងដែរ។

ស្របជាមួយនឹងឆន្ទៈ ភាពជាម្ចាស់ និងភាពជាដឹកនាំ, សមត្ថភាពនៃការយល់ដឹងពីជំនាញ បច្ចេកទេសនិងជំនាញទន់របស់មន្ត្រីសាធារណៈនៃក្រសួង ស្ថាប័ន ជាការគាំទ្រសំខាន់ដល់ការអនុវត្តកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្ពោះទៅរកភាពជោគជ័យ និងនិរន្តរភាពការងារ។ ដូចនេះ “ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍន៍សមត្ថភាព” ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងនិងកសាងសមត្ថភាព ជូនថ្នាក់ដឹកនាំនិងមន្ត្រីកែទម្រង់ តាមរយៈការកំណត់នូវមុខជំនាញបណ្តុះបណ្តាលសំខាន់ៗ សម្រាប់ធានា ប្រសិទ្ធភាពអនុវត្តការងារ ដូចជា ជំនាញថវិកាសមិទ្ធកម្ម, លទ្ធកម្មសាធារណៈ, ព្យាករណ៍ចំណូល និង គ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងជំនាញទន់ផ្សេងៗ ពាក់ព័ន្ធនឹងការបណ្តុះឆន្ទៈ ភាពជាម្ចាស់ ភាព ជាអ្នកដឹកនាំ។ល។ ផែនការយុទ្ធសាស្ត្រនេះ ក៏បានកំណត់ទិសដៅរៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល ដើម្បីទំនើបកម្មការរៀបចំវគ្គបណ្តុះបណ្តាល និងពង្រឹងការអភិវឌ្ឍធនធានមនុស្សស្របតាមសម័យកាលបដិវត្ត ឧស្សាហកម្មឌីជីថល។ ក្រៅពីផែនការយុទ្ធសាស្ត្រនេះ, មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័ន ត្រូវបានគិតគូរកំណត់ក្របខ័ណ្ឌមុខតំណែងការងារហិរញ្ញវត្ថុនិងគុណវុឌ្ឍិច្បាស់លាស់ តាមរយៈការដាក់ចេញ

អនុក្រឹត្យកំណត់លក្ខខណ្ឌតែងតាំងផ្សេងៗ មុននឹងចូលទៅកាន់មុខតំណែងការងារហិរញ្ញវត្ថុណាមួយ នៅក្នុងក្រសួង ស្ថាប័ន។

ជាទិសដៅទៅមុខ, សមត្ថភាពស្ថាប័នទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបន្តពង្រឹង និងគិតគូរបន្ថែមពីលើវឌ្ឍនភាពដែលមាននាពេលបច្ចុប្បន្ន។

ការបន្តជំរុញភាពជាម្ចាស់ និងឆន្ទៈនៃការចូលរួមកម្មវិធីកែទម្រង់÷

- ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ចាំបាច់ត្រូវត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មការងារនិងការចូលរួមកន្លងមករបស់ក្រុមការងារកែទម្រង់របស់ខ្លួន និងពិចារណាពិនិត្យលទ្ធភាពជំរុញក្រុមការងារ ដូចខាងក្រោម÷

  (១) រៀបចំចាត់តាំងរចនាសម្ព័ន្ធក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានការចូលរួមពីប្រធានស្ថាប័ន។

  (២) ផ្តល់យន្តការលើកទឹកចិត្ត ជាប្រាក់ឧបត្ថម្ភ ជាការបណ្តុះបណ្តាល ឬ ផ្តល់កាលានុវត្តភាពណាមួយជូនក្រុមការងារកែទម្រង់របស់ខ្លួន បន្ថែមពីលើប្រាក់ឧបត្ថម្ភដែលផ្តល់ដោយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

  (៣) គួរផ្តល់អាទិភាពខ្ពស់ ដល់មន្ត្រីបង្គោល ក្នុងការចាត់តាំងចូលរួមកិច្ចប្រជុំពាក់ព័ន្ធ វគ្គ-បណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស និងសកម្មភាពការងារផ្សេងៗដែលទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- ការជ្រើសរើសសមាសភាពក្រុមការងារកែទម្រង់ ជាពិសេសមន្ត្រីបង្គោល គួរផ្អែកលើជំនាញ វិជ្ជាជីវៈ និងបទពិសោធន៍។ ជាមួយគ្នានេះ, ក្រុមការងារកែទម្រង់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត គួរមានសមាសភាពពីអង្គភាពជំនាញពាក់ព័ន្ធ ដូចជា អង្គភាពរដ្ឋបាលហិរញ្ញវត្ថុ អង្គភាពលទ្ធកម្ម សវនកម្ម ទ្រព្យសម្បត្តិរដ្ឋ។ល។

ការបន្តពង្រឹងការរៀបចំក្របខ័ណ្ឌកសាងសមត្ថភាពធនធានមនុស្ស÷

- ខណៈដែលសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រី ក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវបានពង្រឹងតាមរយៈការបណ្តុះបណ្តាលជាបន្តបន្ទាប់, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការកសាងសមត្ថភាពនៅក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃឱ្យបានច្បាស់លាស់ អំពីសមត្ថភាពក្នុងការអនុវត្តការងាររបស់មន្ត្រី

សាធារណៈ និងវាស់ស្ទង់ពីឆន្ទៈនៃការចូលរួមការងារកែទម្រង់ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ។ ក្នុងន័យនេះ វិទ្យាស្ថាននឹងអាចវាយតម្លៃសមត្ថភាពធនធានមនុស្សជាក់លាក់ ដើម្បីកំណត់ជាទិសដៅ តម្រូវការបណ្តុះបណ្តាល និងការរៀបចំគតិយុត្តដែលចាំបាច់នានានៅថ្ងៃមុខ។

- ក្រៅពីការគិតគូរពង្រឹងសមត្ថភាពថ្នាក់ដឹកនាំនិងមន្ត្រីកែទម្រង់នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត, សមត្ថភាពថ្នាក់ដឹកនាំនិងមន្ត្រីនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ក៏ចាំបាច់ត្រូវពង្រឹងផងដែរ ដោយប្រើប្រាស់ក្របខ័ណ្ឌបណ្តុះបណ្តាលមួយសមស្រប។
- អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជានិម្មាបនករនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវចូលរួមចែករំលែកចំណេះដឹងនិងបទពិសោធន៍អនុវត្តការងារហិរញ្ញវត្ថុជូនក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។ ការងារនេះ ត្រូវរៀបចំជាយន្តការប្រឹក្សាយោបល់ និងវេទិកាចែករំលែកបទពិសោធន៍នានាជូនក្រសួង ស្ថាប័ន ដូចបានកំណត់នៅក្នុងផ្នែកទី៣ នៃ CAP4។

ការរៀបចំក្របខ័ណ្ឌការងារបច្ចុប្បន្ននិងទិសដៅការងារបន្ត ត្រូវបានរំពឹងថាសមត្ថភាពស្ថាប័ននៅក្នុងក្របខ័ណ្ឌការងារកែទម្រង់នឹងមានការអភិវឌ្ឍថែមមួយកម្រិតទៀត ទាំងសមត្ថភាពបច្ចេកទេស វិជ្ជាជីវៈ ឆន្ទៈ ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់។

៦.៣. ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលនីមួយៗ បានមកពីថវិការបស់រាជរដ្ឋាភិបាល និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។ ការអនុវត្តថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុលោមតាមគោលការណ៍ណែនាំបន្ថែមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលឯកសារនេះផ្អែកលើគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីរួម សម្រាប់ការគ្រប់គ្រង ការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ដែលអនុម័តដោយរាជរដ្ឋាភិបាល។ គោលការណ៍ណែនាំបន្ថែមនេះ ត្រូវបានប្រើប្រាស់សម្រាប់គ្រប់អង្គភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។ **អ.គ.ហ.** ក្នុងនាមជាសេនាធិការរបស់ **គ.ហ.ស.** ដើរតួនាទីសំខាន់ ជាអង្គភាពប្រតិបត្តិគម្រោង ដើម្បីទទួលបន្ទុកសម្របសម្រួលគ្រប់គ្រងប្រភពហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងដើម្បីធានាបានអនុលោមភាពនៃការងារទូទៅ ដែលពាក់ព័ន្ធរដ្ឋបាល ហិរញ្ញវត្ថុ និងលទ្ធកម្ម។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំង៣ដំណាក់កាល ពីឆ្នាំ២០០៤ ដល់ ឆ្នាំ ២០២២ បានប្រើប្រាស់ថវិកាសរុបទាំងអស់ប្រមាណ **៣៤៦ ៩៥២ លានរៀល** ឬសមមូលទៅនឹងប្រមាណ **៨៥,៦៧ លានដុល្លារអាមេរិក** និងគាំទ្រដោយថវិកាជាច្រើនប្រភពផ្សេងគ្នា រួមមាន (១) ថវិការាជរដ្ឋាភិបាល, (២) ថវិកាដៃគូជាច្រើនប្រភព (Multi-Donor Trust Fund), (៣) ហិរញ្ញប្បទានឥតសំណងពីសហភាព អឺរ៉ុប, (៤) ឥណទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង (៥) អង្គការ UNICEF។ ក្នុងនោះ ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានប្រើប្រាស់ថវិកាអស់ប្រមាណ **១៩១ ១៩២ លានរៀល** ឬសមមូល ទៅនឹងប្រមាណ **៤៧,២១ លានដុល្លារអាមេរិក**, អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាន ប្រើប្រាស់ថវិកាអស់ប្រមាណ **១៣៦ ៣១៤ លានរៀល** ឬសមមូលទៅនឹងប្រមាណ **៣៣,៦៦ លានដុល្លារ អាមេរិក**, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តទាំង ២៥ បានប្រើប្រាស់ថវិកាអស់ប្រមាណ **៤៧៨ លានរៀល** ឬសមមូលទៅនឹងប្រមាណ **០,១២ លានដុល្លារអាមេរិក** និង ក្រសួង ស្ថាប័នបានប្រើប្រាស់ថវិកាអស់ ប្រមាណ **១៨ ៩៦៩ លានរៀល** ឬសមមូលទៅនឹងប្រមាណ **៤,៦៨ លានដុល្លារអាមេរិក**។

កម្មវិធីកែទម្រង់ ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" (២០២៣-២០២៧) ដែលជា ដំណាក់កាលចុងក្រោយ មានតម្រូវការថវិកាសរុបប្រមាណ **៤៣៧ ០២៥ លានរៀល** ឬសមមូលទៅនឹង ប្រមាណ **១០៩ លានដុល្លារអាមេរិក** ដោយគិតជាមធ្យមមានទំហំប្រមាណ **៨៧ ៤០៦ លានរៀល** ឬសមមូល ទៅនឹងប្រមាណ **២១,៨៥ លានដុល្លារអាមេរិក** នៅក្នុងមួយឆ្នាំ។

ប្រភពហិរញ្ញវត្ថុដើម្បីគាំទ្រការអនុវត្ត ផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4) រួមមាន÷

- ថវិការបស់រាជរដ្ឋាភិបាលមានទំហំប្រមាណ **១០៨ ៧៧៥ លានរៀល** ឬសមមូលទៅនឹងប្រមាណ **២៧ លានដុល្លារអាមេរិក** ដែលស្មើនឹង ២៥% នៃតម្រូវការថវិកាប៉ាន់ស្មានសរុប។
- មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ (២០២៣-២០២៧) នឹងមានទំហំសរុបប្រមាណ **២៣៩ ១៥០ លានរៀល** ឬសមមូលទៅនឹងប្រមាណ **៦០ លានដុល្លារអាមេរិក** ដែលស្មើនឹង ៥៥% នៃតម្រូវការថវិកាប៉ាន់ស្មានសរុប។
- ថវិកាហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ (សហភាពអឺរ៉ុប) ជាជំនួយឥតសំណងចំនួន **៨៩ ១០០ លាន រៀល** ឬសមមូលទៅនឹងប្រមាណ **២២ លានដុល្លារអាមេរិក** ស្មើនឹង ២០% នៃតម្រូវការថវិកា ប៉ាន់ស្មានសរុប។

៦.៤. វិធានការដោះស្រាយបញ្ហាប្រឈម

សម្រាប់ដំណាក់កាលទី៤ បញ្ហាប្រឈមចម្បងៗ ដែលអាចជះឥទ្ធិពលជាអវិជ្ជមានដល់កម្មវិធីកែ-ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន÷ (១) ភាពជាអ្នកដឹកនាំនិងភាពជាម្ចាស់, (២) ការសម្រប-

សម្រួល, (៣) រចនាសម្ព័ន្ធរដ្ឋបាលនិងកម្មវិធី និង (៤) ហិរញ្ញប្បទានគាំទ្រដំណើរការអនុវត្តកម្មវិធីកែទម្រង់។ បញ្ហាប្រឈមទាំងនេះអាចបង្កឱ្យមានការរាំងស្ទះឬពន្យារពេល ដល់ការអនុវត្តសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងចាំបាច់ត្រូវចាត់វិធានការដោះស្រាយឱ្យបានទាន់ពេលវេលា។

ចំពោះបញ្ហាប្រឈមដែលពាក់ព័ន្ធនឹង "ភាពជាអ្នកដឹកនាំនិងភាពជាម្ចាស់", វិធានការដោះស្រាយរួមមាន÷

- រៀបចំឱ្យមានកិច្ចប្រជុំទៀងទាត់ប្រចាំខែ ឬ ប្រចាំត្រីមាស ក្នុងក្រុមការងារកែទម្រង់ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ ដើម្បីពិនិត្យ ពិភាក្សា និងតាមដានលើវឌ្ឍនភាពកម្មវិធីកែទម្រង់ និងអនុសាសន៍ ឬ ទស្សនៈកែលម្អ។
- បន្តបង្កើនការផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដល់កម្រិតថ្នាក់ដឹកនាំនយោបាយ, កម្រិតថ្នាក់ដឹកនាំបច្ចេកទេសនិងកម្រិតជំនាញ តាមរយៈសិក្ខាសាលា, សន្និសីទ, បទ-ឧទ្ទេសនាម និងការបណ្តុះបណ្តាលចាំបាច់ពាក់ព័ន្ធនានា ទាំងបរិមាណនិងគុណភាព។
- ជំរុញនិងលើកទឹកចិត្តឱ្យមានការដាក់ចេញជាសកម្មភាពជាក់ស្តែងនៅក្នុង CAP4 ឱ្យបានគ្រប់ជ្រុងជ្រោយ។

ចំពោះបញ្ហាប្រឈមដែលពាក់ព័ន្ធនឹង "ការសម្របសម្រួល", វិធានការដោះស្រាយរួមមាន÷

- បន្តបង្កើនទំនាក់ទំនងសម្របសម្រួលជាប្រចាំឱ្យបានសកម្មជាងមុន ជាពិសេសគឺការពង្រឹងការអនុវត្តអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្រប-សម្រួលការកែទម្រង់ ៣ ប្លក ១ នៃរាជរដ្ឋាភិបាល និងក្នុងករណីចាំបាច់ ត្រូវពិនិត្យកែលម្អអនុក្រឹត្យនេះ។
- រៀបចំនិងអនុវត្ត យុទ្ធសាស្ត្រស្តីពីការចូលរួមនិងទំនាក់ទំនង (Engagement and Communication Strategy) ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- បន្តពង្រឹងទំនាក់ទំនងជាប្រចាំ រវាងថ្នាក់ដឹកនាំនិងមន្ត្រីបង្គោល ក្នុងអង្គភាព និង/ឬ អន្តរក្រសួងស្ថាប័ន ក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- បន្តលើកកម្ពស់ជំនាញទន់ពាក់ព័ន្ធនឹងសិល្បៈទំនាក់ទំនង និងភាពជាអ្នកដឹកនាំសម្របសម្រួលគ្រប់កម្រិត ដើម្បីឱ្យការងាររលូន និងបញ្ចៀសបញ្ហាស្មុគស្មាញ។

ចំពោះបញ្ហាប្រឈមដែលពាក់ព័ន្ធនឹង "រចនាសម្ព័ន្ធរដ្ឋបាលនិងកម្មវិធី", វិធានការដោះស្រាយរួមមាន÷

- បន្ទីរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធរបស់ថវិកាកម្មវិធី។
- រៀបចំការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការ។
- កំណត់បន្ទាត់គណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ, ពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំពោះបញ្ហាប្រឈមដែលពាក់ព័ន្ធនឹង “ហិរញ្ញប្បទានគាំទ្រដំណើរការអនុវត្តកម្មវិធីកែទម្រង់”, វិធានការដោះស្រាយ រួមមាន÷

- អនុវត្តឱ្យបាននូវក្របខ័ណ្ឌវាយតម្លៃសមិទ្ធកម្ម (Performance Assessment Framework) រវាងដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល។
- ធានាឱ្យបាននូវភាពជឿទុកចិត្តនៃថវិកា ដោយបន្តអនុវត្តយុទ្ធសាស្ត្រក៏រគរចំណូល និងបន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តចំណាយ។
- អនុវត្តតាមអនុក្រឹត្យ ស្តីពី ការបង្កើតមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព ព្រមទាំងត្រូវរៀបចំបង្កើត មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគ្រប់ជ្រុងជ្រោយមួយ ដើម្បីធានាបាននូវការគាំទ្រដល់ដំណើរការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

៦.៥. វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ដំណាក់កាលទី៤ ត្រូវបន្តអនុលោមតាមសារាចររាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០១៥ ស្តីពី វិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្អែកតាមសារាចរនេះ, ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**ក.ហ.ស.**) នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំលទ្ធផលគន្លឹះនិងផែនការសកម្មភាពលម្អិត ឱ្យមានសង្គតិភាពទៅនឹងផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4)។ **ក.ហ.ស.** ត្រូវរៀបចំកិច្ចប្រជុំត្រួតពិនិត្យផ្ទៃក្នុង ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ប្រចាំត្រីមាសនិងប្រចាំឆ្នាំ និងបូកសរុបជារបាយការណ៍ផ្ញើមក **អ.គ.ហ.** ដើម្បីផ្ទៀងផ្ទាត់ បូកសរុប និងរៀបចំជារបាយការណ៍វឌ្ឍនភាព សម្រាប់ជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សានៅក្នុងកិច្ចប្រជុំបន្តបន្ទាប់។

កិច្ចប្រជុំត្រួតពិនិត្យ តាមដាន និងវាយតម្លៃ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវធ្វើឡើងជា ៣ កម្រិត÷

- គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ (**គ.ក.ហ.**) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការងារកែទម្រង់នៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលើកសំណូមពរជាវិធានការសម្រាប់ដាក់បញ្ចូល ក្នុងកិច្ចប្រជុំកម្រិត **គ.ហ.ស.**។
- **គ.ហ.ស.** សម្រាប់ការងារកែទម្រង់ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល។
- **គ.ហ.ស. និងតំណាងដៃគូអភិវឌ្ឍន៍** សម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

គោលបំណងនៃកិច្ចប្រជុំទាំង ៣ កម្រិត គឺដើម្បីជំរុញការអនុវត្តសកម្មភាពកែទម្រង់ និងពិភាក្សាលើបញ្ហាប្រឈមក្នុងការអនុវត្ត ព្រមទាំងរកដំណោះស្រាយជាវិធានការជាក់លាក់។

ជាមួយគ្នានេះដែរ ដើម្បីពង្រឹងប្រសិទ្ធភាពការអនុវត្តសារាចរលេខ ០៩ សរ របស់រាជរដ្ឋាភិបាល, **គ.ហ.ស.** ត្រូវបង្កើតក្របខ័ណ្ឌ ឬឧបករណ៍ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដែលរួមមាន÷

- **គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងផ្អែកលើលទ្ធផល (Result-Based Management; RBM)÷** ឯកសារនេះ កំណត់វិធាន និងនីតិវិធីលម្អិត ក្នុងការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពកែទម្រង់។
- **ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មនិងគណនេយ្យភាព (Performance Management and Accountability System; PMAS)÷** ប្រព័ន្ធ PMAS គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃនៃការអនុវត្តផែនការសកម្មភាពកែទម្រង់។
- **ក្របខ័ណ្ឌវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត (Public Financial Management Assessment Framework; PFMAF)÷** ក្របខ័ណ្ឌ PFMAF ជាឧបករណ៍វាយតម្លៃ ដើម្បីកំណត់នូវភាពខ្លាំងនិងភាពខ្សោយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។ ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដែលជាស្ថាប័នអនុវត្តថវិកា នឹងអាចកំណត់ចំណុចគន្លឹះចំនួនពីរ រួមមាន÷ (១) ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត និង (២) លំដាប់អាទិភាពនិងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ជាមួយក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤។

ក្នុងក្របខ័ណ្ឌកិច្ចសហការប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍, **គ.ហ.ស**. ត្រូវប្រើប្រាស់ក្របខ័ណ្ឌ ឬ ឧបករណ៍អន្តរជាតិផ្សេងៗ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះ រួមមាន÷ ក្របខ័ណ្ឌ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ក្របខ័ណ្ឌ TADAT, ឧបករណ៍វាយតម្លៃរដ្ឋបាលគយ (Tax Diamond), ក្របខ័ណ្ឌវាយតម្លៃការគ្រប់គ្រងវិនិយោគសាធារណៈ (Public Investment Management Assessment; PIMA), ក្របខ័ណ្ឌវាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈ (Debt Management Performance Assessment; DeMPA), ក្របខ័ណ្ឌ PER, ក្របខ័ណ្ឌវាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ (Methodology for Assessing Procurement Systems; MAPS) និងការវាយតម្លៃពីភាគីឯករាជ្យ (External Advisory Panel; EAP)។

៧. សេចក្តីសន្និដ្ឋាន

ឯកសារ "**ចក្ខុវិស័យនិងយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ដំណាក់កាលទី៤**" បានដាក់ចេញនូវចក្ខុវិស័យ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួម ដើម្បីសម្រេចបាននូវគោលបំណងជាសារវន្តគឺ ការកសាងប្រព័ន្ធ "គណនេយ្យភាពសមិទ្ធកម្ម"។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ត្រូវគិតគូរពីការបង្កើនសិទ្ធិសម្រេចជូនអង្គភាពថវិកា, ការធ្វើទំនើបកម្មនីតិវិធីនិងប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការពង្រឹងសមត្ថភាពស្ថាប័ន, ការធ្វើវិចារណកម្មមុខងារនិងភារកិច្ចអង្គភាពផ្នែកក្នុងនៃក្រសួងស្ថាប័ន, ការតម្រឹមលក្ខខណ្ឌយោងការងារមន្ត្រីជាមួយនឹងរចនាសម្ព័ន្ធនៃថវិកា និងការពង្រឹងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ។

ការសម្រេចបានគោលបំណងនេះ នឹងធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា កាន់តែមានភាពធន់មាំនិងចីរភាព និងឈានទៅសម្រេចបានលទ្ធផលចុងក្រោយទាំង ៣ រួមមាន ប្រសិទ្ធភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា (ទាំងក្នុងផ្នែកវិភាជន៍និងក្នុងផ្នែកប្រតិបត្តិការ) និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

បទពិសោធន៍នៃការកែទម្រង់កន្លងមក បានបង្ហាញថា កត្តាកំណត់ភាពជោគជ័យក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន÷

- **ការលើកទឹកចិត្ត ទាំងផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ÷** ដើម្បីឆ្លើយតបនឹងគុណបំណាច់ក្នុងការលះបង់ពេលវេលាផ្ទាល់ខ្លួន លើសពីការងារប្រចាំថ្ងៃសម្រាប់ការងារកែទម្រង់ ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់នូវការលើកទឹកចិត្តដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ ទាំងផ្នែកហិរញ្ញវត្ថុ

និងមិនមែនហិរញ្ញវត្ថុ ដូចជា ការផ្តល់ប្រាក់ឧបត្ថម្ភមុខងារ ការបណ្តុះបណ្តាល ប័ណ្ណសរសើរ និងអាទិភាពក្នុងការដំឡើងតួនាទី។

- **ការពង្រឹងសមត្ថភាពស្ថាប័ននិងមន្ត្រី÷** ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តចាំបាច់ត្រូវបន្តពង្រឹងយន្តការដឹកនាំ គ្រប់គ្រង និងសម្របសម្រួល ព្រមទាំងបង្កើនឆន្ទៈ ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវខ្ពស់ចំពោះការងារកែទម្រង់។ លើសពីនេះទៅទៀត ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវបន្តអភិវឌ្ឍសមត្ថភាពបន្ថែមលើជំនាញបច្ចេកទេសឱ្យស្របតាមបរិការណ៍កែទម្រង់។ ម្យ៉ាងទៀត ការចែករំលែកបទពិសោធន៍នៃការអនុវត្តរវាងនិម្មាបនករនិងប្រតិបត្តិករ ក៏មានភាពចាំបាច់ ក្នុងការបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ផងដែរ។
- **ការបន្តអនុវត្តអភិក្រមការងារក្នុងបរិការណ៍កែទម្រង់ គឺ បុរេសកម្ម សកម្ម និងអន្តរសកម្ម÷** ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តត្រូវចាត់វិធានការបង្ការទប់ស្កាត់បញ្ហា ដោះស្រាយបញ្ហាដែលកើតមាន និងបង្កើនការប្រាស្រ័យទាក់ទងគ្នា ព្រមទាំងរួមគ្នាដោះស្រាយបញ្ហាចំពោះមុខ។

ជាសេចក្តីសន្និដ្ឋានរួម, សមិទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពោលគឺ **ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ** នឹងក្លាយជាឧបករណ៍សម្រាប់បម្រើឱ្យឧត្តមប្រយោជន៍ជាតិ ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយកម្ពុជាពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ការណ៍នេះ ទាមទារឱ្យមានការប្តេជ្ញាចិត្តខ្ពស់, ការគាំទ្រទាំងផ្នែកនយោបាយនិងផ្នែកបច្ចេកទេស, កិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌស្ថាប័នរាជរដ្ឋាភិបាល និងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍។

ក្នុងន័យនេះ ការគោរពតាមឱវាទានុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គឺ “**កែទម្រង់ រស់, មិនកែទម្រង់ ស្លាប់**” និង “**គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ; ហើយក៏គ្មានការកែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ**” នៅតែមានតម្លៃសម្រាប់តម្រង់ទិសការអនុវត្តកម្មវិធីកែទម្រង់។

បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១. អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពី ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឧបសម្ព័ន្ធទី២. អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឧបសម្ព័ន្ធទី៣. អនុក្រឹត្យ ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ ប្លុក ១ នៃរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធទី៤. សេចក្តីសម្រេចរាជរដ្ឋាភិបាលលេខ ២០ សសរ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពី ការតែងតាំងសមាសភាព គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឧបសម្ព័ន្ធទី៥. សារាចររាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី វិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឧបសម្ព័ន្ធទី៦. ប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពី ការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី៧. ប្រកាសលេខ ៣៤៧ សហវ.ប្រក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ឧបសម្ព័ន្ធទី៨. សេចក្តីសម្រេចលេខ ០៣៦ សហវ.សសរ.អគហ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធទី៩. យន្តការស្ថាប័ន សម្រាប់ទ្រទ្រង់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

ឧបសម្ព័ន្ធទី១០. ផែនការសកម្មភាពរួម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤

ខ្ជបសម្ព័ន្ធទី១. អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពី ការបង្កើត គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៣. អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើត "**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" សរសេរជាអក្សរកាត់ថា "**គ.ហ.ស.**"។

គ.ហ.ស. មានភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។

ជំពូកទី២
សមាសភាពនិងរចនាសម្ព័ន្ធ

មាត្រា២.-

គ.ហ.ស. មានសមាសភាពដូចតទៅ÷

១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ		ប្រធាន
២- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	មួយរូប	អនុប្រធានប្រចាំការ
៣- ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា	មួយរូប	អនុប្រធាន
៤- រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែលមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ		សមាជិក
៥- អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា		សមាជិក
៦- ប្រធានអង្គភាពប្រតិបត្តិនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ដែលមានការពាក់ព័ន្ធផ្សេងទៀត		សមាជិក
៧- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ		សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងនៃ **គ.ហ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៣.-

ដើម្បីធានាប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃការបំពេញភារកិច្ចរបស់ **គ.ហ.ស.** ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើត "**ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" មួយនៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។ ក្រុមការងារនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលជាសមាជិក **គ.ហ.ស.**។

ប្រធាន **គ.ហ.ស.** ត្រូវរៀបចំសេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារនេះ ជូនដល់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើត "**គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" មួយដែលត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធាន **គ.ហ.ស.** ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួង។

ជំពូកទី៣
ដំណើរការការងារ

មាត្រា៤.-

តាមការអញ្ជើញរបស់ប្រធាន សមាជិក និងអនុប្រធាន **គ.ហ.ស.** ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

មាត្រា៥.-

គ.ហ.ស. មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងទៀតនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

គ.ហ.ស. មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ តាមការចាំបាច់។

មាត្រា៦.-

គ.ហ.ស. មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គ.ហ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

គ.ហ.ស. ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

ជំពូកទី៤
អន្តរប្បញ្ញត្តិ

មាត្រា៧.-

រចនាសម្ព័ន្ធរបស់ **គ.ហ.ស.**ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការរៀបចំថ្មីដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ជំពូកទី៥
អវសានប្បញ្ញត្តិ

មាត្រា៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៩
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ខ្ញុំបាទសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសប្រើច្បាប់ដែលរដ្ឋសភាបានពិនិត្យ និងព្រឹទ្ធសភាបានពិចារណាឱ្យការយល់ព្រម តាមរយៈរាជក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពី ការប្រៀបធៀបនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៤.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ.ទៀ.៣៧.....អនក្រ.បក ចុះថ្ងៃទី.១.៧.ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា "**អ.គ.ហ.**"។

អ.គ.ហ. បំពេញមុខងារជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា **គ.ហ.ស.**។

មាត្រា២.-

អ.គ.ហ. មានទីតាំងស្ថិតនៅក្នុងទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រើប្រាស់គ្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

ជំពូកទី២

តួនាទី និងភារកិច្ច

មាត្រា៣.-

ក្នុងការបំពេញមុខងាររបស់ខ្លួន **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** ស្របតាមការណែនាំ និងការសម្រេចរបស់ **គ.ហ.ស.** ដោយរួមទាំងការរៀបចំដាក់ឱ្យអនុវត្ត និងការតាមដានត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការរៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ
- សម្របសម្រួលប្រចាំថ្ងៃ លើការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងផ្នែកភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្តល់យោបល់ និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈម និងបញ្ហាជំនាញបច្ចេកទេសដើម្បីជំរុញល្បឿន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សហការ និងសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ផ្តល់ការគាំទ្រជូន អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ដោយ

រាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន ដោយរាប់បញ្ចូលបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្តត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយ និងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ជំពូកទី៣
រចនាសម្ព័ន្ធ

មាត្រា៤._

អ.គ.ហ. ត្រូវដឹកនាំដោយអគ្គលេខាធិការ ១រូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងពីក្នុងចំណោមមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានគុណវុឌ្ឍិនិងបទពិសោធសមស្របតាមលក្ខខណ្ឌការងារតម្រូវ។

អគ្គលេខាធិការ ត្រូវតែងតាំងនិងបញ្ចប់តួនាទីដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ហ.ស.**។

អគ្គលេខាធិការរង ត្រូវតែងតាំងនិងបញ្ចប់តួនាទីដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ហ.ស.**។

មាត្រា៥._

ការរៀបចំរចនាម៉ូន្ធ និងការប្រព្រឹត្តទៅរបស់ **អ.គ.ហ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាប្រធាន **គ.ហ.ស.**។

មាត្រា៦._

មន្ត្រីបម្រើការងារក្នុង **អ.គ.ហ.** ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពីក្រសួង ស្ថាប័នដែលអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងករណីចាំបាច់ មន្ត្រីបម្រើការងារក្នុង **អ.គ.ហ.** អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃមុខងារសាធារណៈ ដោយផ្អែកលើគោលការណ៍សមត្ថភាព តម្លាភាព និងការប្រកួតប្រជែងបើកទូលាយ។

មាត្រា៧._

លើកលែងអគ្គលេខាធិការនិងអគ្គលេខាធិការរង មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឱ្យបម្រើការងារក្នុង **អ.គ.ហ.** ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ÷

- ផ្អាកការងារនៅអង្គភាពដើមជាបណ្តោះអាសន្ន
- បំពេញការងារពេញម៉ោងនៅ **អ.គ.ហ.**

- រក្សាបាននូវប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភផ្សេងៗ ក្នុងមុខងារសាធារណៈ អតីតភាពការងារ និងមុខតំណែងនៅអង្គភាពដើម ក្នុងពេលបំពេញមុខងារនៅ **អ.គ.ហ.**
- ទទួលបានការលើកទឹកចិត្ត ដោយទទួលបានមុខតំណែងសមស្រប នៅពេលវិលត្រឡប់ទៅបំពេញការងារនៅអង្គភាពដើមវិញ។

មាត្រា៨.-

ដោយមានការឯកភាពពីប្រធាន **គ.ហ.ស.** អគ្គលេខាធិការនៃ **អ.គ.ហ.** អាចជ្រើសរើសទីប្រឹក្សា អ្នកជំនាញការជាតិឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យាផ្សេងទៀត ដើម្បីជួយដល់ការងារ **អ.គ.ហ.**។

ការជ្រើសរើស ត្រូវអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

ជំពូកទី៤
កិច្ចដំណើរការនិងថវិកា

មាត្រា៩.-

អ.គ.ហ. មានកញ្ចប់ថវិកាផ្តាល់ដោយឡែក សម្រាប់គាំទ្រកិច្ចដំណើរការរបស់ខ្លួន។

កញ្ចប់ថវិការបស់ **អ.គ.ហ.** មានប្រភពមកពី÷

- ថវិការដ្ឋដែលជាកញ្ចប់មួយនៅក្នុងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត។

ថវិកាប្រចាំឆ្នាំរបស់ **អ.គ.ហ.** ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកតាមសំណើរបស់អគ្គលេខាធិការនៃ **អ.គ.ហ.**.។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

មាត្រា១០.-

លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ១០០១ សហវ.ប្រក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការរៀបចំ **អ.គ.ហ.** ស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១១.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ឧទ្ធកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ខ្ជបសម្ព័ន្ធនីតិ៣. អនុក្រឹត្យ ២៤១ អនក្រ.បក ចុះថ្ងៃនីតិ២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បុក ១ នៃរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៤១.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

យន្តការសម្របសម្រួលការកែទម្រង់ ៣ បុក ១ នៃរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៤៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៩១ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រួច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១._

អនុក្រឹត្យនេះ មានគោលបំណង ធានាសុខដុមនីយកម្មរវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដែលតទៅនេះហៅថា **យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល** និងសរសេរជាអក្សរកាត់ថា "**យ.ស.ក.**"។

មាត្រា២._

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការកែទម្រង់ទាំងអស់របស់រាជរដ្ឋាភិបាល ដែលមានទំនាក់ទំនងជាមួយនឹងកម្មវិធីកែទម្រង់ទាំង ៤ ខាងលើ។

ជំពូកទី២
មុខងារ និង តួនាទី

មាត្រា៣._

យ.ស.ក. ជាយន្តការដឹកនាំនិងសម្របសម្រួលផ្តាស់វេនប្រចាំត្រីមាសរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

មាត្រា៤._

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ជាប្រធានទទួលវេនដឹកនាំនិងសម្របសម្រួល **យ.ស.ក.** មានតួនាទីនិងភារកិច្ចដូចតទៅ÷

- សិក្សានិងកំណត់បញ្ហាប្រឈមនិងសំណើជំណោះស្រាយទាំងឡាយដែលមានចរិតអន្តរកែទម្រង់ ដើម្បីជាប្រធានបទពិភាក្សានិងសម្រេចក្នុងក្របខ័ណ្ឌ **យ.ស.ក.**
- ដឹកនាំនិងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗ ព្រមទាំងលើកសំណើសកម្មភាពឬសំណើជំណោះស្រាយជាគម្រោងការងារឬបេសកកម្មការងារដែលមានចរិតលក្ខណៈអន្តរកែទម្រង់ តាមសំណើរបស់លេខាធិការដ្ឋានកែទម្រង់ណាមួយ តាមបញ្ជារបស់ប្រធានគណៈកម្មាធិការកែទម្រង់ ឬតាមការចាំបាច់
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
- រៀបចំនិងកំណត់របៀបវារៈប្រជុំ **យ.ស.ក.** ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់
- រៀបចំនិងធានាដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់
- រៀបចំរបាយការណ៍កិច្ចប្រជុំជូនប្រធានគណៈកម្មាធិការកែទម្រង់ទទួលបន្ទុក ស្របតាមនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យនេះ
- រៀបចំ សម្របសម្រួល និងដឹកនាំការងារអន្តរកែទម្រង់ផ្សេងទៀតតាមការចាំបាច់។

មាត្រា៥._

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗ គឺជា "**ប្រធាន យ.ស.ក.**" ប្រចាំត្រីមាសនោះ។ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬ អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុក ដឹកនាំជំនួសបាន។

ប្រធាន **យ.ស.ក.** ត្រូវធានាការអនុវត្តតាមតួនាទីនិងភារកិច្ចដូចមានកំណត់ក្នុងមាត្រា ៤ ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់។

ប្រធាន **យ.ស.ក.** ត្រូវដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ។

ប្រធាន **យ.ស.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងតំណាងអង្គភាពក្រោមឱវាទក្រសួងដឹកនាំការងារកែទម្រង់នីមួយៗ ឬ ដៃគូអភិវឌ្ឍន៍នានា ចូលរួមប្រជុំបានតាមការចាំបាច់។

មាត្រា៦._

ក្នុងករណីចាំបាច់ឬមានសំណើពីអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ណាមួយខាងលើ ការទទួលនិងដឹកនាំសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសអាចប្រព្រឹត្តទៅក្រោមទម្រង់ជាសហប្រធាន។

មាត្រា៧._

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវម្ចាស់ការសម្របសម្រួលស្ថាប័ននិងអង្គភាព ដែលជាតួអង្គអនុវត្តពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់រៀងៗខ្លួន ក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាព របាយការណ៍ និងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីធានាការចូលរួមអនុវត្ត **យ.ស.ក.** ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

ជំពូកទី៣
កិច្ចដំណើរការ

មាត្រា៨._

យ.ស.ក. ត្រូវមានផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវអនុម័តយ៉ាងយូរក្នុងសប្តាហ៍ទី៤ នៃឆ្នាំបន្ទាប់។ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេនប្រចាំត្រីមាសទី៤ និងត្រីមាសទី១នៃឆ្នាំបន្ទាប់ ត្រូវសហការគ្នានិងទទួលខុសត្រូវរៀបចំ និងបូកសរុបផែនការសកម្មភាព ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

មាត្រា៩._

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវរៀបចំ បូកសរុប ត្រួតពិនិត្យតាមដាន និងត្រូវដាក់ជារបៀបវារៈពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

អគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវទទួលបន្ទុកសម្របសម្រួលនិងបូកសរុបរបាយ-ការណ៍វឌ្ឍនភាពដែលស្ថិតក្រោមការទទួលបន្ទុករបស់ខ្លួន និងបញ្ជូនមកអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានដែលជាប្រធានទទួលវេន យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែបន្ទាប់ ដើម្បីបូកសរុបសម្រាប់កិច្ចប្រជុំប្រចាំត្រីមាស។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការកែទម្រង់ទាំងបួន អាចចេញសេចក្តីសម្រេចរួមដើម្បីកំណត់វិធាននិងនីតិវិធីលម្អិតនៃការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព។

មាត្រា១០._

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវរៀបចំឡើងយ៉ាងយូរបំផុតនៅក្នុងសប្តាហ៍ទី ៤ នៃត្រីមាសបន្ទាប់។

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវសម្រេចលើរបៀបវារៈកំណត់ដោយប្រធានកិច្ចប្រជុំ និងត្រូវសម្រេចលើការកំណត់អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ដែលត្រូវទទួលបន្ទុកជាប្រធាន **យ.ស.ក.** នៃត្រីមាសបន្ទាប់។

របាយការណ៍កិច្ចប្រជុំ ត្រូវរៀបចំគោរពជូនប្រធានគណៈកម្មាធិការកែទម្រង់ដែលជាប្រធានទទួលវេន ដើម្បីពិនិត្យនិងសម្រេច មុននឹងចម្លងជូនអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យនិងសហការអនុវត្ត។

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ប្រធាន **យ.ស.ក.** អាចស្នើសុំរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិភាក្សានិងលើកសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់លាក់ណាមួយ។

មាត្រា១១._

ក្នុងករណីដែលអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេន ខកខានឬយឺតយ៉ាវក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស តាមចិរវេលាខាងលើ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតអាចមានសិទ្ធិទទួលភារកិច្ចជំនួសបាន ដើម្បីធានាប្រក្រតីភាព ភាពជាម្ចាស់ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា១២._

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៣._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បុព្វកថា

"**ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច**" ត្រូវបានកំណត់យកជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដែលប្រការនេះជាសក្ខីកម្មអំពីរបៀបវារៈគោលនយោបាយគន្លឹះរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមិនត្រឹមតែបន្តយកចិត្តទុកដាក់លើការងារកែទម្រង់ តែលើសពីនេះ គឺការបង្កើនអាទិភាពលើការងារកែទម្រង់ ជាងពេលណាៗទាំងអស់។

ទន្ទឹមនេះ អភិក្រម ៥ ប្រការ គឺ "**អ្នកញាក់ ឯកទឹក ជុសក្បែល ញាស្ពាល និងឆកាត់**" ដែលខ្ញុំបានដាក់ចេញកាលពីដើមអាណត្តិទី៥នៃរាជរដ្ឋាភិបាល នៅតែជាអភិក្រមកែទម្រង់ដ៏មុតស្រួចនិងត្រូវបន្តប្រកាន់យកសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈ ដើម្បីចូលរួមចំណែកដល់ការសម្រេចបាននូវគោលដៅនៃការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចនេះ។

ការកែទម្រង់បានក្លាយទៅជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ក៏ប៉ុន្តែការកែទម្រង់មិនមែនទើបតែត្រូវបានចាប់ផ្តើមនោះឡើយ ផ្ទុយទៅវិញ យើងបានធ្វើការងារនេះអស់រយៈពេល ៤ ទសវត្សមកហើយ។ ហេតុនេះ ក្នុងនាមជាប្រមុខដឹកនាំរាជរដ្ឋាភិបាល ខ្ញុំតែងមានទស្សនៈមួយថា "**រដ្ឋាភិបាលរបស់ប្រជាជន ដោយសារប្រជាជន និងដើម្បីប្រជាជន**" ដ៏ពិតប្រាកដគឺជារដ្ឋាភិបាលដែលយល់ច្បាស់អំពីគុណតម្លៃនៃការកែទម្រង់និងមោះមុតក្នុងការងារនេះជាប់ជាប្រចាំទៅតាមតម្រូវការនៃគ្រប់កាលៈទេសៈ ដើម្បីធានាចីរភាពនៃរដ្ឋបាលសាធារណៈ ប្រសិទ្ធភាពនៃសេវាសាធារណៈ និងសុខុមាលភាពនិងជីវភាពកាន់តែប្រសើររបស់ប្រជាពលរដ្ឋ។

យើងបានចាប់ផ្តើមការងារកែទម្រង់តាំងពីក្នុងគ្រាដែលកម្ពុជាទើបរួចចាកផុតពីរបបប្រល័យពូជសាសន៍មកម្ល៉េះ ដែលពេលនោះអាទិភាពចាំបាច់ទីមួយរបស់យើងមិនមែនការអភិវឌ្ឍធនធានមនុស្ស ផ្លូវ ទឹក និងភ្លើងដូចសព្វថ្ងៃនេះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ អាទិភាពដែលយើងត្រូវដោះស្រាយជាចាំបាច់ គឺបញ្ចប់ការអត់ឃ្លាន ហើយគោលដៅសំខាន់បំផុតនៃការកែទម្រង់របស់យើងនាពេលនោះ គឺ ***ការរកដំណោះស្រាយបញ្ចប់ភាពក្រីក្ររបស់ប្រជាជនយើង***។ ចំណុចនេះជាការបកស្រាយមួយទៅលើប្រវត្តិនៃទិសស្លោកគន្លឹះដែលខ្ញុំតែងតែលើកឡើងនិងរំលឹកជាប់ជាប្រចាំថា "**កែទម្រង់ រស់, មិនកែទម្រង់ ស្លាប់**"។ ក្នុងសម័យសន្តិភាព ថ្ងៃត្បិតអាទិភាពនៃការកែទម្រង់របស់យើងមានការផ្លាស់ប្តូរទៅតាមតម្រូវការសង្គមកំពុងអភិវឌ្ឍលូតលាស់ ទិសស្លោកមួយនេះនៅតែជាគំនិតដឹកនាំដ៏ត្រឹមត្រូវនិងប្រកបដោយសច្ចធម៌ ដែលថ្នាក់ដឹកនាំនិងមន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់ត្រូវឈ្វេងយល់និងប្រកាន់ខ្ជាប់ ជាពិសេស ត្រូវចៀសវាងសេចក្តីយល់ខុសថាការងារកែទម្រង់គឺជាបន្ទុកបន្ថែមលើការបំពេញមុខងារនិងភារកិច្ចប្រចាំថ្ងៃ។

ជាសព្វានុម័ត រដ្ឋាភិបាលនៃប្រទេសនីមួយៗ បានចាប់យកការកែទម្រង់លើវិស័យអាទិភាពរបស់ខ្លួនទៅតាមវិធីសាស្ត្រដោយឡែកៗពីគ្នា អាស្រ័យលើបរិបទសង្គម ប្រពៃណីស្ថាប័ន និងបែបបទរដ្ឋបាលរៀងៗខ្លួន។ ដោយឡែក សម្រាប់កម្ពុជា យើងបានរៀបចំការងារកែទម្រង់ជាកម្មវិធីរយៈពេលវែង ដោយមានការកំណត់ចក្ខុវិស័យវែងឆ្ងាយ មានការបែងចែកជាដំណាក់កាល

ប្រកបដោយតថភាពនិយមនិងគោលដៅជាក់លាក់ មានរចនាសម្ព័ន្ធដឹកនាំនិងយន្តការអនុវត្តច្បាស់លាស់។ វិធីសាស្ត្រកែទម្រង់នេះបានបង្ហាញអំពីសេចក្តីក្លាហាន មហិច្ឆតា និងឆន្ទៈមោះមុតរបស់យើងលើការកែទម្រង់ ដោយអាចអនុវត្តទៅបានតាមបរិបទកម្ពុជានិងឆ្លើយតបបានទ្បើវសេចក្តីត្រូវការរបស់កម្ពុជា ប្រកបដោយមោទនភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផ្អែកលើទស្សនៈវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាកម្មវិធីកែទម្រង់រយៈពេលវែងជាច្រើនលើគ្រប់វិស័យ ជាពិសេសការដាក់ចេញនូវកម្មវិធីកែទម្រង់ពាក់ព័ន្ធនឹងការបង្កើនគុណភាពអភិបាលកិច្ច ឬការកែទម្រង់លើរចនាសម្ព័ន្ធ ឬនិយាយម្យ៉ាងទៀតការកែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធដែលមានចំនួន ៤ សំខាន់ៗ គឺ **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌**។ កម្មវិធីកែទម្រង់នីមួយៗខាងលើនេះ មានរចនាសម្ព័ន្ធដឹកនាំ យន្តការអនុវត្ត និងផែនការសកម្មភាពយ៉ាងលម្អិត រហូតទទួលបានការសាទរនិងការគាំទ្រពីដៃគូអភិវឌ្ឍន៍នានារួមមានទាំងការផ្តល់ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុជាបន្តបន្ទាប់ ក្នុងភាពជាដៃគូ កិច្ចសហប្រតិបត្តិការ និងការគោរពភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជា។

កម្មវិធីកែទម្រង់ទាំង ៤ នេះ បានវិវត្តរីកចំរើនទៅមុខ ដោយស្រង់បានទ្បើវបទពិសោធន៍ជាមេរៀនល្អៗជាច្រើនជាមូលដ្ឋានគន្លឹះនៃការកែទម្រង់កម្មវិធីរបស់ខ្លួនសម្រាប់ដំណាក់កាលបន្តបន្ទាប់មកទៀត។ ក្នុងន័យនេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានចាប់ផ្តើមអនុវត្តជាផ្លូវការនៅឆ្នាំ២០១០ តាមរយៈកម្មវិធីជាតិ ១០ ឆ្នាំ លើកទី១ (២០១០-២០១៩) របស់ខ្លួន មុននឹងបោះជំហានមកដល់កម្មវិធីជាតិ ១០ ឆ្នាំលើកទី២ (២០២១-២០៣០) ដែលទើបត្រូវបានចាប់ផ្តើមកាលពីពេលថ្មីៗនេះ។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានចាប់ផ្តើមជាផ្លូវការនៅក្នុងឆ្នាំ២០០៤ និងត្រូវបានកំណត់ថាត្រូវអនុវត្តរហូតដល់ឆ្នាំ២០២៥ ដោយចែកជា ៤ ដំណាក់កាល ដែលបច្ចុប្បន្ន កម្មវិធីកែទម្រង់នេះកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល ៣ ឬក ២ មុននឹងទៅចាប់ផ្តើមជាផ្លូវការដំណាក់កាលទី៤ ជាដំណាក់កាលចុងក្រោយ ដែលផ្តោតលើការសម្រេចបានទ្បើវ "គណនេយ្យភាពសមិទ្ធកម្ម"។ ដោយឡែក កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដំណាក់កាលទី១ (២០១៥-២០១៨) ត្រូវបានបញ្ចប់រួចរាល់ និងកំពុងរៀបចំទ្បើវកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០២២-២០៣៥។ រីឯកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក៏កំពុងត្រូវបានរៀបចំជារចនាសម្ព័ន្ធដឹកនាំនិងយន្តការអនុវត្តឱ្យរស់រវើក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

បច្ចុប្បន្ន នៅក្នុងជំហានចុងក្រោយនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដែលមាន "**ការបង្កើនលេខ្បីនៃការកែទម្រង់អភិបាលកិច្ច**" ជាស្នូល រាជរដ្ឋាភិបាលកម្ពុជាតាមរយៈគណៈកម្មាធិការកែទម្រង់ចំនួន ៤ របស់ខ្លួនបានបោះជំហានជាប្រវត្តិសាស្ត្រមួយកម្រិតទៀត នោះគឺការធានាសុខដុមនីយកម្មនៃការកែទម្រង់ទាំងនេះ ឱ្យមានសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ពាក់ព័ន្ធនឹងប្រសិទ្ធភាព ការកែទម្រង់អភិបាលកិច្ចវិតតែមានសារៈសំខាន់ទ្វេដងដើម្បីពង្រឹងសមត្ថភាពនិងភាពរឹងមាំរបស់ស្ថាប័នសាធារណៈ ក្នុងការឆ្លើយតបបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហានានាជាច្រើនដែល

អាចកើតឡើងដោយមិនអាចស្មានទុកបាននិងមានលក្ខណៈកាន់តែស្មុគស្មាញខ្លាំងឡើង ជាក់ស្តែង សកលលោកបាននិងកំពុងប្រឈមនឹងវិបត្តិជាច្រើន ដូចជា វិបត្តិជំងឺកូវីដ-១៩, វិបត្តិសង្គ្រាមរុស្ស៊ីនៅអ៊ុយក្រែនដែលបង្កឱ្យមានវិបត្តិជាសកលផ្សេងៗទៀត និងការត្រៀមខ្លួនទប់ស្កាត់នូវជំងឺឆ្លងផ្សេងទៀតនាពេលអនាគត ព្រមទាំងការីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាក្នុងយុគសម័យបដិវត្តឧស្សាហកម្ម ៤.០។

ឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១** នេះ គឺជាសក្ខីកម្មនៃការបន្តគោលនយោបាយចាស់ គឺគោលនយោបាយកែទម្រង់ផង និងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មី គឺយុទ្ធសាស្ត្រសុខដុមនីយកម្មនៃការកែទម្រង់ ដោយយកសមិទ្ធផលនិងបទពិសោធន៍កន្លងមកធ្វើជាមូលដ្ឋានឈានឆ្ពោះទៅសម្រេចបាននូវគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១** ត្រូវបានរៀបចំឡើងដោយអនុលោមតាមអភិក្រមចំនួន ៤ គឺ ÷ **ទី១) អភិក្រមរក្សាតំហើញទាំងមូល** ដែលសំដៅប្រការដែលកម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែកនិងអាស្រ័យលើកម្មវិធីកែទម្រង់មួយទៀត ដោយប្រទាក់ក្រឡាគ្នានិងមានទំនាក់ទំនងមិនអាចខ្វះបាន, **ទី២) អភិក្រមចូលរួមចំណែកតាមតួនាទី** សំដៅដល់កម្មវិធីកែទម្រង់នីមួយៗបំពេញឱ្យគ្នាមិនអាចខ្វះបានទៅតាមតួនាទីនិងសមត្ថកិច្ចនៅក្នុងក្របខ័ណ្ឌនៃមុខងារស្ថាប័នរៀងៗខ្លួនដែលមានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន, **ទី៣) អភិក្រមរក្សាភាពជាម្ចាស់និងគាំទ្រកិច្ចសហការ** គឺការគោរពភាពជាម្ចាស់លើវឌ្ឍនភាពនិងគណនេយ្យភាពចំពោះកម្មវិធីកែទម្រង់របស់ខ្លួនផងនិងផ្តល់ការគាំទ្រនិងកិច្ចសហការប្រកបដោយឆន្ទៈជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀតផង និង **ទី៤) អភិក្រមបុរេសកម្ម** គឺការប្រមើលមើលត្រៀមលក្ខណៈដោះស្រាយបញ្ហាជាមួយគ្នាតាមរយៈយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ ដោយមិនរង់ចាំបញ្ហាកើតឡើងទើបមានសកម្មភាពនោះឡើយ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឯកឧត្តម **ង្វៃ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលបានដឹកនាំ ណែនាំ និងតម្រង់ទិសជាប់ជាប្រចាំរហូតសម្រេចបាននូវឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១**។ ខ្ញុំក៏សូមកោតសរសើរចំពោះក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាន និងអង្គភាពនានាជាពិសេសថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននិងលេខាធិការដ្ឋានកែទម្រង់នីមួយៗ ដែលបានសហការនិងពុះពារួមគ្នា ប្រកបដោយសាមគ្គីភាព ស្មារតីទទួលខុសត្រូវ និងឆន្ទៈកែទម្រង់ខ្ពស់ ក្នុងនាមជាសេនាធិការដ៏ចំណានរបស់គណៈកម្មាធិការកែទម្រង់រៀងៗខ្លួន ដែលនេះគឺជាកត្តាដ៏ចម្បងនាំឱ្យសម្រេចបាននូវឯកសារដ៏មានសារៈសំខាន់នេះ។

ខ្ញុំរំពឹងថាឯកសារ **ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១** នេះ ជាមគ្គទេសក៍បង្ហាញផ្លូវដ៏ល្អសម្រាប់ការអនុវត្តយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ សំដៅសម្រេចបាននូវចក្ខុវិស័យ សុខដុមនីយកម្មនៃការកែទម្រង់ ៣ បូក ១ ដូចដែលបានកំណត់រួមគ្នា។ ជាមួយគ្នានេះ ខ្ញុំសូមលើកទឹកចិត្តឱ្យស្ថាប័ននិងអង្គភាពដែលជាតួអង្គពាក់ព័ន្ធទាំងអស់ដកស្រង់បទពិសោធន៍និងមេរៀនល្អៗ ដែលកើតចេញពីកិច្ចដំណើរការនិងការអនុវត្តនៃឯកសារនេះ ធ្វើជាមូលដ្ឋានក្នុងការកែទម្រង់សម្រាប់ការបោះជំហានបន្ទាប់ ជាបន្តទៀត សំដៅពង្រឹងគុណភាពអភិបាលកិច្ច ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិនិងប្រជាជនកម្ពុជា ឱ្យបានកាន់តែប្រសើរឡើង។

ថ្ងៃសុក្រ ២កើត ខែ ចិត្តសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២២ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ខ្ចបសម្ព័ន្ធទី៤. សេចក្តីសម្រេចរាជរដ្ឋាភិបាលលេខ ២០ សសរ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣
ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...២០ សសរ.....

សេចក្តីសម្រេច

ស្តីពី

ការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹតលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .–

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរអក្សរកាត់ថា **គ.ហ.ស.** ដូចខាងក្រោម ÷

១.	ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ប្រធាន
២.	ឯកឧត្តម **ទៀ វិសុត**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជា រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធានប្រចាំការ
៣.	លោកជំទាវ **អ៊ុក ម៉ាលី**	ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា	អនុប្រធាន
៤.	ឯកឧត្តម **រស់ សីលវ៉ា**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃ អ.គ.ហ.	សមាជិកអចិន្ត្រៃយ៍
៥.	ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ចិន្តាសោភា**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៦.	ឯកឧត្តម **ជីវ កេង**	អនុប្រធានតុលាការកំពូល	សមាជិក
៧.	ឯកឧត្តម **ពិត ចំណាន**	រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
៨.	ឯកឧត្តម **ឆាន់ សាផាន**	រដ្ឋលេខាធិការប្រចាំការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៩.	ឯកឧត្តមបណ្ឌិត **សួស គង់**	រដ្ឋលេខាធិការប្រចាំការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១០.	លោកជំទាវ **ខេង សំវ៉ាដា**	រដ្ឋលេខាធិការប្រចាំការក្រសួងកិច្ចការនារី	សមាជិក
១១.	ឯកឧត្តម **ជាប សត្ថារតន៍**	រដ្ឋលេខាធិការប្រចាំការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក

១២. ឯកឧត្តម **យក់ ប៊ុនណា**	រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ	សមាជិក
១៣. ឯកឧត្តម **ម៉ុង សំផន**	រដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
១៤. ឯកឧត្តម **ម៉ៅ ប៊ុនណារិន**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
១៥. ឯកឧត្តម **ចាប សុថារិទ្ធ**	រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	សមាជិក
១៦. លោកជំទាវ **ឌុច សុគន្ធ**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១៧. ឯកឧត្តម **ញឹម ខេមរា**	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១៨. ឯកឧត្តម **អេង គីមស៊ុន**	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ	សមាជិក
១៩. ឯកឧត្តម **ង៉ាវ ហោងតារា**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
២០. ឯកឧត្តម **គីម ឌួច**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិក
២១. លោកជំទាវ **ងិត លីនដា**	រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល	សមាជិក
២២. ឯកឧត្តម **សន ស៊ីថន**	រដ្ឋលេខាធិការក្រសួងផែនការ	សមាជិក
២៣. ឯកឧត្តម **សៅ សុភាព**	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
២៤. ឯកឧត្តម **ប៊ុន ហ៊ាន**	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
២៥. ឯកឧត្តម **ថាច់ ផែន**	រដ្ឋលេខាធិការក្រសួងពតិមាន	សមាជិក
២៦. លោកជំទាវ **យក់ សម្បត្តិ**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
២៧. ឯកឧត្តម **សួង ហោង**	រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
២៨. ឯកឧត្តម **ឡុង ប៉ុណ្ណាស៊ីវ៉ែត្ត**	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
២៩. ឯកឧត្តម **សុខ តុងហាប់**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិក
៣០. ឯកឧត្តម **សារ៉ាយ ឃុន**	រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា	សមាជិក
៣១. ឯកឧត្តម **ហោង សួរ**	រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
៣២. ឯកឧត្តម **ម៉ែន ភុទ្ធី**	រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង	សមាជិក
៣៣. ឯកឧត្តម **ពៅ ប៉ូលីណែល**	រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល	សមាជិក
៣៤. ឯកឧត្តម **ខាន់ ទណ្ណៈ**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
៣៥. ឯកឧត្តមបណ្ឌិត **អ៊ុក សារាទុច**	អគ្គសវនករងនៃអាជ្ញាធរសវនកម្មជាតិ	សមាជិក
៣៦. ឯកឧត្តម **ខូយ លីមហុង**	ឧបការីនៃអង្គភាពប្រឆាំងអំពើពុករលួយ	សមាជិក
៣៧. ឯកឧត្តម **តាំង រតនា**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ	សមាជិក
៣៨. ឯកឧត្តម **សំ ប្រជាមានិត**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាអង្គចៅក្រម	សមាជិក
៣៩. ឯកឧត្តម **ជូ ប៊ុនរិន**	អគ្គលេខាធិការនៃអគ្គលេខាធិកាដ្ឋានសាលាឧទ្ធរណ៍	សមាជិក

៤០. ឯកឧត្តម **ទេព ឌីថា**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត	សមាជិក
៤១. ឯកឧត្តម **សេង ឃុយអ៊ាន់**	អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភានិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ	សមាជិក
៤២. ឯកឧត្តម **ឡឿន រិទ្ធីវ័ន្ត**	អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
៤៣. ឯកឧត្តម **ឡោក ឆាយ**	អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា	សមាជិក
៤៤. ឯកឧត្តម **មិត្ត ការ៉ែន**	អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា	សមាជិក

ប្រការ២ .-

ត្រូវនិរាករណ៍សេចក្តីសម្រេចលេខ ១៣៣ សសរ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ ចាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

ខ្ញុំបាទសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសឱ្យដឹងថា

ព្រះរាជក្រឹត្យ

ស្តីពី

ការតែងតាំងលោក ឈាង ប៊ុនណារិទ្ធ ជាទីប្រឹក្សារាជរដ្ឋាភិបាល

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ឃ្លាំមើលដោយ

ព្រះរាជក្រឹត្យ នស/រកត/០៩១៥/៩៨៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី ការតែងតាំងលោក ឈាង ប៊ុនណារិទ្ធ ជាទីប្រឹក្សារាជរដ្ឋាភិបាល

ព្រះរាជក្រឹត្យ

ស្តីពី

ការតែងតាំងលោក ឈាង ប៊ុនណារិទ្ធ ជាទីប្រឹក្សារាជរដ្ឋាភិបាល

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ឃ្លាំមើលដោយ

ព្រះរាជក្រឹត្យ នស/រកត/០៩១៥/៩៨៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី ការតែងតាំងលោក ឈាង ប៊ុនណារិទ្ធ ជាទីប្រឹក្សារាជរដ្ឋាភិបាល

**ខ្ញុំបាទសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសឱ្យដឹងថា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៨៧ សជ

សារាចរ

ស្តីពី

វិធានទិន្នន័យវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅខែធ្នូ ឆ្នាំ២០០៤ សម្រាប់រយៈពេលវែង ក្នុងគោលដៅប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ ដែលមានលក្ខណៈវិមជ្ឈការ ផ្តោតលើធាតុចេញ និងសមិទ្ធកម្ម នៅឆ្នាំ២០២៥ តាមរយៈការអនុវត្តអភិក្រមបោះជំហាន តាមដំណាក់កាល ដូចខាងក្រោម÷

- ដំណាក់កាលទី១ : "ភាពជឿទុកចិត្តបាននៃថវិកា" ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨,
- ដំណាក់កាលទី២ : "គណនេយ្យភាពហិរញ្ញវត្ថុ" ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥,
- ដំណាក់កាលទី៣ : "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ និង
- ដំណាក់កាលទី៤ : "គណនេយ្យភាពចំពោះសមិទ្ធកម្ម" ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។

ដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តផែនការសកម្មភាពរួម ដែលត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល តាមសំណើរបស់ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា "**គ.ហ.ស.**" ដើម្បីក្រសួង-ស្ថាប័ននីមួយៗ រៀបចំនិងអនុវត្តផែនការសកម្មភាពលម្អិត ដោយមានសង្គតិភាពនិងប្តូរណាភាព ជាមួយនឹងផែនការសកម្មភាពរួម។

អនុលោមតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើត "ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" មួយ ដែលហៅកាត់ថា "**ក.ហ.ស.**" នៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។

ដើម្បីធានាសង្គតិភាពនិងសមានគតិភាពនៃការរៀបចំ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្ត ព្រមទាំង សុក្រឹតភាពនិងភាពទាន់ពេលនៃការត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាល ធ្វើការណែនាំដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគ្រប់ក្រសួង-ស្ថាប័ន ដែលចូលរួមក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវយន្តការ វិធាន និងនីតិវិធី ដូចតទៅ÷

ក. យន្តការស្ថាប័ន

ក.ហ.ស. នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នីមួយៗ ត្រូវមានសមាសភាព ដូចតទៅ÷

ក.១. សមាសភាព ក.ហ.ស. នៅតាមក្រសួង-ស្ថាប័ន

ក.១.១. ប្រធាន ក.ហ.ស.

ក.ហ.ស. ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងនៃក្រសួង-ស្ថាប័ន ០១ រូប ដែលជាសមាជិក **ក.ហ.ស.** ដែលត្រូវជារដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំមួយរូប ដែលទទួលបន្ទុកជួយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ផ្ទាល់លើការងារហិរញ្ញវត្ថុ របស់ក្រសួង-ស្ថាប័ន។

ក.១.២. អនុប្រធាន ក.ហ.ស.

ក្រសួង-ស្ថាប័ន នីមួយៗ ត្រូវចាត់តាំងឱ្យមានអនុប្រធាន **ក.ហ.ស.** ០១ រូប ដែលជាអនុរដ្ឋលេខាធិការ ឬ អគ្គលេខាធិការ ឬ អគ្គនាយកទទួលបន្ទុកហិរញ្ញវត្ថុ ឬថ្នាក់ដឹកនាំដែលបំពេញការងារផ្ទាល់ជាមួយប្រធាន **ក.ហ.ស.**។

ក.១.៣. សមាជិក ក.ហ.ស.

ក្រសួង-ស្ថាប័ន នីមួយៗ ត្រូវចាត់តាំងសមាជិក នៃ **ក.ហ.ស.** ដែលមានសមាសភាព ដូចតទៅ÷

- តំណាង ០១ រូប នៃគ្រប់អគ្គនាយកដ្ឋាន ឬ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមឱវាទក្រសួង-ស្ថាប័នផ្ទាល់ និង
- តំណាង ០១ រូប នៃគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួង-ស្ថាប័នសាមី នីមួយៗ។

ក.១.៤. លេខាធិការ ក.ហ.ស.

ក្រសួង-ស្ថាប័ន នីមួយៗ ត្រូវចាត់តាំងឱ្យមានលេខាធិការ **ក.ហ.ស.** ០១ រូប ឬមួយចំនួន តាមការចាំបាច់ ដែលជាមន្ត្រីបង្គោលតែងតាំងដោយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ស្របតាមសំណើនិងលក្ខខណ្ឌយោងការងារ ដែលកំណត់ដោយប្រធាន **ក.ហ.ស.**។

សមាសភាពជាក់ស្តែង នៃ **ក.ហ.ស.** ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីនីមួយៗ ដោយមានការឯកភាពពីប្រធាន **ក.ហ.ស.**។

កិច្ចដំណើរការនៃ **ក.ហ.ស.** នៅតាមក្រសួង-ស្ថាប័ន នីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន។

ក.២. សមាសភាព ក.ហ.ស. នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំបង្កើត **ក.ហ.ស.** នៅតាមសាមីអង្គភាព នីមួយៗ ដែលត្រូវមានសមាសភាពដូចតទៅ÷

- អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ		ប្រធាន
- អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង	០១រូប	អនុប្រធានប្រចាំការ
- អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង	០១ ឬ ច្រើនរូប	អនុប្រធាន
- ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទ	០១ ឬ ច្រើនរូប	សមាជិក

- មន្ត្រីជំនាញពាក់ព័ន្ធក្រោមឱវាទ ០១ ឬ ច្រើនរូប សមាជិក
- មន្ត្រីបង្គោល ដែលជាអ្នកទទួលបន្ទុកហិរញ្ញវត្ថុសម្រាប់
  អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន ០១ ឬច្រើនរូប លេខាធិការ។

អគ្គនាយកដ្ឋាន ដែលមានមន្ត្រីបង្គោលច្រើនរូប អាចរៀបចំបង្កើតជាក្រុមមន្ត្រីបង្គោលបាន តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ដើម្បីសម្របសម្រួលការងារផ្ទៃក្នុង និងជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា "**អ.គ.ហ.**"។

សមាសភាពជាក់ស្តែង នៃ **ក.ហ.ស.** នៅតាមអង្គភាពក្រោមឱវាទនីមួយៗ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កិច្ចដំណើរការនៃ **ក.ហ.ស.** នៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រធាន **ក.ហ.ស.** នីមួយៗ។

ខ. ទិដ្ឋានន៍និតិវិធី នៃការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ក្រសួង ស្ថាប័ន និងអង្គភាពនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំផែនការសកម្មភាពលម្អិតអនុលោមតាមក្របខ័ណ្ឌផែនការសកម្មភាពរួម សម្រាប់ដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ខ.១. ការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: របស់ក្រសួង-ស្ថាប័ន

ក.ហ.ស. នៅតាមក្រសួង-ស្ថាប័ននីមួយៗ មានភារកិច្ចសម្របសម្រួលនិងបូកសរុបផែនការសកម្មភាព ពីគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ រួចផ្ញើមក **អ.គ.ហ.** ដើម្បីពិនិត្យ ផ្តល់យោបល់ និងកែលម្អ។

ផែនការសកម្មភាព របស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវចុះហត្ថលេខាដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីនីមួយៗ បន្ទាប់ពីមានការឯកភាពពីប្រធាន **ក.ហ.ស.** និងត្រូវផ្ញើជូនប្រធាន **ក.ហ.ស.** តាមកាលកំណត់។

ខ.២. ការរៀបចំ ផែនការសកម្មភាព របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក.ហ.ស. នៃអង្គភាពនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលលើការរៀបចំនិងបូកសរុបផែនការសកម្មភាព ពីគ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដែលការងារនេះត្រូវដឹកនាំផ្តាល់ដោយប្រធាន **ក.ហ.ស.** ដោយមានមន្ត្រីបង្គោល ឬ ក្រុមមន្ត្រីបង្គោលរបស់ខ្លួន ជាសេនាធិការ និងត្រូវផ្ញើមក **អ.គ.ហ.** ដើម្បីពិនិត្យ ផ្តល់យោបល់ និងកែលម្អ។,

ផែនការសកម្មភាព របស់អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចុះហត្ថលេខាទទួលស្គាល់ដោយប្រធានអង្គភាពនីមួយៗ និងត្រូវផ្ញើមក **អ.គ.ហ.** បូកសរុបជាផែនការសកម្មភាពរួម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងពិភាក្សាក្នុងគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬសម្រេចចុះហត្ថលេខា ដាក់ឱ្យអនុវត្តជាផ្លូវការ។

ការរៀបចំផែនការថវិកានិងការអនុវត្តថវិកា សម្រាប់ការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តតាមវិធានន៍និងនីតិវិធីជាធរមាន ដែលត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ. វិធានដ៏និងនីតិវិធី នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវអនុវត្តផែនការសកម្មភាព ដែលត្រូវបានដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករនិងគោលដៅនៃសកម្មភាពនីមួយៗ តាមកាលកំណត់។

ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការតាមដានវឌ្ឍនភាពជាប្រចាំ ត្រូវបានដាក់ឱ្យអនុវត្ត ដូចតទៅ÷

គ.១. កិច្ចប្រជុំប្រចាំខែ

- សម្រាប់ក្រសួង-ស្ថាប័ន÷ **ក.ហ.ស.** នៃក្រសួង-ស្ថាប័ននីមួយៗ រៀបចំកិច្ចប្រជុំប្រចាំខែរបស់ខ្លួន និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំខែ តាមទម្រង់ដែលត្រូវកំណត់ដោយ **អ.គ.ហ.** មក **អ.គ.ហ.** នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។ ក្នុងករណីចាំបាច់ មន្ត្រីជំនាញទទួលបន្ទុកពាក់ព័ន្ធនៃ **អ.គ.ហ.** អាចត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ។
- សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ **ក.ហ.ស.** នៃអង្គភាពនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំប្រចាំខែរបស់ខ្លួន ដោយមានការចូលរួមពីមន្ត្រីជំនាញទទួលបន្ទុកពាក់ព័ន្ធនៃ **អ.គ.ហ.** និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំខែ តាមទម្រង់ដែលត្រូវកំណត់ដោយ **អ.គ.ហ.** មក **អ.គ.ហ.** នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។
- កិច្ចប្រជុំប្រចាំខែរវាង **អ.គ.ហ.** ជាមួយ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនៅក្នុងសប្តាហ៍ទី២ នៃខែបន្ទាប់ ឬ តាមការចាំបាច់ ដើម្បីពិនិត្យនិងពិភាក្សាលើវឌ្ឍនភាពប្រចាំខែ បញ្ហាប្រឈម និងសំណូមពរ ព្រមទាំងសំណើដំណោះស្រាយ ជូនប្រធាន **គ.ហ.ស.** ពិនិត្យនិងសម្រេច សម្រាប់ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

គ.២. កិច្ចប្រជុំប្រចាំត្រីមាស

វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានត្រួតពិនិត្យតាមដានជាប្រចាំត្រីមាស តាមរយៈកិច្ចប្រជុំ ដែលត្រូវរៀបចំក្នុងខែទីមួយ នៃត្រីមាសបន្ទាប់ ឬ តាមការចាំបាច់ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។ កិច្ចប្រជុំប្រចាំត្រីមាស រួមមានដូចតទៅ÷

- កិច្ចប្រជុំ នៃគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កិច្ចប្រជុំ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- កិច្ចប្រជុំ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយតំណាងដៃគូអភិវឌ្ឍន៍។

គ.៣. ការកែសម្រួលផែនការសកម្មភាព នៅក្នុងត្រីមាសទី៣

ក.ហ.ស. នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនីមួយៗក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យឡើងវិញនិងអាចស្នើកែសម្រួល តាមការចាំបាច់ នូវផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងអង្គភាពសាមី សម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់ ដោយសហការនិងសម្របសម្រួលជាមួយ **អ.គ.ហ.** ដើម្បីពិនិត្យនិងផ្តល់យោបល់ ក្នុងអំឡុងត្រីមាសទី៣ នៃឆ្នាំនីមួយៗ។

ផែនការសកម្មភាពកែសម្រួល សម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់នេះ ត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីប្រធាន **គ.ហ.ស.** និងបញ្ជូនមកប្រធាន **គ.ហ.ស.** ឱ្យបានយ៉ាងយូរត្រឹមដំណាច់ត្រីមាសទី៣។

ការកែសម្រួលផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុលោមតាមវិធាននិងនីតិវិធីនៃការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងចំណុច "**ខ.**" ខាងលើ។

គ.៤. កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ

ការអនុវត្តផែនការសកម្មភាព របស់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវត្រួតពិនិត្យក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដែលជាកិច្ចប្រជុំត្រួតពិនិត្យតាមដានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទូទាំងក្រសួង-ស្ថាប័ន។

កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវរៀបចំនៅក្នុងត្រីមាសទី ១ នៃឆ្នាំបន្ទាប់ ឬ តាមពេលវេលាជាក់ស្តែង ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

ខ្លឹមសារសំខាន់ៗនៃកិច្ចប្រជុំប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវមានកត់ត្រាក្នុងរបាយការណ៍ និងសេចក្តីសម្រេចសង្ខេបនៃកិច្ចប្រជុំ ដែលត្រូវផ្សព្វផ្សាយជូនគ្រប់ក្រសួង ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ.៥. យន្តការដោះស្រាយកិច្ចប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តយន្តការដោះស្រាយកិច្ចប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

ឃ. វិធាននិងនីតិវិធី នៃការត្រួតពិនិត្យតាមដាននិងវាយតម្លៃ លើការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ឃ.១. ការរៀបចំនិងបូកសរុបរបាយការណ៍សមិទ្ធកម្ម

ចំពោះសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនិងបូកសរុបបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ព្រមទាំងត្រូវផ្ញើមក **អ.គ.ហ.** តាមកាលបរិច្ឆេទកំណត់ ដូចតទៅ÷

- របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ÷ យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃត្រីមាសបន្ទាប់។
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ÷ យ៉ាងយូរត្រឹមដំណាច់ខែទីមួយ នៃឆ្នាំបន្ទាប់។

របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវរៀបចំតាមទម្រង់ ដែលកំណត់ដោយប្រធាន **គ.ហ.ស.** តាមសំណើរបស់ **អ.គ.ហ.**។

របាយការណ៍សមិទ្ធកម្ម ដែលត្រូវបានផ្ញើមក **អ.គ.ហ.** ក្រោយកាលបរិច្ឆេទកំណត់ខាងលើ អាចជាកម្មវត្ថុនៃការបដិសេធក្នុងការពិនិត្យនិងបូកសរុប ដោយ **អ.គ.ហ.**។

ប.២. ការរៀបចំនិងបូកសរុបរបាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម

របាយការណ៍សមិទ្ធកម្ម របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនិងបូកសរុបជារបាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម ដោយ **អ.គ.ហ.** ដើម្បីដាក់ជូនកិច្ចប្រជុំនៃ **គ.ហ.ស.** ពិនិត្យនិងសម្រេច។

ប.៣. ការវាយតម្លៃសមិទ្ធកម្ម

ការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ មានគោលដៅវាស់វែងប្រចាំឆ្នាំ អំពីកម្រិតសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិងវិធីសាស្ត្រ នៃការវាយតម្លៃ ដូចតទៅ÷

- **មូលដ្ឋាននៃការវាយតម្លៃ មាន ២ គឺ÷**
  ១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត
  ២. លទ្ធផលសម្រេចបាន ធៀបនឹងគោលដៅសូចនាករសមិទ្ធកម្ម។
- **វិធីសាស្ត្រនៃការវាយតម្លៃសមិទ្ធកម្ម ផ្អែកលើការកំណត់ទម្ងន់ ជាភាគរយ (%) ដែលមាន ២ កម្រិត ដូចតទៅ÷**
  ១. កម្រិតផ្នែក គោលបំណង ចង្កោមសកម្មភាព នៃក្របខ័ណ្ឌផែនការសកម្មភាពរួម ត្រូវកំណត់ដោយ **គ.ហ.ស.**។
  ២. កម្រិតសកម្មភាពលម្អិត (កម្រិត ៣ ខ្ទង់) នីមួយៗ ត្រូវកំណត់ដោយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយ **អ.គ.ហ.**។

មូលដ្ឋាន រូបមន្ត និងវិធីសាស្ត្រនៃការកំណត់ទម្ងន់ និងការវាយតម្លៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវសម្រេច និងដាក់ឱ្យអនុវត្តដោយប្រធាន **គ.ហ.ស.**។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំត្រីមាស នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានផ្សព្វផ្សាយ បន្ទាប់ពីមានការសម្រេចក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានផ្សព្វផ្សាយ តាមការសម្រេចរបស់ប្រធាន **គ.ហ.ស.**។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំឆ្នាំ និងរបាយការណ៍វាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ញើជូននាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេចផ្តល់ចំណាត់ការបន្ត។

ខ. ទិដ្ឋភាពលើកទឹកចិត្ត និងទិដ្ឋភាពរឹតត្បិត

សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវយកធ្វើជាមូលដ្ឋាននៃការពិចារណាអំពីការផ្តល់ការលើកទឹកចិត្ត និង ការរឹតត្បិត ដោយគិតគូរបន្ថែមអំពីធនធានមនុស្ស សម្ភារៈ បច្ចេកទេស និងហិរញ្ញវត្ថុ ដែលត្រូវបានផ្តល់ជូនជាមធ្យោបាយ សម្រាប់អនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត ចែកចេញ ជា ២ កម្រិត ដូចតទៅ÷

- កម្រិតស្ថាប័ន÷ វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត អាចអនុវត្តចំពោះឥណទានថវិកាចរន្តក្នុងឆ្នាំ ដែលកំពុងដំណើរការ ឬ ចំពោះដំណើរការពិភាក្សា ឬ ចរចាឥណទានថវិកានៃឆ្នាំបន្ទាប់ សម្រាប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នីមួយៗ។
- កម្រិត **ក.ហ.ស.** ÷ វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត អាចអនុវត្តចំពោះសមាសភាពនៃ **ក.ហ.ស.** នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលអាចជាការផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង គុណបំណាច់ ឬវិធានការរឹតត្បិតនានា តាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត ជាក់ស្តែង ត្រូវដាក់ឱ្យអនុវត្តដោយប្រធាន **ក.ហ.ស.** អនុលោមតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

ទទួលបានសារាចរនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ខ្ទបសម្ព័ន្ធទី៦. ប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពី ការបង្កើត
គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ប្រកាស
ស្តីពី
ការបង្កើតគណៈកម្មការកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រួច

ប្រការ១._

ត្រូវបានបង្កើត គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "កសហវ" ដែលសរសេរជាអក្សរកាត់ថា "**គ.ក.ហ.**" ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ២._

គ.ក.ហ. មានសមាសភាពដូចតទៅ ÷

១. រដ្ឋមន្ត្រី	កសហវ		ប្រធាន
២. រដ្ឋលេខាធិការ	កសហវ	១រូប	អនុប្រធានអចិន្ត្រៃយ៍
៣. រដ្ឋលេខាធិការ	កសហវ	ផ្សេងទៀត	អនុប្រធាន
៤. អគ្គលេខាធិការ	អ.គ.ហ		អនុប្រធានប្រចាំការ
៥. អនុរដ្ឋលេខាធិការ	កសហវ		សមាជិក
៦. អគ្គលេខាធិការ	កសហវ		សមាជិក
៧. អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន	កសហវ		សមាជិក
៨. អគ្គាធិការនៃអគ្គាធិការដ្ឋាន	កសហវ		សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ក.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ៣._

គ.ក.ហ. មានមុខងារនិងភារកិច្ចដូចតទៅ÷

- ធ្វើជាចំណុចប្រមូលផ្តុំរបស់ កសហវ ក្នុងការរៀបចំនិងតាមដានការអនុវត្តផែនការសកម្មភាពរបស់ កសហវ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលការងារកែទម្រង់នេះ ជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ រួមទាំងរាជធានី ខេត្ត
- ពិនិត្យនិងសម្រេចលើចក្ខុវិស័យ គោលបំណង កម្មវិធី និងផែនការសកម្មភាព របស់ កសហវ ក្នុងក្របខណ្ឌការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ
- ដឹកនាំនិងតាមដានការអនុវត្តចក្ខុវិស័យ គោលបំណង កម្មវិធី និងផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធានាឱ្យបាននូវសង្គតិភាព លំដាប់លំដោយត្រឹមត្រូវ និងប្រសិទ្ធភាពខ្ពស់ នៅក្នុងកិច្ចដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ
- សម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ ជាមួយការងារកែទម្រង់ផ្សេងទៀតរបស់ រាជរដ្ឋាភិបាល
- ធ្វើជាចំនុចប្រមូលផ្តុំរបស់ កសហវ ក្នុងការកៀរគរជំនួយនិងការសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ កសហវ ជាមួយដៃគូអភិវឌ្ឍន៍នានា។

ប្រការ៤.-

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាននិងសមាជិក **គ.ក.ហ** ត្រូវចូលរួមប្រជុំសាមញ្ញរបស់ខ្លួនក្នុងមួយខែមួយដង ឬញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ។

ប្រធាន **គ.ក.ហ** អាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនានានៃ កសហវ ដែលមិនមែនជាសមាជិកនៃ **គ.ក.ហ.** ឱ្យចូលរួមប្រជុំ ទៅតាមតម្រូវការចាំបាច់នៃការងារ។

ប្រការ៥.-

ក្នុងករណីអវត្តមាន សមាជិកនៃ **គ.ក.ហ** ដែលជាអគ្គលេខាធិការ អគ្គនាយក ឬអគ្គាធិការ អាចស្នើសុំការអនុញ្ញាតពីប្រធាន **គ.ក.ហ** ដើម្បីចាត់តាំងអគ្គលេខាធិការរង អគ្គនាយករង ឬអគ្គាធិការរងមួយរូបឱ្យចូលរួមប្រជុំជំនួស។

សមាជិក **គ.ក.ហ** អាចស្នើសុំការអនុញ្ញាតពីប្រធាន **គ.ក.ហ** ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារកែទម្រង់ នៅក្នុងអង្គភាពរបស់ខ្លួន ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ។

ប្រការ៦.-

គ.ក.ហ មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសេនាធិការបច្ចេកទេសរបស់ខ្លួន ក្នុងការបំពេញការងារ។

ប្រការ៧.-

គ.ក.ហ ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន។

ប្រការ៨.-

ត្រូវបាននិរាករ ដូចតទៅ÷

- ប្រកាសលេខ ៤៥១ សហវ.ប្រក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ០៣៦ សហវ.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើតអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៣៥ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមសម្របសម្រួល នៃក្រសួង ស្ថាប័ន
- សេចក្តីសម្រេចលេខ ០៣៤ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៣៣ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស
- ប្រកាសលេខ ១២០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ប្រកាសលេខ ១៥០ សហវ.ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអនុគណៈកម្មាធិការសម្រាប់ជំរុញការអនុវត្តការងារក្នុងក្របខណ្ឌគម្រោងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យា
- ប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមការងាររៀបចំមាតិកាគណនេយ្យនិងថវិកាថ្មី
- ប្រកាសលេខ ២៩០ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតអនុគណៈកម្មាធិការជ្រើសរើសនិងផ្តល់ការលើកទឹកចិត្ត នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកម្មវិធីកន្សោមអាទិភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ៥៨៨ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការផ្ទេរមុខងារបន្ថែមឱ្យទៅអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រកាសលេខ ៥៩២សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់
- ប្រកាសលេខ ២២៥សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៩.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ខ្ញុំសម្តែងនូវ. ប្រកាសលេខ ៣៤៧ សហវ.ប្រក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ស្តីពី ការរៀបចំ
និងការប្រព្រឹត្តទៅនៃមន្ត្រាពង្រាយវិទ្យាទរអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជីកឆាំ
ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....សហវ.....

ប្រកាស
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

សម្រួច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១._

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជីកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា "**អ.គ.ហ.**"។

ប្រការ២._

ប្រកាសនេះ មានគោលបំណង ដូចខាងក្រោម÷

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ **អ.គ.ហ.**
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពក្រោមឱវាទ **អ.គ.ហ.**
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ប្រការ៣._

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់អង្គភាពក្រោមឱវាទ **អ.គ.ហ.**។

ជំពូកទី២

បេសកកម្មនិងរចនាសម្ព័ន្ធ

ប្រការ៤._

ក្នុងការបំពេញមុខងាររបស់ខ្លួន ជាសេនាធិការរបស់គណៈកម្មាធិការជីកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា "**គ.ហ.ស.**", **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** ស្របតាមការណែនាំ និងការសម្រេចរបស់ **គ.ហ.ស.** ដោយរួមទាំងការរៀបចំដាក់ឱ្យអនុវត្ត និងការតាមដានត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការរៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ
- សម្របសម្រួលប្រចាំថ្ងៃ លើការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្ម និងផ្នែកភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សហការនិងសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ផ្តល់ការគាំទ្រដល់ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ដោយ

រាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន ដោយរាប់បញ្ចូលបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្តត់ផ្តង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- សម្របសម្រួល ប្រមូលផ្តុំ លើកសំណើ និងដាក់ឱ្យអនុវត្តវិធានការណ៍កែទម្រង់ តាមរយៈការបណ្តុះគំនិតផ្តួចផ្តើមនិងការបង្កើននវានុវត្តន៍ ក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងដំណើរការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ប្រការ៥._

អ.គ.ហ. មានរចនាសម្ព័ន្ធដូចខាងក្រោម÷

១. ផ្នែកគោលនយោបាយ

២. ផ្នែកចំណូល

៣. ផ្នែករៀបចំថវិកា

៤. ផ្នែកអនុវត្តថវិកា

៥. ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ

៦. ផ្នែកគាំទ្រទូទៅនិងកសាងសមត្ថភាព

៧. ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ។

ប្រការ៦._

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គការលេខរបស់ **អ.គ.ហ.** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ជំពូកទី៣
ផ្នែកគោលនយោបាយ

ប្រការ៧._

ផ្នែកគោលនយោបាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញ ល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករគម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្តត់ផ្តង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ប្រការ៨._

ផ្នែកគោលនយោបាយ ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ÷ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- ស្ថាប័នសេវាសេដ្ឋកិច្ច ដែលរួមមាន ÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជំពូកទី៤
ផ្នែកចំណុច

ប្រការ៩._

ផ្នែកចំណុច មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំជាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញ ល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការ រៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើន ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ របស់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាម ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការ ផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់ រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានា សង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាព ពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ប្រការ១០._

ផ្នែកចំណូល ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ÷ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេស និងសេវាសាធារណៈ:ទូទៅ ដែលរួមមាន÷ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន និងក្រសួងផែនការ។

ជំពូកទី៥
ផ្នែករៀបចំថវិកា

ប្រការ១១._

ផ្នែករៀបចំថវិកា មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ននិងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្តត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ប្រការ១២._

ផ្នែករៀបចំថវិកា ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ÷ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

  ស្ថាប័នសេវាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលរួមមាន÷ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ "សន្តិសុខសាធារណៈ" និង "រដ្ឋបាលទូទៅ" ក្រសួងបរិស្ថាន ក្រសួងយុត្តិធម៌ សាលាឧទ្ធរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី៦
ផ្នែកអនុវត្តថវិកា

ប្រការ១៣._

ផ្នែកអនុវត្តថវិកា មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត

ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្តត់ផ្តង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ប្រការ១៤._

ផ្នែកអនុវត្តថវិកា ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន÷ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ស្ថាប័នសេវាសង្គមកិច្ច ដែលរួមមាន÷ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងធម្មការនិងសាសនា និងក្រសួងកិច្ចការនារី។

ជំពូកទី៧

ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ

ប្រការ១៥._

សម្រាប់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**

- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតនាក់រកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្តត់ផ្តង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ប្រការ១៦.

សម្រាប់ការងារនវានុវត្តន៍ ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំយន្តការនិងក្របខ័ណ្ឌនៃការបណ្តុះគំនិតផ្តួចផ្តើមនិងបង្កើតនវានុវត្តន៍ ក្នុងការដោះស្រាយបញ្ហាប្រឈមនៃការសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែកផ្សេងទៀតនៃ **អ.គ.ហ.**
- ប្រមូលផ្តុំនិងសម្របសម្រួលការផ្តួចផ្តើមគំនិតនិងនវានុវត្តន៍ ដែលត្រូវបានស្នើឡើងដោយផ្នែកជំនាញ នៃ **អ.គ.ហ.** ដើម្បីដាក់ជូនថ្នាក់ដឹកនាំ **អ.គ.ហ.** ពិនិត្យនិងអនុម័តសំណើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍
- សម្របសម្រួលជាមួយអង្គភាពរបស់ កសហវ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យ កែលម្អ និងសម្រេចលើសំណើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍
- រៀបចំសំណើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ ជូន **អ.គ.ហ.** ដើម្បីដាក់ជូន **គ.ហ.ស.** ពិនិត្យនិងសម្រេច លើវិធានការណ៍គំនិតផ្តួចផ្តើមនិងនវានុវត្តន៍
- សម្របសម្រួលការរៀបចំនិងការអនុវត្តវិធានការណ៍គំនិតផ្តួចផ្តើមនិងនវានុវត្តន៍ នៅក្នុងកិច្ចដំណើរការនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ ដែលត្រូវបានដាក់ចេញនៅក្នុងកិច្ចដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ប្រការ១៧._

សម្រាប់ការងារផ្សព្វផ្សាយ ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំសិក្ខាសាលា សន្និសីទ សន្និសីទកាសែត វេទិកាសាធារណៈ បទឧទ្ទេសនាម តាមក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សា និងគ្រឹះស្ថានសាធារណៈ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងគ្រប់គ្រងការបោះពុម្ពនិងការផ្សព្វផ្សាយព្រឹត្តិប័ត្រ ខិតប័ណ្ណ និងឯកសារផ្សេងទៀតពាក់ព័ន្ធកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងសម្របសម្រួលផលិតកម្មខ្សែភាពយន្តខ្លីពាក់ព័ន្ធកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំកម្មវិធីផ្សព្វផ្សាយផ្សេងទៀត ដើម្បីបង្កើនការយល់ដឹង ការទទួលស្គាល់អំពីភាពចាំបាច់ និងការចេះដឹងអំពីទស្សនវិស័យ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនសាធារណជន គ្រប់ស្រទាប់ជាន់ថ្នាក់ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ តាមការសម្រេចរបស់ **អ.គ.ហ.**។

ប្រការ១៨._

សម្រាប់ការងារនវានុវត្តន៍និងផ្សព្វផ្សាយ ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយទទួលបន្ទុកសម្របសម្រួលជាមួយគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គ្រប់ក្រសួង ស្ថាប័ន។

ជំពូកទី៨

ផ្នែកគាំទ្រទៅនិងកសាងសមត្ថភាព

ប្រការ១៩._

ផ្នែកគាំទ្រទៅនិងកសាងសមត្ថភាព មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងសក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល

- ផ្តល់ការគាំទ្រ ដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សួចនាការម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់លើការផ្តត់ផ្តង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- ពិនិត្យ បូកសរុប និងផ្តល់យោបល់លើផែនការបណ្តុះបណ្តាលដែលស្នើឡើងដោយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងតាមដានដំណើរការនៃការបណ្តុះបណ្តាល
- រៀបចំនិងសម្របសម្រួលលើការងារគាំទ្រទូទៅ កសាងសមត្ថភាព និងការលើកទឹកចិត្ត ជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ចូលរួមពិនិត្យនិងផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា លើការជ្រើសរើសបុគ្គលិក/មន្ត្រី និងជំនាញការបច្ចេកទេសសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ប្រការ២០.

ផ្នែកគាំទ្រទូទៅនិងកសាងសមត្ថភាព ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ÷ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋាន
- ស្ថាប័នកំពូលនិងឯករាជ្យ ដែលរួមមាន÷ ក្រសួងព្រះបរមរាជវាំង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា តុលាការកំពូល អង្គភាពប្រតិបត្តិនៃខុទ្ទកម ក្រុមប្រឹក្សានៃអង្គចៅក្រម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។

ជំពូកទី៩
ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ

ប្រការ២១._

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ មានមុខងារនិងភារកិច្ចដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **អ.គ.ហ.** ស្របតាមការណែនាំរបស់អគ្គលេខាធិការនៃ **អ.គ.ហ.**
- សម្របសម្រួលប្រចាំថ្ងៃ លើការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្ម និងផ្នែកភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពិនិត្យ ផ្តល់យោបល់បច្ចេកទេសលើការគ្រប់គ្រងគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- គ្រប់គ្រង ចរាចរ តម្កល់ និងថែរក្សាឯកសាររដ្ឋបាល
- សម្របសម្រួលការងាររដ្ឋបាល របស់ **អ.គ.ហ.** ជាមួយ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- សម្របសម្រួលការងាររវាងអ្នកជំនាញ ឬ ទីប្រឹក្សាបច្ចេកទេស និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនានា
- រៀបចំនិងបូកសរុបផែនការថវិកា និងផែនការលទ្ធកម្ម ដែលបានបញ្ជូនមកដោយភ្នាក់ងារពាក់ព័ន្ធ រួចលើកគម្រោងសរុបផែនការទាំងនេះដាក់ជូនថ្នាក់ដឹកនាំ និងដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យនិងសម្រេច
- រៀបចំ អនុវត្ត និងគ្រប់គ្រងការងារគណនេយ្យនិងហិរញ្ញវត្ថុ ការងារលទ្ធកម្ម និងការងាររដ្ឋបាលរបស់ **អ.គ.ហ.**
- ផ្តល់ជំនួយបច្ចេកទេស ដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនានា សម្រាប់ការងារពាក់ព័ន្ធការរៀបចំ ផែនការថវិកា កិច្ចលទ្ធកម្មផ្សេងៗទៀត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំបញ្ជូលរបាយការណ៍វឌ្ឍនភាពរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនានា និងការងារពាក់ព័ន្ធផ្សេងៗ សម្រាប់បញ្ចូលក្នុងគេហទំព័ររបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងបុគ្គលិករបស់ **អ.គ.ហ.**
- គ្រប់គ្រងនិងបែងចែកសម្ភារៈប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផ្សេងៗ និង
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

ជំពូកទី១០

អវសានប្បញ្ញត្តិ

ប្រការ២២._

ក្នុងការបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញ ដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការនៃ **អ.គ.ហ.** ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬ ស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការកំណត់ឬបែងចែកភារកិច្ចទាំងនោះ។

ប្រការ២៣._

ប្រកាសនេះ មានអានុភាពអនុវត្តជំនួសប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលត្រូវបានសម្រេចដាក់ឱ្យអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ ខាងលើ ត្រូវមានអានុភាពអនុវត្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ២៤._

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥

បណ្តាគ. អួន ព័ន្ធមុនីវត្ថ

កន្លែងទទួល ÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ២៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ៣៧៧សហវ.ប្រក
ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៥

អង្គការលេខ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ស្ថាប័ន សេនាសេដ្ឋកិច្ច	ស្ថាប័ន សេនាហិរញ្ញវត្ថុ ការបរទេស និង សេនាសាធារណៈទូទៅ	ស្ថាប័ន សេនាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ	ស្ថាប័ន សេនាសង្គមកិច្ច	ស្ថាប័ន កំពូល និងឯករាជ្យ
១- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	១- ទីស្តីការគណៈរដ្ឋមន្ត្រី	១- ក្រសួងការពារជាតិ	១- ក្រសួងសុខាភិបាល	១- ក្រសួងព្រះបរមរាជវាំង
២- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម	២- ក្រសួងមុខងារសាធារណៈ	២- ក្រសួងមហាផ្ទៃ "សន្តិសុខសាធារណៈ"	២- ក្រសួងអប់រំ យុវជន និងកីឡា	២-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
៣- ក្រសួងរ៉ែនិងថាមពល	៣- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	៣- ក្រសួងមហាផ្ទៃ "រដ្ឋបាលទូទៅ"	៣- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	៣- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
៤- ក្រសួងពាណិជ្ជកម្ម	៤- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	៤- ក្រសួងបរិស្ថាន	៤- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	៤- អគ្គលេខាធិការដ្ឋានរដ្ឋសភា
៥- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	៥- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	៥- ក្រសួងយុត្តិធម៌	៥- ក្រសួងធម្មការនិងសាសនា	៥-អង្គភាពប្រតិបត្តិក្រុមប្រឹក្សានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
៦- ក្រសួងអភិវឌ្ឍន៍ជនបទ	៦- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	៦- សាលាឧទ្ធរណ៍	៦- ក្រសួងកិច្ចការនារី	៦- តុលាការកំពូល
៧- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	៧- ក្រសួងព័ត៌មាន	៧- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់		៧-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
៨- ក្រសួងសាធារណការ និងដឹកជញ្ជូន	៨- ក្រសួងដែនការ			៨- អាជ្ញាធរសវនកម្មជាតិ
៩- ក្រសួងទេសចរណ៍				៩- អង្គភាពប្រឆាំងអំពើពុករលួយ
១០- ក្រសួងធនធានទឹក និងឧតុនិយម				
១១- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ				

ឧបសម្ព័ន្ធទី៨. សេចក្តីសម្រេចលេខ ០៣៦ សហវ.សសរ.អគហ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០៧៦៩...សហវ...ស.ស.ខ.ស.ស

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹតលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានឃើញប្រកាសលេខ៩៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១ .-

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរអក្សរកាត់ថា **គ.ក.ហ.** ដូចខាងក្រោម ÷

១	ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ	**អូន ព័ន្ធមុនីរ័ត្ន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.)	ប្រធាន
២	ឯកឧត្តម	**ឥន្ទ្រី ឥសម្បុត**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការប្រចាំការ ក.ស.ហ.វ.	អនុប្រធានអចិន្ត្រៃយ៍
៣	ឯកឧត្តមបណ្ឌិតសភាចារ្យ	**ង៉ូ ឥជិវ្ត**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
៤	ឯកឧត្តមបណ្ឌិតសភាចារ្យ	**ហ៊ាន សាហ៊ីប**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
៥	ឯកឧត្តម	**ង៉ី តាយ៉ី**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
៦	ឯកឧត្តម	**ង៉ូ គីមឡេង**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
៧	ឯកឧត្តម	**ស្តើង សុខុម**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
៨	ឯកឧត្តម	**ឥង់ សណ្តាប់**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
៩	ឯកឧត្តម	**រស់ សីលវ៉ា**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធានប្រចាំការ
១០	ឯកឧត្តម	**សួន ម៉េងគា**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១១	ឯកឧត្តម	**ហែម ឥណ្ណឌី**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន

១២	លោកជំទាវ	**កែវ ចរិយា**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១៣	ឯកឧត្តម	**ងាន់ ផល្លា**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១៤	ឯកឧត្តម	**គីម សុត:**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១៥	ឯកឧត្តម	**ឈន សុតាឌ**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១៦	ឯកឧត្តម	**ងាន់ សុធី**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១៧	ឯកឧត្តម	**អឿង ស៊ុនលី**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១៨	ឯកឧត្តម	**ហ៊ែល ចំរើន**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
១៩	ឯកឧត្តម	**ហ៊ុត សុវណ្ណ**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
២០	ឯកឧត្តម	**ងាន់ ឥន្ទ្រ:**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
២១	ឯកឧត្តម	**ម៉ី ង៉ាន់**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
២២	លោកជំទាវ	**ប៉ែន សុបតា**	រដ្ឋលេខាធិការ ក.ស.ហ.វ.	អនុប្រធាន
២៣	ឯកឧត្តម	**ពេជ្រ សម្បត្តិ**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
២៤	ឯកឧត្តម	**ប៉ូ រតនា**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
២៥	ឯកឧត្តម	**ប៉ែន សំអាត**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
២៦	ឯកឧត្តម	**ទេព តិយ្យោរិទ្ធ**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
២៧	ឯកឧត្តម	**ប៉ែន ធីរុទ្ធ**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
២៨	ឯកឧត្តម	**នុប សុធនវិចិត្រ**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
២៩	ឯកឧត្តម	**គង់ ម៉ារី**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
៣០	ឯកឧត្តម	**យ៉ែត ឥណែល**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក
៣១	ឯកឧត្តម	**ចន ណារិទ្ធ**	អនុរដ្ឋលេខាធិការ ក.ស.ហ.វ.	សមាជិក

៣២	ឯកឧត្តម	**ឆួន ច័ន្ទរិទ្ធ**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៣៣	ឯកឧត្តម	**អេង ឆុច**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៣៤	ឯកឧត្តម	**គីម ផល្លា**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៣៥	ឯកឧត្តម	**ហួត ពុំ**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៣៦	ឯកឧត្តម	**ស៊ាង ផល្លា**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៣៧	លោកជំទាវ	**ស៊ុន ណារី**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៣៨	លោកជំទាវ	**លឹម ឈុនឆៃ**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៣៩	ឯកឧត្តម	**ង៉ាន់ ពុទ្ធិពល**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤០	ឯកឧត្តម	**ចាន់ សុភាព**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤១	ឯកឧត្តម	**ឆូវ សុខសម្បត្តិ**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤២	ឯកឧត្តម	**រស់ ច័ន្ទស្រស់**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤៣	ឯកឧត្តម	**ម៉ឹង មករា**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤៤	ឯកឧត្តម	**ស៊ឹម ឥរៈ**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤៥	ឯកឧត្តម	**អូន ប៊ុនហាក់**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤៦	ឯកឧត្តម	**រស់ បរមេ**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤៧	ឯកឧត្តម	**សឹង រេត**	អនុរដ្ឋលេខាធិការ ក.ស.ហ.រ.	សមាជិក
៤៨	ឯកឧត្តម	**គង់ វិបុល**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋ-មន្ត្រីនិងជាអគ្គនាយកនៃអគ្គ-នាយកដ្ឋានពន្ធដារ	សមាជិក
៤៩	ឯកឧត្តម	**គុណ ញឹម**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋ-មន្ត្រីនិងជាអគ្គនាយកនៃអគ្គ-នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា	សមាជិក

៥០	ឯកឧត្តម	**ហាស សុខសេនសាន**	អគ្គលេខាធិការនៃអគ្គ-លេខាធិការដ្ឋាន ក.ស.ហ.វ.	សមាជិក
៥១	ឯកឧត្តម	**ឈាង ឥណ្ណារិទ្ធ**	អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ	សមាជិក
៥២	ឯកឧត្តម	**ហាច រតនៈ**	អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា	សមាជិក
៥៣	ឯកឧត្តម	**ឥទ្ធ ប៊ុនឥន្ទ្រាវុធ**	អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ	សមាជិក
៥៤	ឯកឧត្តម	**ឈឹម សាវ៉ែត**	អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ	សមាជិក
៥៥	ឯកឧត្តម	**នេត មុន្នី**	អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ	សមាជិក
៥៦	ឯកឧត្តម	**កែវ ប៉េងឥណ្ឌន**	អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោម-ជាតិ	សមាជិក
៥៧	ឯកឧត្តម	**ឆាយ រតនៈ**	អគ្គាធិការនៃអគ្គាធិការដ្ឋាន	សមាជិក
៥៨	ឯកឧត្តម	**ឈួន សំរិទ្ធ**	អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល	សមាជិក
៥៩	ឯកឧត្តម	**ឱម ម៉ាក់ឆារិទ្ធ**	អគ្គនាយកនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន	សមាជិក
៦០	ឯកឧត្តម	**ជា ភុជណា**	អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង	សមាជិក
៦១	ឯកឧត្តម	**អិន អេម**	នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
៦២	ឯកឧត្តម	**ស៊ីសុភត្ថិ ជួនចំន្ទោ**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្ម-ធិការជាតិផលិភាពសេដ្ឋកិច្ចកម្ពុជា	សមាជិក

៦៣	ឯកឧត្តម	**ស៊ូ សុជាតិ**	អគ្គនាយក នៃនិយ័តករមូល-បត្រកម្ពុជា	សមាជិក
